៣

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៤០ ខែ មីនា

ព.ស. ២៥១១ គ.ស. ១៩៦៨

-ភ្នំពេញ-

E FRANCAISE
F.744
BIBLIOTHEQUE
P.P.

៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

| អត្ថបទ | ផ្នែកសាសនា | ទំព័រ |
|---|---|---|

១– កឋិនកថាសង្ខេប (ត) សម្ដេចព្រះពោធិវង្ស រៀបរៀង . . . . ២៥១
២– រឿងមាតាព្រះកស្សបៈ (សហ. ប៊ូ-ប៊ូ ប្រែរៀបរៀង) . . . . . ២៦៦

ផ្នែកអក្សរសាស្ត្រ

៣– វចនានុក្រមសំស្ក្រឹត-ខ្មែរ (ព្រះមហា ប៉ាង.ខាត់) . . . . . ២៧៣
៤– ល្បងសិក្សា ប្រវត្តិអក្សរសាស្ត្រខ្មែរ (សហ. លាង.ហ័បអាន) . . ២៧៧
៥– រឿងចៅតែលលក (ត) (សហ. ព្រួប-កុម រៀបរៀង) . . . . ២៨៨
៦– ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត (លោក ញ៉ុក.ថែម) . . . . ២៩៨
៧– ជីវប្រវត្តិ លោក ប៊ូ-ប៊ូ . . . . . . . . . . . ៣០៧
៨– រឿងសាមកុក (ត) (ឧកញ៉ា គូ-កន) . . . . . . . . ៣១៧
៩– ការស្រាវជ្រាវ ប្រវត្តិលោកវិសេស ធួន (បណ្ឌិតមហា ឈឹម.ស៊ុម) . ៣២៩

ផ្នែកកំណត់-ប្រវត្តិការណ៍

១០– ទស្សនកិច្ចនៃសហជីវិនអនុវត្តលេខាធិការ ក្រសួងធម្មការ
នៅខេត្តកោះកុង (សហ. លី-ធាមតេង រៀបរៀង) . . . . ៣៤៥
១១– ពុតហ្លាយថ្វាយពរឆ្នាំថ្មី . . . . . . . . . . . ៣៥៦

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
ប៉ះនេះលោកហៅ ពុទ្ធសាសនា ។

ប. ព.

# កឋិនកថាសង្ខេប

សម្តេចព្រះពោធិវ័ង្ស ហួត-តាត រៀបរៀង

(ត)

ទី ១០– បរិភណ្ឌការណមត្តេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែលើកឡើង នូវអនុវាតខាងទទឹង ឬអនុវាតខាងពោះ ។

ទី ១១– ឱវឌ្ឍេយ្យការណមត្តេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែលើកបញ្ចូលផ្ទាំងសំពត់ថ្មី ពុំនោះគ្រាន់តែលើកផ្ទាំងសំពត់អំពីកឋិនចីវរ ១ ទៅដាក់បញ្ចូលក្នុងកឋិនចីវរឯទៀត ។

ទី ១២– កម្ពលមទ្ទនមត្តេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែដាក់បុះក្នុងទឹកជ្រលក់១ដង មានពណ៌ដូចក្កុកដំរី ឬស្លឹកឈើទុំលឿង ។

ទី ១៣– និមិត្តកតេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលបានមកដោយសារធ្វើនិមិត្តកម្ម គឺនិយាយបញ្ចិតបញ្ចៀងថា " អាត្មានឹងក្រាលកឋិនដោយសំពត់បែបនេះ" ឬនិយាយថា "សំពត់សាដកនេះល្អ អាត្មាអាចនឹងក្រាលកឋិន ដោយសំពត់នេះបាន" ។

ទី ១៤– បរិកថាកតេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលកើតឡើង ដោយសារការនិយាយបញ្ចុះបញ្ចូលទាយកថា "ការប្រគេនសំពត់កឋិន ជាការគួរ ព្រោះទាយកអ្នកប្រគេនសំពត់កឋិន រមែងបានទទួលនូវផលបុណ្យដ៏ប្រសើរ" ។

អដ្ឋកថា ពន្យល់ថា ធម្មតាសំពត់កឋិន ទាល់តែឧក្រិដ្ឋណាស់ ទើបគួរ, ភិក្ខុនិយាយបញ្ចុះបញ្ចូល សូម្បីតែមាតារបស់ខ្លួន ក៏មិនគួរដែរ លុះតែសំពត់នោះប្រាកដដូចជាធ្លាក់ចុះមកពីអាកាស ទើបគួរ ។

ទី ១៥– កុក្កុកតេន ភិក្ខុក្រាលកឋិន ដោយសំពត់ខ្ចីគេ ឬដោយសំពត់ដែលមិនមានទាយកនាំមកប្រគេន គឺសំពត់ស្វែងរកដោយខ្លួនឯង ។

ទី ១៦– សន្និធិកតេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលធ្វើឲ្យទៅជាសន្និធិ គឺទុកសំពត់នៅដៃសង្ឃ ឬនៅដៃនៃភិក្ខុអ្នកក្រាលឲ្យរំលងថ្ងៃ គឺមិនក្រាលឲ្យស្រេចក្នុងថ្ងៃនោះ ។

សន្និធិក្នុងអាការនេះមានពីរយ៉ាងគឺ ករណសន្និធិ ១ និចយសន្និធិ ១ ។ ការដែលភិក្ខុអ្នកក្រាលតំកល់សំពត់កឋិនទុក មិនធ្វើឲ្យ

ហើយកន្លងថ្ងៃនោះ ហៅថា ការណាសន្និធិ ។ សង្ឃបានសំពត់កឋិនមកថ្ងៃនេះ ដល់ថ្ងៃស្អែកទើបប្រគល់ឲ្យទៅភិក្ខុអ្នកក្រាល ហៅថា និចយសន្និធិ ។

ទី១៧- និស្សគ្គិយេន ភិក្ខុក្រាលកឋិន ដោយចីវរជានិស្សគ្គិយៈ គឺចីវរកំពុងតែធ្វើទទួលអរុណរះឡើង ឬចីវរដែលកន្លងរាត្រី ។

ទី១៨- អកប្បកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនបានធ្វើពិន្ទុកប្បៈ ។

ទី១៩- អញ្ញត្រ សង្ឃាដិយា ភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីសង្ឃាដី មានសំពត់កម្រាលជាដើម ។

ទី២០- អញ្ញត្រ ឧត្តរាសង្គេន ឬភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីឧត្តរាសង្គៈ មានសំពត់កម្រាលជាដើម ។

ទី២១- អញ្ញត្រ អន្តរវាសកេន ឬក៏ភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីអន្តរវាសកៈ មានសំពត់កម្រាលជាដើម ។

ទី២២- អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន ភិក្ខុក្រាលកឋិនដោយចីវរក្រៅពីចីវរដែលបានកាត់ជាបញ្ចខណ្ឌ ឬ លើសពីបញ្ចខណ្ឌឡើងទៅ គឺសត្តខណ្ឌ, នវខណ្ឌ និង ឯកាទសខណ្ឌ ព្រមទាំងធ្វើឲ្យប្រកបដោយមណ្ឌល គឺមហាមណ្ឌល និងអឌ្ឍមណ្ឌល ក្នុងថ្ងៃនោះឯង បានសេចក្តីថា

ក្រាលកឋិនដោយចីវរមិនបានប្រកបដោយលក្ខណៈត្រឹមត្រូវ មានមិនបានកាត់ជាបញ្ចខណ្ឌ (ដែលមានកន្ទ្រង់ធំ ៥ មានកន្ទ្រង់តូច ៥) ជាដើម ។

ក្នុងអាការនេះ គម្ពីរអដ្ឋកថា ដីកា បានអធិប្បាយសេចក្ដីពិស្ដារ ដើម្បីឲ្យភិក្ខុសង្ឃងាយយល់ងាយប្រតិបត្តិតាម ដូចមានតទៅនេះ ៖

អដ្ឋកថាប្រាប់ថា ការក្រាលកឋិន ដោយចីវរដែលបានធ្វើឲ្យត្រឹមត្រូវ គឺបានកាត់ដាច់ជាបញ្ចខណ្ឌ ឬ អតិរេកបញ្ចខណ្ឌ សំដែងនូវមហាមណ្ឌល និងអឌ្ឍមណ្ឌល គឺកន្ទ្រង់ធំ និងកន្ទ្រង់តូច ឲ្យឃើញច្បាស់ទើបគួរ ។ មែនពិត, ចីវរដែលធ្វើយ៉ាងនេះ ឈ្មោះថា ធ្វើឲ្យប្រកបដោយមណ្ឌល បើភិក្ខុលើកលែងចីវរបែបនេះចេញ ហើយក្រាលដោយចីវរដទៃទៀត ដែលមិនបានកាត់សោះក្ដី កាត់តែត្រឹម ២ ខណ្ឌ, ៣ ខណ្ឌ, ៤ ខណ្ឌក្ដី មិនគួរទេ ។

គម្ពីរធម្មសម្ពហវិន័យ ថា[1] កឋិនចីវរ ដោយកំណត់យ៉ាងហោចបំផុត ក៏ត្រូវឲ្យបានកាត់ស្បង់មួយដែរ បើធ្វើឲ្យខុសពីនេះ លោកចាត់ជាអត្ថារវិបត្តិ គឺក្រាលខុសមិនបានឡើងជាកឋិនឡើយ ព្រោះហេតុនោះ ចីវរកឋិន បើមិនបានកាត់ដេរឲ្យត្រឹមត្រូវ (ដូចស្បង់លាត ឬ ចីពរខុស សង្ឃាដីខុសជាដើម) មិនគួរទេ ។

---

១ សព្វន្តិមេន បរិច្ឆេទេន អន្តរវាសកោបិ ឆិន្ទិត្វា វ កាតព្វោ អញ្ញថា អត្ថារវិបត្តិ ហោតិ កេនចិ អច្ឆិន្នសិព្វិតំ បន កឋិនំ ន វដ្ដតិ ។

ក្នុងគម្ពីរវជិរពុទ្ធិដីកាថា សំពត់កឋិន កាលបើសង្ឃសូត្រកម្មវាចា ប្រគល់ឲ្យដល់ភិក្ខុអ្នកក្រាលហើយ ភិក្ខុអ្នកក្រាលត្រូវតែកាត់ធ្វើឲ្យប្រកបដោយមណ្ឌលត្រឹមត្រូវជាស្រេចក្នុងថ្ងៃនោះដែរ ។ ក៏ពាក្យដែលព្រះសង្គាហកត្ថេរ ពោលទុកក្នុងគម្ពីរបរិវារៈថា “បុព្វករណៈ សង្គ្រោះដោយធម៌ ៧ ប្រការ” នោះ ចំពោះតែសំពត់ដែលសង្ឃប្រគល់ឲ្យមក នៅជាសំពត់ថ្មីសុទ្ធ គឺសំពត់មិនទាន់ធ្វើជាចីវរនៅឡើយ មិនមែនចំពោះចីវរដែលទាយកវេរប្រគេនមក ដោយបានធ្វើរួចស្រេចមកហើយនោះទេ ។ ព្រោះហេតុនោះ បើទាយកវេរប្រគេន នូវចីវរដែលធ្វើបុព្វករណៈរួចស្រេចមកហើយ សង្ឃត្រូវទទួលហើយសូត្រកម្មវាចា ប្រគល់ឲ្យទៅភិក្ខុអ្នកក្រាលចុះ ។ ឯភិក្ខុអ្នកក្រាលនោះ ត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌលសីមានោះហើយញ៉ាំងសង្ឃឲ្យអនុមោទនាចុះ ព្រោះមិនមានកិច្ចនឹងត្រូវធ្វើបុព្វករណៈ ដែលគេធ្វើរួចស្រេចមកហើយនោះថែមទៀតទេ ។ មែនពិត, ព្រះពុទ្ធដីកានៃព្រះពុទ្ធជាម្ចាស់ដែលព្រះអង្គត្រាស់ថា “ក្រាលកឋិនដោយសំពត់ដែលគ្រាន់តែវាស់គូស ក្រិតស្ទង់មើលទទឹងបណ្តោយប៉ុណ្ណោះ មិនបានឡើងជាកឋិន” ជាដើមនោះ គឺសំដៅយកសំពត់ដែលមកដល់ដៃភិក្ខុអ្នកក្រាល នៅជាសំពត់ថ្មីសុទ្ធ មិនទាន់ធ្វើជាចីវរនៅឡើយ ។

ក្នុងគម្ពីរធម្មសមូហវិន័យ និងគម្ពីរនិបុណ្ណបទសង្គហៈ មានសេចក្តី

បញ្ជាក់រឿងនេះ ដោយធ្វើជាពាក្យបុច្ឆា - វិស្សជ្ជនាដូចតទៅនេះ ៖

ស.(១) បើទាយកប្រគេនចីវរ ដែលមានបរិកម្មសម្រេចរួចហើយ ដើម្បីឲ្យភិក្ខុក្រាលកឋិន តើគួរ ឬមិនគួរ ?

ឆ.(២) អាចារ្យពួកខ្លះ ពោលថាមិនគួរ ព្រោះអាងព្រះពុទ្ធដីកាដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា តទហេវ សញ្ឆិន្នេន ដែលប្រែថា "ត្រូវកាត់ឲ្យហើយក្នុងថ្ងៃនោះ" ។

អ្នកសួរបដិសេធថា(៣) ពាក្យដែលអាចារ្យទាំងនោះពោល មិនគួរទេ ។

អ្នកឆ្លើយសួរតបវិញថា(៤) ហេតុដូចម្ដេច បានជាថាពាក្យនោះមិនគួរ?

អ្នកសួរឆ្លើយថា(៥) បានជាថាពាក្យនោះមិនគួរ ព្រោះអាចារ្យទាំងឡាយដែលពោលមកនោះ មិនដឹងសេចក្ដីអធិប្បាយត្រង់បទថា តទ-ហេវ សញ្ឆិន្នេន នោះឡើយ ឯបុព្វាចារ្យទាំងឡាយអ្នកទ្រទ្រង់វិន័យលោកពោលថាគួរ គឺចីវរកឋិនដែលគេធ្វើស្រេចហើយនោះ ពិតជាគួរ ។

ទី ២៣– អញ្ញត្រ បុគ្គលស្ស អត្ថារា វៀរលែងការក្រាលរបស់បុគ្គល គឺមិនឲ្យបុគ្គលក្រាល ត្រឡប់ជាឲ្យសង្ឃ ឬគណៈក្រាលវិញ ។

---

១ និដ្ឋិតបរិកម្មំ ចីវរំ សចេ ទាយកោ កឋិនត្ថាយ ទេតិ វដ្ដតិ ឧទាហុ ន វដ្ដតិ ។ ២ ឯកច្ចេ តទហេវ សញ្ឆិន្នេនាតិ វុត្តត្តា ន វដ្ដតីតិ វទន្តិ ។ ៣ តំ អយុត្តំ ។ ៤ កស្មា ។ ៥ តទហេវ សញ្ឆិន្នេនាតិ បទស្ស អធិប្បាយំ អជានិត្វា វុត្តត្តា ។ វិនយធរា បន បុព្ពាចរិយា វដ្ដតីតិ វទន្តិ ។

ទី២៤– ន សញ្ញា ចេវ អត្ថតំ ហោតិ កតេញ្ញ និស្សីមដ្ឋោ អនុមោទតិ បើភិក្ខុនៅក្រៅឧបចារសីមា អនុមោទនានូវកឋិនណា កឋិននោះ ឈ្មោះថា ក្រាលមិនត្រឹមត្រូវឡើយ ។

កឋិនដែលភិក្ខុក្រាលមិនឡើងជាកឋិន ដោយអាការ ២៤ នេះឯង ។

អនត្ថតាការ ចប់

---

## អត្ថតាការ

អាការដែលភិក្ខុក្រាលបានឡើងពេញលក្ខណៈជាកឋិន ហៅថា អត្ថតាការ ។

ស. កឋិនដែលភិក្ខុក្រាលឡើង ដោយអាការយ៉ាងណាខ្លះ ?

ឆ. តាមព្រះពុទ្ធដីកា ក្នុងគម្ពីរមហាវគ្គ ថា កឋិនដែលភិក្ខុក្រាលឡើង ដោយអាការ ១៧ គឺ៖

ទី ១– អហតេន ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ថ្មីសុទ្ធ គឺសំពត់ដែលគេមិនទាន់ប្រើ ។

ទី ២- អហតកប្បេន ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ដែលបោកគក់ ១ ដង ឬ ២ ដង ប្រាកដដូចជាសំពត់ថ្មីសុទ្ធ ។

ទី ៣– បិលោតិកាយ ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់សាដកចាស់ ។

ទី ៤– បំសុកូលេន ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់បង្សុកូល ដែលកើតឡើងក្នុងបង្សុកូលខេត្ត ២៣ ដែលគេយកមកវេរប្រគេន ។

ទី ៥– អាបណិកេន ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ដែលធ្លាក់ចុះក្បែរទីផ្សារ ដែលទាយករើសយកមកវេរប្រគេន ។

ទី ៦– អនិមិត្តកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលកើតឡើងដោយធម៌ គឺមិនបានធ្វើនិមិត្តកម្ម បញ្ឆិតបញ្ឆៀង ឲ្យទាយកគេវេរប្រគេនឡើយ ។

ទី៧– អបរិកថាកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលកើតឡើងដោយធម៌ គឺមិនបាននិយាយបញ្ចុះបញ្ចូលទាយក ឲ្យគេវេរប្រគេនឡើយ ។

ទី ៨– អកុក្កុកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលទាយកគេវេរប្រគេន មិនមែនចីវរដែលខ្ចួនខ្ចីគេឡើយ ។

ទី ៩– អសន្និធិកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនបានធ្វើឲ្យជាសន្និធិ ។

ទី ១០– អនិស្សគ្គិយេន ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនមែនជានិស្សគ្គិយៈ ។

ទី ១១– កប្បកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលបានធ្វើ

ពិន្ទុកប្បៈរួចហើយ ។

ទី ១២– សង្ឃាដិយា ភិក្ខុក្រាលកឋិន ដោយសង្ឃាដី ។

ទី ១៣– ឧត្តរាសង្គេន ឬភិក្ខុក្រាលកឋិន ដោយឧត្តរាសង្គៈ ។

ទី ១៤– អន្តរវាសកេន ឬភិក្ខុក្រាលកឋិន ដោយអន្តរ-វាសកៈ ។

( អាការទី ១ ទី ១៣ និងទី ១៤ នេះ មិនមែនត្រូវយកទាំង ៣ មកក្រាលកឋិនទេ ភិក្ខុអ្នកក្រាលត្រូវជ្រើសរើសយកតែ ១ មកក្រាល) ។

ទី ១៥– បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលបានកាត់ដាច់ជាបញ្ចខណ្ឌ ឬជាអតិរេកបញ្ចខណ្ឌ គឺសត្តខណ្ឌ នវខណ្ឌ និងឯកាទសខណ្ឌ ព្រមទាំងធ្វើឲ្យប្រកបដោយមណ្ឌល គឺមហាមណ្ឌល និងអឌ្ឍមណ្ឌល ឲ្យហើយស្រេចក្នុងថ្ងៃនោះ ។

ទី ១៦– បុគ្គលស្ស អត្ថារា មិនវៀរលែងចាកការក្រាលរបស់បុគ្គល គឺភិក្ខុមួយរូបជាអ្នកក្រាល, មិនមែនសង្ឃ ឬគណៈជាអ្នកក្រាលឡើយ ។

ទី ១៧– សម្មា ចេវ អត្ថតំ ហោតិ តញ្ចេ សីមដ្ឋោ អនុមោទតិ បើភិក្ខុនៅក្នុងសីមា អនុមោទនាកឋិនណា កឋិននោះឈ្មោះថា ក្រាលត្រឹមត្រូវ ។

កឋិនដែលភិក្ខុក្រាលឡើង ដោយអាការតាំង ១៧ នេះឯង ។

អត្ថាការ ចប់ ។

---

ឧព្ភារកឋិន "កឋិនដោះ"

ដំណើរកឋិនដោះនេះ ក្នុងគម្ពីរមហាវគ្គ មានព្រះពុទ្ធដីកាផ្ដើមឡើង ជាពាក្យសួរថា ម្នាលភិក្ខុទាំងឡាយ! កឋិនដោះយ៉ាងណាខ្លះ ?

ព្រះពុទ្ធជាម្ចាស់ទ្រង់ឆ្លើយដោយព្រះអង្គឯងថា ម្នាលភិក្ខុទាំងឡាយ! មាតិកា ៨ នេះ ប្រព្រឹត្តទៅដើម្បីដោះនូវកឋិន ឬសម្រាប់កឋិនដោះ ។

ស. ពាក្យថា "កឋិនដោះ" ហាក់ដូចជាកឋិនដោះខ្លួនចេញពីភិក្ខុ ព្រោះកឋិនកើតមានដល់ភិក្ខុ តាំងពីក្រាលរួចហើយ ។ គួរឲ្យឆ្ងល់ថា ហេតុដូចម្ដេច ក៏កឋិនដោះខ្លួនចេញពីភិក្ខុ ? ឬក៏ពាក្យថា "កឋិនដោះ" បានសេចក្ដីដូចម្ដេចទៅវិញ ?

ឆ. ពាក្យថា "កឋិនដោះ" មិនមែនបានសេចក្ដីថា កឋិនរើដោះខ្លួនចេញពីភិក្ខុទេ ។ ពាក្យនេះ បើពោលឲ្យពេញសេចក្ដី ត្រូវពោលថា កឋិនដែលភិក្ខុដោះចេញ ឬដកចេញ គឺភិក្ខុទេ ដែលជាអ្នកដោះឬដកកឋិនចេញ ប៉ុន្តែដល់ពោលឲ្យខ្លីទៅ នៅត្រឹមតែពាក្យថា "កឋិនដោះ" ប៉ុណ្ណោះ ។ រឿងកឋិនដោះនេះ មានសេចក្ដីដូចតទៅនេះ ៖

ភិក្ខុបានក្រាល - អនុមោទនាកឋិនហើយក្នុងពេលណា ឈ្មោះថា

មានកឋិនជាប់នៅនឹងខ្លួនក្នុងពេលនោះ កឋិននោះ នាំឲ្យភិក្ខុមានអានិ-សង្ស ៥ ។ ការចងកឋិនឲ្យជាប់នៅនឹងភិក្ខុអ្នកក្រាល - អនុមោទនាដោយបលិពោធ គឺកង្វល់ដែលទុកដូចជាបំណង មានពីរយ៉ាង គឺ អាវាសបលិពោធ ១ ចីវរបលិពោធ ១ ។ ឯបលិពោធទាំងពីរយ៉ាងនេះជាប់នៅលើរូបភិក្ខុអ្នកក្រាល - អនុមោទនាគ្រប់រូប ។ កាលបើភិក្ខុអ្នកក្រាល-អនុមោទនាកឋិន ធ្វើឲ្យបលិពោធទាំងពីរដែលជាកង្វល់ទុកដូចជាបំណងដាច់ផុតចេញពីខ្លួនក្នុងពេលណា កឋិនក៏ដោះចេញ ឬឃ្លាតចេញពីភិក្ខុអ្នកក្រាល - អនុមោទនា ក្នុងពេលនោះដែរ ។ រឿងកឋិនដោះនេះ នឹងមានសំដែងដោយសព្វគ្រប់ក្នុងមាតិកាទាំង ៨ ប្រការខាងមុខនេះ ប៉ុន្តែមាតិកាទាំង ៨ ប្រការនោះ មានការទាក់ទងនឹងបលិពោធទាំងពីរប្រការដោយជាក់ស្តែង ហេតុនេះ គួរសំដែងនូវបលិពោធទាំងពីរជាមុន រួចសឹមសំដែងនូវមាតិកា ៨ តទៅ ដើម្បីឲ្យភិក្ខុអ្នកសិក្សាបានងាយយល់ដោយឆាប់រហ័ស ។

## បលិពោធ " កង្វល់ "

ក្នុងគម្ពីរមហាវគ្គ មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ! បលិ-ពោធ (កង្វល់) របស់កឋិន មានពីរយ៉ាងគឺ៖

១– អាវាសបលិពោធ "កង្វល់ចំពោះអាវាស" ។ សេចក្តីថា ភិក្ខុក្នុងសាសនានេះ នៅក្នុងអាវាសដែលបានក្រាល-អនុមោទនា

កឋិននោះ មានសេចក្តីអាល័យចំពោះអាវាសដែលខ្លួននៅនោះ, កាលបើចេញពីអាវាសនោះទៅ នៅមានបំណងថា អាត្មាអញនឹងត្រឡប់មកវិញ; យ៉ាងនេះ ហៅថា អាវាសបលិពោធ គឺភិក្ខុអ្នកក្រាល-អនុមោទនាកឋិន នៅមានកង្វល់ក្នុងអាវាស ។

២– ចីវរបលិពោធ "កង្វល់ចំពោះចីវរ" ។ សេចក្តីថា ភិក្ខុក្នុងសាសនានេះ មិនទាន់បានធ្វើចីវរ ឬធ្វើមិនទាន់រួចស្រេច ឬក៏សេចក្តីប្រាថ្នាចំពោះចីវរមិនទាន់ដាច់នៅឡើយ; យ៉ាងនេះហៅថា ចីវរបលិពោធ គឺភិក្ខុអ្នកក្រាល-អនុមោទនាកឋិន នៅមានកង្វល់ចំពោះចីវរ (ដែលត្រូវរក ឬដែលត្រូវធ្វើឲ្យមានគ្រប់គ្រាន់ល្មមប្រើប្រាស់បាន)(១) ។

## មាតិកា

ស. ពាក្យថា មាតិកា បានសេចក្តីដូចម្តេច ?

ឆ. តាមអដ្ឋកថា មានសេចក្តីពន្យល់ថា មាតិកា គឺជាមាតា ឬជាអ្នកបង្កើត ព្រោះមាតិកាទាំង ៨ នោះ ញ៉ាំងកឋិនុព្ភារៈ គឺការដោះកឋិនឲ្យកើត ។

---

១ ក្នុងសម័យយើងសព្វថ្ងៃនេះ ភិក្ខុទាំងឡាយច្រើនតែមានចីវរគ្រប់គ្រាន់ ពុំសូវខ្វះខាត ពុំសូវមានភិក្ខុដែលចេញពីវត្តលំនៅទៅរកចីវរទេ ដោយហេតុនេះ ពួកភិក្ខុច្រើនតែពុំសូវមាន ចីវរបលិពោធ នៅមានត្រឹមតែ អាវាសបលិពោធ ប៉ុណ្ណោះឯង គួរភិក្ខុរក្សា អាវាសបលិពោធ កុំឲ្យដាច់ ។

មាតិកា ៨ នោះ អានសេចក្ដីពន្យល់តទៅនេះគឺ៖

១- បក្កមនន្តិកា មាតិកា មានកិរិយាបៀសចេញទៅចាកកឋិនាវាស គឺអាវាសដែលក្រាល-អនុមោទនាកឋិន ជាទីបំផុត ឬជាកំណត់ ។ សេចក្ដីថា ភិក្ខុក្រាលកឋិន-អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលធ្វើស្រេចហើយ ចេញទៅចាកអាវាស ដោយគិតថា “ អាត្មាអញនឹងមិនត្រឡប់វិញទេ ” ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះត្រង់ការចេញផុតចាកអាវាសជាកំណត់ ។ កឋិនដោះពេលណា អានិសង្ស ៥ របស់ភិក្ខុនោះ ក៏អស់ក្នុងពេលនោះឯង ។

( ក្នុងមាតិកានេះ ចីវរបលិពោធដាច់មុន គឺដាច់តាំងពីនៅក្នុងអាវាស, អាវាសបលិពោធដាច់ក្រោយ ) ។

២- និដ្ឋានន្តិកា មាតិកា មានកិរិយាសម្រេចនៃចីវរជាទីបំផុត ។ សេចក្ដីថា ភិក្ខុបានក្រាល-អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើ ចេញទៅអំពីអាវាសដែលបានក្រាល - អនុមោទនាកឋិន, កាលដែលទៅដល់វត្តដទៃជិតខាង ជាវត្តនៅខាងក្រៅឧបចារសីមា ក៏មានគំនិតកើតឡើងថា “ អញនឹងឲ្យគេជួយធ្វើចីវរក្នុងទីនេះ អញនឹងមិនត្រឡប់វិញទេ ” ។ ភិក្ខុនោះក៏បានធ្វើចីវរហើយស្រេចក្នុងទីនោះទៅ ។ គ្រាន់តែធ្វើចីវររួចស្រេចភ្លាម កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះក្នុងពេលដែលធ្វើចីវររួចស្រេចនោះឯង ។

(ក្នុងមាតិកានេះ អាវាសបលិពោធដាច់មុន ចីវរបលិពោធដាច់ក្រោយ)

៣– សន្និដ្ឋានន្តិកា មាតិកា មានសន្និដ្ឋានគឺសេចក្តីសម្រេចចិត្តជាទីបំផុត ។ សេចក្តីថា ភិក្ខុបានក្រាល – អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសនោះទៅ កាលទៅដល់វត្តជាខាងក្រៅឧបចារសីមាក៏បានសម្រេចចិត្តថា "អញនឹងមិនរកគេឲ្យជួយធ្វើចីវរនេះទេ ទាំងវត្តដែលអាត្មាអញបានក្រាល – អនុមោទនាកឋិន ក៏អញមិនត្រឡប់ទៅវិញឡើយ" ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះក្នុងគ្រាដែលសម្រេចចិត្តនោះឯង ។

(ក្នុងមាតិកានេះ អាវាសបលិពោធ និងចីវរបលិពោធ ដាច់ព្រមគ្នា)

៤– នាសនន្តិកា មាតិកា មានកិរិយាវិនាសចីវរជាទីបំផុត ។ សេចក្តីថា ភិក្ខុបានក្រាល – អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ កាលទៅដល់វត្តជាខាងក្រៅឧបចារ-សីមា ក៏គិតថា "អញនឹងឲ្យគេជួយធ្វើចីវរក្នុងទីនេះ អញនឹងមិនត្រឡប់ទៅកាន់វត្តដើមវិញទេ"; លុះកំពុងតែធ្វើ ចីវរនោះក៏ត្រូវវិនាសដោយហេតុណាមួយ មានចោរលួច ឬភ្លើងឆេះជាដើម ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះក្នុងគ្រាវិនាសចីវរ ។

(ក្នុងមាតិកានេះ អាវាសបលិពោធដាច់មុន ចីវរបលិពោធដាច់ក្រោយ)

៥– សវនន្តិកា មាតិកា មានកិរិយាឮដំណឹងជាទីបំផុត ។

សេចក្តីថា ភិក្ខុបានក្រាល–អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ ដោយគិតថា "អាត្មាអញនឹងត្រឡប់វិញ"; កាលទៅដល់វត្តជាខាងក្រៅឧបចារសីមា ក៏ឲ្យគេជួយធ្វើចីវរ លុះធ្វើចីវរហើយ ក៏បានឮដំណឹងថា "សង្ឃក្នុងវត្តសូត្រដោះកឋិនទៅហើយ" ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះក្នុងគ្រាដែលបានឮដំណឹងនោះឯង ។

(ក្នុងមាតិកានេះ ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ក្រោយ)

៦– អាសាវច្ឆេទិកា មាតិកាប្រកបដោយកិរិយាដាច់បំណង ឬការអស់សេចក្តីសង្ឃឹម ។ សេចក្តីថា ភិក្ខុបានក្រាលកឋិន-អនុ-មោទនាកឋិនរួចហើយ ចេញពីអាវាសទៅដោយមានបំណងនឹងស្វែងរកចីវរក្នុងទីដទៃឯទៀត លុះទៅដល់ខាងក្រៅឧបចារសីមា ក៏គិតថា "អញនឹងស្វែងរកចីវរតែក្នុងទីខាងក្រៅឧបចារសីមានេះ អញនឹងមិនត្រឡប់ទៅវត្តវិញទេ"; ភិក្ខុនោះក៏ស្វែងរកចីវរក្នុងទីនោះ លុះដល់ស្វែងរកមិនបានបំណង ឬ សេចក្តីប្រាថ្នាក្នុងការស្វែងរកចីវរនោះ ក៏ដាច់ទៅ ឬអស់ទៅ ។ កឋិនរបស់ភិក្ខុនោះ ក៏ដោះក្នុងគ្រាដែលដាច់បំណង ឬ អស់សេចក្តីសង្ឃឹមក្នុងការស្វែងរកចីវរនោះឯង ។

(ក្នុងមាតិកានេះ អាវាសបលិពោធដាច់មុន ចីវរបលិពោធដាច់ក្រោយ)

៧– សីមាតិក្កន្តិកា មាតិកា មានកិរិយាកន្លងនូវសីមា គឺខេត្តនៃកឋិនជាទីបំផុត ១ សេចក្តីថា ភិក្ខុបានក្រាល-អនុមោទនាកឋិន

(នៅមានត)

# រឿងមាតាព្រះកុមារកស្សប

អដ្ឋកថាធម្មបទ ភាគទី ៦ អដ្ឋវត្ថុទី ១២

កាលព្រះបរមសាស្តាគង់ក្នុងវត្ត ជេតពន ទ្រង់ប្រារព្ធនឹងមាតាព្រះកុមារកស្សបត្ថេរ សំដែងធម៌ដោយបទគាថា ថា អត្តាហិ អត្តនោ នាថោ ដូច្នេះជាដើម ។

បានឮមកថា មាតារបស់ព្រះថេរៈនោះជាធីតានៃសេដ្ឋីក្នុងនគររាជគ្រឹះ តាំងពីវេលាដឹងក្តីហើយសូមបួស ប៉ុន្តែ បើទុកជាសូមបួសញយ ៗ ក៏នៅតែមិនបានបួស ព្រោះមិនបានអនុញ្ញាតអំពីមាតាបិតា លុះចំរើនវ័យធំឡើងហើយក៏ទៅកាន់ត្រកូលប្តី មានប្តីដូចជាទេវតានៅគ្រប់គ្រងផ្ទះ ។ បំណោរតមកមិនយូរប៉ុន្មាន សត្វកើតក្នុងគភ៌តាំងឡើងក្នុងផ្ទៃរបស់នាង គឺថានាងមានផ្ទៃពោះ ប៉ុន្តែនាងមិនដឹងថាខ្លួនមានផ្ទៃពោះ ធ្វើស្វាមីឲ្យមានសេចក្តីត្រេកអរហើយអង្វរសូមបួស ។ គ្រានោះ ស្វាមីនាំនាងទៅកាន់សំណាក់របស់នាងភិក្ខុនី ដោយគ្រឿងសក្ការៈដ៏ធំ ដោយមិនដឹងខុសត្រូវ ក៏នាំទៅឲ្យបួសក្នុងសំណាក់នាងភិក្ខុនីជាបក្ខពួកនៃព្រះទេវទត្ត ។ សម័យតមក នាងភិក្ខុនីទាំងនោះបានដឹងថានាងភិក្ខុនីដែលបួសថ្មីនោះមានផ្ទៃពោះ ទើបសួរថា នេះជាអ្វី ? នាងឆ្លើយថា បពិត្រនាងម្ចាស់ទាំងឡាយ ! ខ្ញុំមិនដឹងថាជាអ្វីដែរ ប៉ុន្តែឯសីលរបស់ខ្ញុំមិនដាច់ទេ ។ ពួកនាងភិក្ខុនីនាំនាងទៅកាន់សំណាក់ព្រះទេវទត្តសួរថា នាងភិក្ខុនីនេះបួសដោយសទ្ធា

ពួកខ្ញុំមិនដឹងថានាងមានផ្ទៃពោះ ឥឡូវឲ្យពួកខ្ញុំធ្វើយ៉ាងណា ៗ ព្រះទេវ-ទត្ត គិតតែត្រឹមខ្ញុំប៉ុណ្ណោះថា ទោសចូរកុំបង្កើតឡើងដល់ពួកនាងភិក្ខុនីអ្នកធ្វើតាមឱវាទរបស់អញ ទើបប្រាប់ថា ពួកនាងចូរឲ្យនាងភិក្ខុនីនេះសឹកចេញទៅចុះ ៗ នាងភិក្ខុនីក្មេងឮដូច្នោះ ហើយនិយាយថា បពិត្រនាងទាំងឡាយ ! សូមលោកទាំងអស់កុំធ្វើខ្ញុំឲ្យវិនាសឡើយ ខ្ញុំមិនមែនបួសចំពោះព្រះទេវទត្តទេ សូមនាងទាំងឡាយនាំខ្ញុំទៅឯសំណាក់ព្រះសាស្តា ៗ ពួកនាងភិក្ខុនីទាំងនោះនាំនាងទៅឯវត្តជេតពន ក្រាបទូលព្រះសាស្តា ៗ ព្រះសាស្តាសូម្បីទ្រង់ជ្រាបថា នាងមានផ្ទៃពោះតាំងពីនៅជាគ្រហស្ថ ក៏ដើម្បីនឹងបំបាត់នូវពាក្យតិះដៀល ទើបទ្រង់បង្គាប់ឲ្យអញ្ជើញស្តេចព្រះបាទបសេនទិកោសល និងលោកមហាអនាថបិណ្ឌិក, លោកចូឡអនាថ-បិណ្ឌិក, នាងវិសាខា ឧបាសិកា និងត្រកូលធំៗដទៃទៀតជាច្រើនមកប្រជុំ ហើយទ្រង់បង្គាប់ព្រះឧបាលិត្ថេរថាអ្នកចូរទៅ ចូរជម្រះកម្មរបស់នាងភិក្ខុនីក្មេងនេះ ឲ្យស្អាតបរិសុទ្ធកណ្តាលបរិស័ទបួន ៗ ព្រះថេរៈឲ្យអញ្ជើញនាងវិសាខាមកចំពោះព្រះភក្ត្រព្រះរាជា ហើយឲ្យទទួលជម្រះអធិ-ករណ៍នោះ ៗ នាងវិសាខាប្រើមនុស្សឲ្យបាំងរាំងនន រួចពិនិត្យមើលដៃនិងជើងនិងផ្ចិតនិងពោះរបស់នាងភិក្ខុនីក្នុងរាំងនន ហើយរាប់ខែនិងថ្ងៃដឹងថានាងមានផ្ទៃពោះតាំងពីវេលានៅជាគ្រហស្ថ ក៏ទូលសេចក្តីនោះដល់ព្រះថេរៈ ៗ គ្រានោះ ព្រះថេរៈប្រតិស្ឋាន គឺតម្កល់សេចក្តីទុកថា នាង

ភិក្ខុនីនោះជាស្ត្រីបរិសុទ្ធគង់ទីកណ្តាលបរិស័ទ ។ សម័យក្រោយមក នាងប្រសូតបុត្រដែលមានបុណ្យច្រើន ដែលមានសេចក្តីប្រាថ្នាតាំងទុកជិតព្រះបាទរបស់ព្រះពុទ្ធទ្រង់ព្រះនាមថា បទុមុត្តរៈ ។

ថ្ងៃមួយ ព្រះរាជា ស្តេចទៅជិតលំនៅរបស់នាងភិក្ខុនី ទ្រង់បានឮសំឡេងទារកយំ ត្រាស់សួរថា នេះជាសំឡេងអ្វី ? អាមាត្យក្រាបទូលថា សូមព្រះតេជៈតម្កល់លើត្បូង ! បុត្ររបស់នាងភិក្ខុនីនេះកើតហើយ នេះជាសំឡេងរបស់បុត្រនាងភិក្ខុនីនោះ ។ ព្រះរាជាទ្រង់នាំយកកុមារនោះទៅឯព្រះរាជវាំងនៃព្រះអង្គ បានប្រទានឲ្យគីលៀងស្ត្រីអ្នកចិញ្ចឹមថែរក្សាទាំងឡាយ ។ គង់ថ្ងៃរកឈ្មោះឲ្យកុមារនោះ ជនទាំងពួងសន្មតឲ្យឈ្មោះកុមារថា កស្សប នាំគ្នាហៅថា កុមារកស្សប ព្រោះចម្រើនហើយដោយគ្រឿងបរិហាររបស់កុមារ ។ កុមារនោះ វាយក្មេងក្នុងធ្លាជាទីលេង, កាលក្មេងទាំងនោះនិយាយថា អញត្រូវក្មេងឥតមាតាបិតាវាយហើយ ។ កុមារឮពាក្យនេះក៏ចូលទៅគាល់ព្រះរាជាទូលសួរថា បពិត្រព្រះអង្គ ! ពួកក្មេង ៗ ថាខ្ញុំព្រះអង្គនោះ ជាមនុស្សឥតមាតាបិតា សូមព្រះអង្គត្រាស់ប្រាប់មាតាដល់ខ្ញុំ ។ ព្រះរាជា ចង្អុលស្ត្រីគីលៀងទាំងឡាយហើយត្រាស់ថា ស្រីទាំងនេះ ជាមាតារបស់ឯង ។ កុមារ ក្រាបទូលថា មាតារបស់ខ្ញុំមិនមែនច្រើនដល់ប៉ុណ្ណោះទេ មាតា របស់ខ្ញុំមានតែម្នាក់ប៉ុណ្ណោះ សូមព្រះអង្គ ត្រាស់ប្រាប់មាតានោះដល់ខ្ញុំ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញមិន

អាចបញ្ឆោតកុមារនេះបានទេ ទើបប្រាប់ថា នែកូន ! មាតារបស់ឯងជានាងភិក្ខុនី អញនាំយកឯងមកអំពីសំណាក់នាងភិក្ខុនី ។ កុមារនោះ មានសេចក្ដីសង្វេគស្លុតចិត្តកើតឡើងដោយហេតុត្រឹមតែប៉ុណ្ណោះ ក៏ក្រាបទូលថាបពិត្រព្រះបិតា ! សូមព្រះអង្គអនុញ្ញាតឲ្យខ្ញុំបួសផង ។ ព្រះរាជាទ្រង់ទទួលព្រមថា ល្អហើយកូន ! ហើយញុំាងកុមារនោះឲ្យបួសក្នុងសំណាក់របស់ព្រះសាស្ដា ដោយគ្រឿងសក្ការៈធំ ។

លោកបានឧបសម្បទ័ហើយ មានព្រះនាមជាប្រាកដថា ព្រះកុមារកស្សបត្ថេរ លោករៀនព្រះកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្ដាចប់ហើយ ចូលទៅគង់នៅក្នុងព្រៃ ខំព្យាយាមដូចម្ដេច ក៏មិនបានសម្រេចគុណវិសេសណាមួយសោះ គិតថា អញនឹងរៀនព្រះកម្មដ្ឋានថ្មីទៀតឲ្យវិសេស ហើយវិលមកគាល់ព្រះសាស្ដាវិញ នៅក្នុងព្រៃអន្ធវន ។ គ្រានោះ ភិក្ខុអ្នកធ្វើសមណធម៌ជាមួយគ្នា ក្នុងកាលរបស់ព្រះពុទ្ធព្រះនាមកស្សប បានសម្រេចអនាគាមិផល ទៅកើតក្នុងព្រហ្មលោក មកអំពីព្រហ្មលោកសួរប្រស្នា ៩១ ហើយបញ្ជូនទៅ ដោយពាក្យថា មនុស្សដទៃ លើកលែងតែព្រះសាស្ដាមួយព្រះអង្គចេញ ដែលអាចដើម្បីនឹងព្យាករប្រស្នាទាំងនេះគ្មានទេ, លោកចូលទៅរៀនសេចក្ដីរបស់ប្រស្នាទាំងនេះ ក្នុងសំណាក់របស់ព្រះសាស្ដាចុះ ។ លោកធ្វើតាមពាក្យនោះ ក៏បានសម្រេចព្រះអរហត្តផលក្នុងទីបំផុតវិស្សជ្ជនាប្រស្នា ។

ចាប់តាំងអំពីថ្ងៃព្រះថេរៈចេញទៅបាត់ហើយ ទឹកភ្នែកហូរចេញពីភ្នែករបស់នាងភិក្ខុនី ជាមាតាអស់ចំនួន ១២ ឆ្នាំ ។ នាងវេទនាព្រោះព្រាត់ប្រាសចាកបុត្រ មានមុខទទឹកជោក ដោយទឹកភ្នែក ត្រាច់ទៅដើម្បីភិក្ខា ស្រាប់តែក្រឡេកទៅឃើញព្រះថេរៈនៅកណ្តាលផ្លូវ ស្រែកហៅថា កូន! កូន! ស្ទុះចូលទៅប្រុះទឹងចាប់ព្រះថេរៈ ភ្ញាក់ដើងដួលស្រែកទឹកដោះទទឹកចីពរជោក ក្រោកឡើងចូលទៅចាប់ព្រះថេរៈ ។ គិតថា បើមាតា បានឮពាក្យផ្អែមល្ហែមពីពេះពីអញ មុខជានឹងវិនាសចាកមគ្គផល អាត្មាអញនឹងនិយាយជាមួយមាតានេះ ដោយសំដីរឹងរូសទ្រគោះ ទើបលោកនិយាយនឹងនាងភិក្ខុនីនោះថា លោកត្រាច់ទៅធ្វើអ្វី បានជាគ្រាន់តែសេចក្តីស្រឡាញ់ប៉ុណ្ណឹង ក៏កាត់មិនដាច់ដែរ ។ នាងភិក្ខុនីឮហើយគិតថា យីអើ! សំដីរបស់ព្រះថេរៈទ្រគោះណាស់ ទើបនិយាយថា នែកូន! កូនថាម៉េច? ។ ព្រះថេរៈថាដូចមុនទៀត ។ នាងគិតថា អញមិនអាចទប់ទឹកភ្នែកបានអស់កាល ១២ ឆ្នាំមកហើយ ព្រោះតែបុត្ររបស់អញនេះ ប៉ុន្តែ បុត្រអញនេះមានហឫទ័យរឹងរូស អញនឹងត្រូវការអ្វីដោយបុត្រនេះ, ក៏កាត់សេចក្តីស្រឡាញ់ចេញពីបុត្រដាច់ បានសម្រេចព្រះអរហត្តផលក្នុងថ្ងៃនោះឯង ។

សម័យក្រោយទៀត ភិក្ខុទាំងឡាយសន្ទនាគ្នា ក្នុងរោងធម៌ថា នែអាវុសោទាំងឡាយ! ព្រះទេវទត្តញ៉ាំងព្រះកុមារកស្សប និងព្រះថេរី អ្នកមានឧបនិស្ស័យបរិបូណ៌យ៉ាងនេះឲ្យវិនាសហើយ ចំណែកព្រះសាស្តាជា

ទីពឹងរបស់លោកទាំងពីររូបនោះ ធម្មតាព្រះពុទ្ធជាម្ចាស់ តែងអនុគ្រោះលោក ព្រះសាស្ដា ស្ដេចមកដល់ត្រាស់សួរថា ភិក្ខុទាំងឡាយ! ពេលនេះ ពួកអ្នកនិយាយគ្នាពីរឿងអ្វី ? កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបហើយត្រាស់ថា ភិក្ខុទាំងឡាយ! តថាគត ជាទីអាស្រ័យ ជាទីពំនាក់របស់ជនទាំងពីរនាក់នេះ មិនតែក្នុងកាលនោះទេ សូម្បីក្នុងកាលមុនក៏បានជាទីពឹងពំនាក់ របស់ជនទាំងនោះដូចគ្នាដែរ ហើយសំដែងនិគ្រោធជាតកនេះដោយពិស្ដារ សេចក្ដីសង្ខេបថា :

និគ្រោធមេវ សេវេយ្យ ន សាខមុបសំវសេ
និគ្រោធស្មិំ មតំ សេយ្យោ យញ្ចេ សាខស្មិំ ជីវិតន្តិ ។

ចៅប្ដុមនុស្សដទៃ គប្បីសេពគប់តែនឹងម្រឹគឈ្មោះ និគ្រោធម្នាក់ កុំសេពគប់នឹងម្រឹគឈ្មោះ សាខៈ ឡើយ ស្លាប់ក្នុងសំណាក់នៃម្រឹគឈ្មោះ និគ្រោធប្រសើរជាង រស់នៅក្នុងសំណាក់របស់ម្រឹគឈ្មោះ សាខៈ នឹងប្រសើរអ្វី ។

ទ្រង់ប្រជុំជាតកថា ម្រឹគឈ្មោះ សាខៈ ក្នុងគ្រានោះ បានមកជាទេវទត្តក្នុងគ្រានេះ ឯបរិស័ទរបស់ម្រឹគឈ្មោះ សាខៈ នោះ ក៏ជាបរិស័ទរបស់ទេវទត្តនុះឯង ចំណែកមេម្រឹគអ្នកដល់វារៈហើយ បានមកជានាងថេរី បុត្ររបស់មេម្រឹគនោះ បានមកជា កុមារកស្សប ឯស្ដេចម្រឹគឈ្មោះ និគ្រោធ អ្នកលះបង់ជីវិតដល់មេម្រឹគ ដែលមាន

គតិឲ្យរួចជីវិត ទៅហើយ គឺតថាគតនេះឯង កាលព្រះអង្គទ្រង់ប្រកាស សេចក្តីដែលព្រះ ថេរី កាត់សេចក្តីស្រឡាញ់អំពីបុត្រចេញបាន ហើយ ធ្វើទីពឹងដល់ខ្លួនដោយខ្លួនឯង ទើបទ្រង់ត្រាស់ថា ខែភិក្ខុទាំងឡាយ បុគ្គលអាស្រ័យមនុស្សដទៃ មិនអាចដើម្បីនឹងបានទៅស្ថានសួគ៌ ឬបាន សម្រេចមគ្គផលទេ ព្រោះហេតុនោះ ខ្លួនឯងហ្នឹងជាទីពឹងរបស់ខ្លួន អ្នក ដទៃនឹងធ្វើអ្វីបាន ហើយត្រាស់គាថាថា ៖

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។

ខ្លួនឯងហ្នឹងជាទីពឹងរបស់ខ្លួន បុគ្គលដទៃណាជាទីពឹងបាន ព្រោះ បុគ្គលមានខ្លួនទូន្មានល្អហើយ រមែងបានទីពឹងដែលបុគ្គលបានដោយក្រ ។

កាលចប់ធម្មទេសនា មនុស្សជាច្រើនបានសម្រេចមគ្គផល មាន សោតាបត្តិផលជាដើម ។

( រឿងមាតាព្រះកុមារកស្សបត្ថេរ ចប់ )

យើងត្រូវលះបង់ សុខតូចពោល
ដើម្បីយកសុខធំវិញទើបប្រសើរ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាន់-ខាត់ រៀបរៀង*

---

អបាណ្ឌុរ គុ. ដែលមិនមែនជាបាណ្ឌុរ ។

អបាតក នបុំ. អបាតក, កិរិយាមិនមានទោសឧក្រិដ្ឋ ។

អបាត្រ នបុំ. អបាត្រ, ជនមិនគួរទទួលទាន ។ –ក្រិត្យា ស្ត្រី. អបាត្រក្រិត្យា អំពើដែលធ្វើមិនឲ្យសមនឹងទទួលទាន ។ –វស៌ណ នបុំ. កិរិយាឲ្យដល់ជនអបាត្រ ។ –វស៌ិន គុ. ដែលឲ្យទានដល់ជនអបាត្រ ។ –អបាត្រករណ គុ. ដែលធ្វើមិនឲ្យសមទទួលទាន ។

អបាទាន នបុំ. អបាទាន, កិរិយាចៀសចេញ ។

អបាន៑ អន: ធាតុ ដកដង្ហើមចេញ ។

អបាន បុំ. ដង្ហើមចេញចូល ។ វច្ចមគ្គ ។ –អបា-នោទ្គារ បុំ. ផោម (F. Pet) ។

អបាទីយ	គុ.	ដែលមិនមានទឹកដីក ។

អបាទុខ	ពាគុ	វែក ញែក ចៀសវាង ។

អបាទ្ធត	គុ.	ដែលប្រាសចាកសេចក្ដីពិត, ពិត ។

អបាទ្ធវិតមស	ចុំ.	តាមឫស្សី ។

អបាប	គុ.	ដែលមិនមានបាប បរិសុទ្ធ ស្អាត ល្អ ។

បេតស គុ. ដែលមានចិត្តល្អ ។ – ទស្សិន

គុ. ដែលឃើញជាល្អ ។

អបាយ	ចុំ.	អបាយ, សេចក្ដីវិនាស ។

អបាយិន	គុ.	ដែលចេញទៅ, ដែលស្លាប់ ។

អបារ	គុ.	ដែលមិនមានត្រើយ ដែលនៅកណ្ដាលស-

មុទ្រ ។ ចុំ. អបារ ត្រើយជិត ។

អបារណីយ	គុ.	ដែលមិនអាចរំលងបាន ដែលមិនអាចដល់-

ត្រើយបាន ។

អបាថិ	គុ.	ដែលមិនមានសេចក្ដី ។ –ក គុ. ដែល

ឥតប្រយោជន៍ ។

អបាថិវ គុ. ដែលមិនមែនជាដី ។

អបាល គុ. អបាល ដែលមិនមានអ្នករក្សា ។

អបាវុ ធាតុ. បើក រកឃើញ ។ —វុត គុ. ដែលបើក ដែលរួច ដែលបើកបង្ហាញ ។

អបាវុត គុ ដែលមិនឃាត់ទុក, ដែលមិនទើស ។

អបវុត ធាតុ. ប្រឡប់ ។ —វុត្ត គុ ដែលត្រឡប់ ។ វុត្តក គុ ដែលរត់បាត់ ។

អបាស្រយ បុំ. អបាស្រ័យ ក្បាលព្រៃ ពំនឹង ទីជម្រក ការ-យារូច ។ របងព័ទ្ធព្យារ ។ ក្លាល ។ — ស្រយិន ឬ ស្រយវន្ត គុ. ដែលមានទីបង្អែក ។

អបាស្រិ ធាតុ ពឹង ស្វែងរកទីពឹង ។ —ស្រិត គុ ដែលពឹង ដែលរកទីពឹង ។

អបាបណ្ណ គុ. អបាសណ្ណ អឥន្ទ្រិយ ដែលមានសេចក្ដីយល់ផ្សេង ។

អបៀស: អស: ធាតុ. បោសបោលទៅឆ្ងាយ អបាស្ស ដោយប្រ-
ហែស ដោយលើកលែង ។

អបិ និបាត ដែរ ប៉ុន្តែ តែប៉ុណ្ណោះ ។ កោ បិ
អកណាមួយ កុត្រាបិ នៅក្នុងទីណា ។

អបិគម ធាតុ ចលរូម ។

អបិគុណ គុ. ប្រសើរ ដ៏វិសេស ។

អបិគ្រហ ធាតុ បិទទ្វារ បិទគ្រពៀក ។

អបិត្រ្យ គុ. ដែលមិនស៊ីខ្សែពីបិតា ។

អបិធា ធាតុ បិទ គ្រប ពាក់ ។

អបិធាន នបុំ. ភួយ ស្រោម នប ។ គម្រប របង រនុកទ្វារ ។

អបិធាន គុ. ដែលមិនមានស្រោម ទទេ អាក្រាត ។

អបិនហ៍ ធាតុ ចង ចុក ។

អបិបាស គុ. ដែលមិនមានសេចក្ដីប្រាថ្នា ដែលមិនស្រេក
ឃ្លាន ។

អបិប្បលាទ គុ. ដែលមិនស៊ីផ្លែល្វា ដែលមិនរីករាយនឹងកាម។

អបិពទ្ធ គុ. ដែលចង ។

## ល្បងសិក្សា

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

ដោយ លាង ហាប់អាន

សាស្ត្រាចារ្យ–នាយកពុទ្ធសាសនបណ្ឌិត្យ

(ស្រង់ពីមេរៀនវិជ្ជាឋានអប់រំខាងអក្សរសាស្ត្រ)

## អក្សរសាស្ត្រខ្មែរ

## ពីសម័យបុរាណ មកសម័យបច្ចុប្បន្ន

[ត]

កាលបរិច្ឆេទនៃការតែង និងឈ្មោះអ្នកបញ្ជាឲ្យតែង ។

២– តួសេចក្ដី : ដែលរៀបរាប់អំពីគោលបំណង (គឺអត្ថន័យនៃអត្ថបទ) របស់អ្នកបញ្ជា ។ ក្នុងតួសេចក្ដីនេះ មានបញ្ជាក់អំពីទឹកព្រះទ័យព្រះមហាក្សត្រដែលទ្រង់ជាប់ជំពាក់ព្រះហឫទ័យទៅលើពុទ្ធសាសនា ទៅលើការកសាងសមិទ្ធិនានាដើម្បីជាប្រយោជន៍ដល់ត្រៃសរណគមន៍ ហើយនិងព្រហ្មវិហារធម៌ចំពោះសព្វសត្វ ពោលគឺអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ ។

៣_សេចក្ដីបញ្ចប់ : ដែលជាយោបល់នៃអត្ថបទ មានបែបជាដំបូន្មានណែនាំប្រជានុរាស្ត្រឲ្យតាំងនៅក្នុងសច្ចៈ សុចរិត យុត្តិធម៌ ឲ្យប្រកាន់ខ្ជាប់

នូវធម៌សន្តោស មានមេត្តាករុណាជាអាទិ ។

សិលាចារឹកខ្លះ (ឧទាហរណ៍ សិលាចារឹកប្រាសាទតាព្រហ្ម : បានបញ្ជាក់ដោយបញ្ញា គឺ "ព្រះមហាក្សត្រ") សូមអធិដ្ឋានអានិសង្សកើតមកពីបុណ្យ និងការកសាងនានាដើម្បីសំរេចប្រយោជន៍ទៅបរលោកនាយ ដូចជាសុំតាំងខ្លួនជាឧបាសកសុំឲ្យប្រាសចាកបាបកម្មនានា ហើយបានសំរេចមគ្គផលដល់ត្រើយព្រះនិព្វានជាដើម ។

សារុបសេចក្ដីទៅ ឃ្លាប្រយោគនៃអត្ថបទសិលាចារឹកច្រើនកាត់ៗមិនអស់សេចក្ដីទេ (អន្ទើខ្លះរលប់បាត់ដោយមកពីការចាស់ជកនៃសិលា)ហើយរបៀបយល់នូវគំនិតត្រូវតែពិនិត្យមើលឯកសារខាងប្រវត្តិវិជ្ជានានា ដើម្បីប្រៀបធៀបនូវនាំតាមព្រះមហាក្សត្រ និងសម័យកាលពិតប្រាកដផង ។

## ៣- អំពីអត្ថរសនៃអត្ថបទសិលាចារឹក

តម្លៃជាមូលដ្ឋាននៃអត្ថបទសិលាចារឹក គឺបិតនៅលើ សង្គមរស = Le social ពីព្រោះតាំងអ្នកកត់ត្រាក្ដី គឺយោលទៅលើហេតុការណ៍ច្បាស់លាស់ នៃការរស់នៅ (ពប់តាំងពីទឹកចិត្ត ជំនឿនៃការកសាងនានាសមិទ្ធិដែលកើតមាន) ឬវិបត្តិនានា ដែលមនុស្សជាតិក្នុងសម័យកាលនោះបានជួបប្រទះ ។

គឺដោយសារសង្គមរសនេះទៀត ដែលអ្នកសិក្សាប្រវត្តិវិជ្ជាអាចយក

សិលាចារឹក យកធ្វើជាសេចក្ដី ប្រមាណសិក្សាក្នុងការស្រាវជ្រាវ ពិនិត្យវិនិច្ឆ័យអំពីជីវភាព ការរស់នៅរបស់ខ្មែរក្នុងសម័យកាលនោះៗដែលកន្លងទៅហើយ ។

## ៤– យោបល់រួម

ដូច្នេះយើងឃើញថា សិលាចារឹកជាអត្ថបទអក្សរសាស្ត្រដ៏ចំណាស់មួយ ហើយមានប្រយោជន៍សំខាន់ដែលធ្វើឲ្យអនុជន (អ្នកប្រវត្តិវិជ្ជា-អ្នកសិក្សាស្រាវជ្រាវ) បានយល់ បានដឹងនូវកម្រិតសមត្ថភាពនៃវប្បធម៌អរិយធម៌ខ្មែរ ដែលប្រជាជនខ្មែរបានរក្សា ទ្រទ្រង់ ពង្រីកឲ្យលូតលាស់តាំងពីបុរាណកាលមកម៉្លេះ ។

## ទី ២– សម័យកាលទី ២

## សម័យមុនអង្គរ គ.ស. ៥៥០-៨០២

### ១– ក្សត្រសំខាន់ៗក្នុងសម័យកាលទី ២ (១)

(១) ឯកសារខ្លះសំរាប់សិក្សាសម័យកាលនេះគឺ :

— P. Pelliot : Le Founan; — L. Finot. BEFEO, XXVIII, P. 44 ;

— G. Cœdès, les Etats hindouïsés P. 130; — G. Cœdè·, Inscriptions du Csmbodge, Vol. V. P. 23;

— A. Barth, Inscription dn Cambodge, P. 60; — G. Cœdès Histoire ancienne des Etats hindouïsés d'Extrême-Orient, P. 90 .

សម័យកាលទី ២ នេះ អាចហៅបាន ២ យ៉ាងទៀតគឺ :

- សម័យមុនអង្គរ ឬ សម័យចេនឡាក៏បាន

ឯព្រះមហាក្សត្រ ដ៏ល្បីខ្លះក្នុងសម័យកាលទី ២ នេះ គឺមាន :

- ព្រះបាទភវវរ្ម័ន ទី ១ (គ.ស. ៥៥០-៦០០)

- ព្រះបាទមហេន្ទ្រវរ្ម័ន ចិត្រសេនា (គ.ស. ៦០០-៦១៥)

- ឥសានវរ្ម័ន ទី ១ (គ.ស. ៦១៥-៦៣៥)

- ភវវរ្ម័ន ទី ២ (គ.ស. ៦៣៩-៦៥៥)

- ជ័យវរ្ម័ន ទី ១ (គ.ស. ៦៥៥-៦៨១) ។

## ២- សាសនាក្នុងសម័យកាលទី ២

ក្នុងសម័យកាលនេះ ពុទ្ធសាសនាថេរវាទចំរើនរុងរឿងនៅឡើយទេ ។ នៅខាងដើមពុទ្ធសតវត្សទី ១២ (គ្រិស្តសតវត្សទី ៧) ពុទ្ធសាសនាលទ្ធិមហាយានបានចូលមកក្នុងប្រទេសកម្ពុជាយើងជាមុនដំបូង ។

## ៣- អក្សរសាស្ត្រក្នុងសម័យកាលទី ២

ក្នុងសម័យកាលនេះ អត្ថបទនៃអក្សរសាស្ត្រ ឋិតនៅក្នុងផែនសិលាដដែល គឺសិលាចារឹកនេះឯង ។

សិលាចារឹកសំខាន់ៗ មាន ៤ កន្លែង គឺ :

ទី ១– សិលាចារឹកនៅសម្បូណ៌ព្រៃគុក (ក្នុងដែនឥសានបុរៈ) ខេត្តកំពង់ធំ សរសេរក្នុង ព.ស. ១១៦៩ (គ.ស. ៦២៦) ក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័ន ទី ១ (១) ។

ទី ២.– សិលាចារឹកនៅភូមិ ទាវកំង ជិតអរញ្ញប្រទេស (ដីខ្មែរពីដើម ប្រទេសសៀមឥឡូវនេះ) ក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី ២ ព.ស. ១១៨២ (គ.ស. ៦៣៩) (២) ។

ទី ៣.– សិលាចារឹក ក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័ន ទី ១ (គ.ស. ៦៥៧-៦៨១) ដែលមានពីរ គឺ :

ក– សិលាចារឹកនៅវត្តព្រៃវៀរ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង (ពីដើមហៅថា ខេត្តបាភ្នំ) ក្នុង ព.ស. ១២០៦ (គ.ស. ៦៦៤) (៣) ។

ខ– សិលាចារឹកនៅវត្តប្រាសាទ ក្នុងស្រុកកំពង់ត្របែក ។ ខេត្តព្រៃវែង ។ លោក Aymonier បញ្ជាក់ថា សិលាចារឹកនេះ សរសេរក្នុងគ្រិស្តសតវត្សរ៍ទី ៦ ឬទី ៧ ហើយសរសេរជាភាសាខ្មែរ ។

---

(១) មើល L. Finot, BEFEO, XXVIII, p. 44.. ;

(២) មើល G. Cœdès, Inscription du Cambodge Vol. V, p. 23.

(៣) មើល A. Barth, Inscription du Cambodge, p. 60...,

(សូមមើលពុទ្ធសាសនា ២៥០០ អត្ថបទព្រះតេជព្រះគុណ ជាំង-ទាត់ ពីទំព័រ ៥៣ ដល់ ៦២)

ទី៤.- សិលាចារឹកនៅប្រាសាទ តាតាំ ក្នុងខេត្តសៀមរាប ព.ស. ១៣៣៤ (គ.ស. ៧៩១) (១) ។

## ៤– លក្ខណៈសិលាចារឹកក្នុងសម័យកាលទី ២

### ទី ១ – សិលាចារឹកនៅសម្បូណ៌ព្រៃគុក

**ក– អត្ថបទ** (អត្ថបទនៅទំព័រ ៤០)

ទី ១.- *អត្ថបទមួយ នៅមេបញ្ជរនៃទ្វារ ទិសខាងត្បូង* ( *ហៅ* Piédroit sud )

*១...រ ជយតិ ស ស្រីប្រហសិ តេ ស្វរ៌ស យស្យាង្គ ភាសា*

*មគនេវ ទ្រុតហេមាម្វុជា មហី ។*

*២– ស្រីមត៌អវិនីទ្រោណាំ អន្វយាម្វុកាស្វត៌ស មណ្ឌលេ មធ្យម*

*ស្យាបិ ប្រគាថា យស្យ ទុស្យហ័ស ។*

*៣– យ័ម កាន្ត វបុស័ម ទ្រស្តា វិស្មិតេ ភកវទតិស័ អហោ*

*នុ មិថ្យា វៃនវ្យ វញ្ចិតាស្មិ បិភទ ឥតិ ។*

*៤– ស្រីត រុណ្យាបវិស្វក័ត កាម្យវូថា យុភ បិយ័យ កុក្តាសុ*

---

(១) សេចក្តីបញ្ជាក់ថា សិលាចារឹកមាន ៤ កន្លែងសំខាន់នេះ មិនមែនបានសេចក្តីថា មានសិលាចារឹកតែ ៤ ប៉ុណ្ណោះទេ ។ ក្នុងសម័យនោះ មានសិលាចារឹកច្រើនជាងនេះទៅទៀត ដែលខ្ញុំមិនអាចនាំយកមករៀបរាប់ទេ ។ ខ្ញុំនឹងធ្វើកយឈ្មោះបញ្ជីសិលាចារឹកតាំងពីដើមមក កាលណាចប់មេរៀនទាំងអស់ ស្តីពីសិលាចារឹកនេះ ។

វិទ្វទ្វិទ្យាសុ រក្ត បរិណតាស្វ អបិ ។

៥- ស្វយាំ.. ន. មយិតា បយ័ស កក្តៃត្រល យុ... ស្វរិកិស័ ។

៦- វេត្ថរ ឧទន្វាន ឥវយ បរិបូរណាប្យ អនុន្ថតិស័ ឋាតា...រ

...ឥបក្សានត្រ្តា អបិ មហិក្ស តំ ។

៧- បរេសំ វត្តតារេសុ យស្យ ណិកោ នពស្យទស័ ស្ថិត

កេវលម អាចារ សុក្សតា តក្តីតិសុ ។ (១)

ទី ២.– អត្ថបទមួយ នៅមេបញ្ឈរនៃទ្វារ ទិសខាងជើង ( ហៅ Piédroit nord )

១៨... មា វិបុស្កាន្តិ...

១៩... ប្រក្ស តិប្រត្យាយាទេស គុណាវិទ្យាគមាទ្វិតាស័ សុទិតិ

ស សត្វ វិទ្យា ច បទ...យស្យ... ។

២០.. យ. .យោ...យ ទ្យុតា ស្វវិញ ជិគីសុណាយេន ទ្វិះ

ជិតស័ សក្រវារណ៍ស(២) . . . . .

## ខ- សេចក្តីប្រែ

ទី ១.– ជ័យជំនះ មានដល់ព្រះស្រីប្រហសិតេស្វរដែលមានព្រះកាយគឺ

គឺព្រះធរណី ដែលឋិតនៅក្នុងសាគរទឹកមាស ។

(១) អត្ថបទនេះនៅក្នុង ( Inscriptiou du Cambodge ) របស់ G. Cœdès T. 4 page 7 មានដល់ទៅ ១៣ វគ្គ ស្រង់សំរួលមកបង្ហាញជាគាង ។

(២) T. 4 page 8 មានដល់ទៅ ១៣ វគ្គដែរ គឺពីវគ្គទី ១៨ ដល់ ៣៤ ។

អំពីព្រះរាជា ដែលជាព្រះអាទិត្យនៃវេហាស៍នេះ គឺព្រះវង្សនៃមហាក្សត្រ ជាទីគោរពលើកពផែនដីចេញមកអំពីចំហាយដែលពុំអាចអត់ទុនបាន ទោះបី ព្រះអង្គសណ្ឋិតនៅឰដ៏កណ្តាលរដ្ឋតាំងឡាយរបស់ទ្រង់ក្តី ។

– ដោយយល់ឃើញនូវព្រះកាយ យ៉ាងល្អស្រស់ ព្រះរតិភ្ញាក់ស្មារតី ហើយបន្ទឹថា " ពិតណាស់ខ្ញុំយល់ខុសសោះ ជាអំពីកាលមុន ខ្ញុំស្មានថាខ្លួន មេម៉ាយសោះ" ។

– ពិតមែនតែទ្រង់នៅក្មេង ប្រកបដោយព្រះចំណង់ តែសោ-ភណភាពនៃយុវវ័យ មិនអាចផ្តិមនឹងព្រះអង្គបានឡើយ ។ ព្រះអង្គសព្វព្រះទ័យតែនូវវិទ្យាសាស្ត្រជ្រៅជ្រះ ហើយដែលមានតែប៉ុណ្ណោះទើបយល់បាន ។

. . . . . . . . . .

– ពិតមែនតែទ្រង់ប្រកបដោយអលង្ការ ដូចជាទំហំនៃសាគរ.. ព្រះកដិ ទោះបីរបស់ព្រះរាជានៃបពិតកំបរិបូណ៌ ដូច្នោះដែរ ។

– ព្រះរូបឆោមព្រះអង្គ ពុំមានស្ត្រីឯណាមួយ ឬមនុស្សផ្សេងៗ ប្រៀបប្រដូចបានឡើយ ។ ព្រះរូបនេះមានពិសេសតែចំពោះទ្រង់ គឺចំពោះព្រះអាកប្បកិរិយា ព្រះសកម្មភាពដ៏ល្អ... និងព្រះចេស្តាព្រះអង្គ ។

ទី ២.–

– លំអរបស់ទ្រង់រកអ្វីផ្ទឹមគ្មានទេ

– បរិបូណ៌ទៅដោយចំណេះវិជ្ជា សម្រាប់គ្រប់គ្រងវដ្តពេញពោរ ទៅដោយការពិសោធន៍ ការប្រុងប្រយ័ត្ន មានគុណធម៌ បូរណ-ភាព ចំណេះវិជ្ជាបូរមបូរាណ និងវៃឆ្លាតខាងនយោបាយ និងវេយ្យាករណ៍ ។ . . . . . .

– . . . ព្រះរាជាអង្គនេះ សម្បូរមទឹងទទួលនូវឋានសួគ៌ ទ្រង់បានឈ្នះដំរីញាក់ណរបស់ព្រះឥន្ទ្រ ។ (១)

## គ– អត្ថបទដទៃទៀត

ក្រៅពីសិលាចារឹកនៅនាមេទ្វារបញ្ឈរទាំងពីរ ទិសខាងត្បូង និងខាងជើងនេះ នៅមានសិលាចារឹក ៤ ទៀតនៅនាកម្រាលមណ្ឌប= dalle du mandapa នៃប្រាសាទហោត្រៃខាងត្បូង នៃទ្វារចូលខាងលិចបិតនៅក្នុងកំពែងក្រៅផ្នែកខាងត្បូងដែលសរសេរជាភាសាសំស្ក្រឹតដែរនៅមេបញ្ឈរខាងត្បូងនៃប្រាសាទមុខ (la tour F) ដែលសរសើរអំពីព្រះបាទ-មីព្រះបាទឥសានវរ្ម័ន តាប់ពីវគ្គទី២ ដល់ទី៦, សិលាចារឹកផ្សេងៗ នៅក្នុងពួក S. ; នៅមេបញ្ឈរខាងត្បូង នៃទ្វារខាងកើត ក្នុងកំពែងខាងក្រៅផ្នែកខាងជើង ដែលសរសើរបារមីព្រះឥស្វរ ព្រះនីលកណ្ឋ, ព្រះវិណ្ណុបង្គំជនាក

(១) សេចក្តីប្រែនេះមានវែងទាំង ៣៤ វគ្គនៃមេទ្វារខាងត្បូងនិងខាងជើង ។

និងព្រះព្រហ្ម ហើយទឹងសរសើរអំពីព្រះបាទពជេន្រ្ទវរ្ម័ន ចាប់ពីវគ្គទី ១៥ ដល់ទី ១៣, នៅមេបញ្ជរនៃប្រាសាទខាងជើង គេសរសេរដោយអក្សរក្នុងសតវត្សទី ៧ ជាភាសាសំស្រ្កឹតនិយាយពីព្រះបារមីរបស់ព្រះបាទឥសានវរ្ម័នទី ១ ប្រកបដោយព្រះបរមនាមថា សាការមញ្ជារី, នៅមេបញ្ជរនៃបន្ទប់ខាងត្បូងនៃប្រាសាទខាងជើង សរសេរជាភាសាខ្មែរ សរសើរអំពីតេជៈរបស់ព្រះបាទកវវរ្ម័នទី ១, ព្រះបាទមហេន្រ្ទវរ្ម័ន និងព្រះបាទឥសានវរ្ម័នដែលទ្រង់បូជាទាសៈ បំពោះព្រះអាទិទេពគម្ភីរស្វរៈ ដោយព្រះអាចារ្យមានគោរម្យងារជា ព្រះកម្រតាញ, នៅមេបញ្ជរនៃប្រាសាទខាងជើងដែលនិយាយអំពីរជ្ជកាលព្រះបាទកវវរ្ម័នទី ២, នៅមេបញ្ជរនៃផ្នែកខាងត្បូងប្រាសាទខាងជើងជាដើម ។

## ឃ- អត្ថន័យទូទៅ

បើពិនិត្យមើលន័យសេចក្ដីនៃសិលាចារឹកទាំងឡាយ នៅសម្បូណ៌ព្រៃគុកនេះ យើងអាចយល់បានថា ក្នុងសម័យសតវត្សទី ៧ នៃគ្រិស្តសករាជជំនឿរបស់ខេមរជន គឺមានចំពោះព្រះសិវៈ (ឥស្វរព្រះវិស្ណុ ព្រះព្រហ្មជាដើម) ។ ឯព្រះពុទ្ធសាសនាក្នុងសម័យនោះ ក៏មានឥទ្ធិពលណាស់ដែរ ។ គេគោរពនាគរាជមុចលិន្ទដែលគ្របដណ្ដប់ជាមួយចំពោះព្រះពុទ្ធ ។ គេនិយាយពីព្រាហ្មណ៍រាជបុរោហិតឈ្មោះ បសុបតិ= pasupati មានងារជា

វិទ្យាវិសេស: ជាអ្នកប្រាជ្ញចេះដឹងវិជ្ជាជ្រៅជ្រះ ចេះអច្ឆ័ន គឺវិជ្ជាសាស្ត្រខាងក្បួនវេយ្យាករណ៍ ចេះវិជ្ជាខាងវៃសេសិក: ន្យាយ: សមីក្ស ឬសំខ្យាក្នុងព្រហ្មញ្ញទ្រឹស្តី ព្រមទាំងវិជ្ជាក្នុងពុទ្ធសាសនាថែមទៀត ។

ដទៃពីការបញ្ជាក់នូវជំនឿ សិលាចារឹកបានរំលឹកអំពីរូបសម្ផស្សសោភណភាពខាងកងកាយរបស់ព្រះរាជា ព្រមទាំងតេជ:បារមី និងព្រះជំនឿរបស់ព្រះបាទភវវរ្ម័ន ឥសានវរ្ម័ន មហេន្ទ្រវរ្ម័ន ដែលបានឲ្យកសាងរាជនិវេសនស្ថាន សក្ការបាន មានរូបសំណាក ទេវ: ពុទ្ធរូបសម្រាប់បូជាជាដើម ។

ក្នុងសម័យកាលនោះ មនុស្សមានចំណេះចេះដឹងខាងវិជ្ជាផ្លូវលោក និងផ្លូវធមច្បាស់លាស់ណាស់ ។ ការរស់នៅប្រកបដោយរបៀបរបបមានសម្ភារ:ប្រើប្រាស់បរិបូណ៌ ដោយសារមានឃើញការរៀបរាប់អំពីគង្វាយផ្សេង ៗ របស់ព្រះមហាក្សត្រចំពោះទេវរូបឬពុទ្ធរូប មានទាំងសត្វពាហន:ផង ដូចជាគោក្របីជាដើម ។

## ៦- យោបល់រួម

ដូចសេចក្ដីរៀបរាប់មកហើយខាងលើ សិលាចារឹកនៅសម្បូណ៌ព្រៃគុក ( គ.ស. ៦២៦ ) មានចំនួនដល់ទៅ ១៧ គឺ៖

ផ្នែកកណ្ដាល ហៅ groupe central ( C ) រកមិនទាន់ឃើញ,

(នៅមានត)

# រឿង ចៅកែវគលលភ

សហ. ព្រួច - ភុម

រៀបរៀងតាមការនិទានត ៗ មក

[ក]

— ខ្មោច មានម្រាមដៃមិនគ្រប់ ១០ ទេ, ចូរមើលម្រាមដៃខ្ញុំ ។

ភ្នែកខ្មោច គ្មានប្រស្រីខ្មៅទេ មានតែប្រស្រីសព្រាតទាំងអស់ ។

— ខ្មោច តែកាលណាហាមាត់និយាយ មានពន្លឺក្នុងមាត់ ។

— ខ្មោច ដើរទៅណាមកពីណា គ្មានស្រមោលចោលចេញពីខ្លួន មិនប្រាកដ ទឹងស្មានថាជាអ្វីក៏មិនត្រូវដែរ ។

- ខ្មោច បើចង់ឲ្យឃើញក៏ឃើញ បើចង់ឲ្យបាត់ក៏បាត់ភ្លាម ហើយអាចកាឡាខ្លួនជាអ្វី ៗ បាន តាមសេចក្ដីត្រូវការ ។

- ខ្មោច មិនប្រាកដពីត្រឹមក្បាលជង្គង់ចុះទៅក្រោម, ប្រាកដបានខ្លះតែពីត្រឹមលើជង្គង់ឡើងទៅលើ, មើលទៅហាក់ដូចជាខ្មោចដើរទីងៈដីង ប៉ុន្តែជើងខ្មោចមិនជិតជាប់ដល់ដី ដូចជាមនុស្សនោះទេ ។

— ខ្មោច មានរូបមិនប្រាកដ ចាប់ពាល់មិនត្រូវ ដូចជាគេចាប់ស្រមោល ។

— ខ្មោច មានរិទ្ធិខ្លាំងពូកែណាស់, ប៉ុន្តែខ្មោចនៅឆោតម្ដុំ ៗ អាចឲ្យមនុស្សបញ្ឆោតបានងាយ ៗ, តែថា រឿងឆោតនេះ ខ្ញុំឈ្មោះតូច

មិនជាគោតផ្ដេសផ្ដាស ដូចអស់ទាំងខ្មោចគេទេ ព្រោះខ្ញុំចេះដឹងច្រើន ។

ក្លាយនោះ មាណពឲ្យខ្មោចតូចសម្ដែងរិទ្ធិលមើល, តូចចាប់សម្ដែងរិទ្ធិកាឡាជាសត្វផ្សេងៗ ជាមនុស្ស ជាអ្វីៗ ជាច្រើនបែបប្លែកៗ, ជាដើម ខ្មោចតូច កំពុងឈរនិយាយ ស្រាប់តែបាត់, លេចឯដុំថ្ម ១ ដុំ រមៀល ត្រឡប់តុបមកឈប់ស្ងៀម ចេញផ្សែងផ្សាង ចេញជាដុំភ្លើងប៉ុនផ្លែដៃ ហើយរ៉ា ឈាន់សម្ដេងកុំ ទៅធ្លាក់នៅជ្រុងចំការខាងកើត ផ្សែងនោះហុយ ទ្រូបកំពស់ចុងត្នោតលៃ លេចមនុស្សម្នាក់កំពស់ដុំផ្សែង ខ្មៅកក្វាក់ ខ្លួនធំស្តឹង ដៃជើងមាំៗ ធ្មេញប៉ុនៗចបកាប់ បបូរមាត់ស្តែកំបើញៗ ស្មេញ ក្រាប់ភ្នែកលៀនត្រលសព្រាតប៉ុនៗគង សក់ក្រញាញ់ដូចឫស ឬស្សី ស្បែកកំពកកំពួ ដើរគឃ្លើនគឃ្លាក់ចូលមក, មាណពគិតដាក់មេ-ដាយកយកែងជូនខ្មោចតូច តែខ្មោចឃាត់ទាន់ថា "កុំខ្លាចៗ" រួចហើយ កាឡាបជ្រមធ្វើខ្លួនឲ្យល្អជាឡើងវិញ ដើរចូលមក ល្មមឲ្យស្គាល់ថាខ្មោច តូចបាន ហើយនិយាយថា "ឃើញទេ! អម្បាញ់មិញ? ហ្នឹងហើយ ដែលហៅថា ខ្មោច" រួចក៏ចាប់បង្ហាញល្បិចកិច្ចការខ្លះៗទៀត ឲ្យមាណព ចេះដឹង មានប្រាប់ឲ្យសំគាល់អ្វីផ្សេងៗ និងឧបកិច្ចជាដើមថា :

– សំគាល់ព្រះឥន្ទទេព្ដា : ព្រះឥន្ទទេព្ដា បើធ្វើការ មិន ចេះបែកញើស មិនចេះហត់អស់កម្លាំង ឥតចេះតក់ស្លុតខ្លាចខ្លាច ឥត ប៉ប្រិចភ្នែក និង ឥតមានស្រមោល ។

- សំគាល់យក្ស : យក្សមិនប៉ប្រិចភ្នែក មានភ្នែកក្រហមដូចភ្លើង គ្មានប្រស្រីភ្នែក ឥតបែកញើសខ្លួន គ្មានស្រមោល និង មិនចេះអាណិតអាសូរអ្នកណា ។

- សំគាល់ក្បាលខ្មោចមនុស្ស : ថ្ងៃលលាដ៍ក្បាលខ្មោចមនុស្សប្រុសត្រង់ៗ ថ្ងៃលលាដ៍ក្បាលខ្មោចមនុស្សស្រីវៀចវេរវិលក្រវិចក្រវក់ ។

- សំគាល់ពស់ញីឈ្មោល : ពស់ឈ្មោល មានចុងកន្ទុយពងវេល ក្បាលក្រាស់ក្រមឹប ភ្នែកធំៗសង្ហារធ្មេញអន្ទាយ ។ ពស់ញី កន្ទុយឆ្មារវៀវ ក្បាលស្តើងកន្ទ្រឹម ភ្នែកតូចៗ សង្ហារធ្មេញកំបុត ។

- បើស្រីពីរនាក់ដណ្តើមក្មេងគ្នា : ចង់ដឹងថា ណាម៉ែមែន ណាមិនមែន ឲ្យគូសរង្វង់មូលមួយ យកកូនដាក់កណ្តាល ឲ្យដណ្តើមគ្នា ដោយកុំឲ្យដឹងខ្លួន, ប្រាប់ថា អ្នកណាឈ្នះបានកូន គឺជាកូនអ្នកនោះ, ប៉ុន្តែអ្នកឈ្នះនោះមិនមែនម៉ែពិតទេ ព្រោះគ្មានមេត្តាដូចម៉ែពិត ពឹតតែដណ្តើមយកឈ្នះដៃ ។

- ឧបក្រិច្ចផ្សេងៗ : បើក្អែក ខ្លែង ប្រមង់ ឆាបឆក់អ្វីៗយើង ហើយចង់បានវិញ ត្រូវតាំងចិត្តថា នឹងយកវិញឲ្យបាន កុំងើបមើលលើឲ្យសោះ មើលតែស្រមោលវា ស្ទុះឲ្យលឿនទៅជាន់ស្រមោលវា ទះដៃឲ្យខ្លាំងៗ វានឹងទម្លាក់ឲ្យវិញហើយ ។

– ឧបករិក្ខបណ្ដេញខ្មោច : បើខ្មោចចូល ត្រូវល្បួងបញ្ឆោតពីនេះពីនោះ បន្លាចនឹងរបស់ណាដែលវាខ្លាច ពន្យុយចុះឡើង វានឹងខ្លាចចេញរត់ទៅបាត់ហើយ ។

– តម្រាដើរព្រៃ : បើដើរព្រៃទៅហើយវង្វេងរកទិសមិនឃើញអស់ពេញមួយថ្ងៃ ពួកមនុស្សនិងខ្មោចពីបុរាណធ្លាប់និយមសំគាល់មក គឺនៅពេលយប់នោះ ត្រូវស្ទាបគល់ឈើមើល បើខាងណាក្ដៅខ្លាំងជាង គឺខាងនោះហើយជាទិសខាងលិច ។ បើស្ទាបឈើទៅហើយមិនដឹងត្រជាក់ក្ដៅទេ ឲ្យរកមើលវល្លិ៍ព័ន្ធ, វល្លិ៍តែងព័ន្ធតែទៅខាងស្ដាំ ចុងត្រួយវល្លិ៍តែងវិលមួយជុំមកនៅទិសខាងកើតជានិច្ច, ខ្មោច ដើររកស៊ីមិនចេះវង្វេងទេ ព្រោះបានតម្រានេះគ្រាន់នឹងចំណាំ ។

លុះខ្មោចតូច ប្រាប់ដូច្នោះជាដើមរួចហើយ ក៏និយាយថា ខ្មោចមិនចេះធ្វើផ្ទះនៅទេ អាស្រ័យនៅតែនឹងទីផ្សេង ៗ ដូចជាព្រៃព្រឹក្សាដំបូកជាដើម, ដូច្នេះ នៅពេលព្រឹកនេះ ចូរអ្នកដើរតាមសរសៃអម្បោះដែលហៅថា អម្បោះខ្មោច ដែលយើងបង្ហុតទុកឲ្យឯងដើរទៅ, បើដើរទៅផុតត្រឹមណា ត្រង់នោះជាទីផ្ទះរបស់ខ្ញុំហើយ ត្រូវស្រែកហៅ យើងនឹងឆ្លើយ ហៅអ្នកឲ្យចូលទៅ ។ នៃសម្លាញ់ រឿងដែលខ្ញុំប្រាប់អ្នកទាំងប៉ុន្មាននេះ មិនសូវមាននរណាចេះដឹងទេ មានតែពួកអ្នកប្រាជ្ញទើបចេះដឹងច្រើនជាងនេះទៅទៀត ។ មាណពចំកត់សំគាល់តាមដែល

ខ្មោចតូចនិយាយប្រាប់ដោយសព្វគ្រប់, លុះព្រឹកឡើង ក៏ដើរទៅតាមខ្សែអម្បោះដែលខ្មោចបង្ហុតទុកឲ្យ ដើរទៅលុះដល់ដំបូក ក៏ផុតអស់ខ្សែអម្បោះ ទើបស្រែកហៅថា "អើបងតូចសម្លាញ់!" តូច ឆ្លើយ កូក! ពីក្នុងដំបូកមក ហើយហៅមាណពឲ្យចូលតាមប្រហោងដីតូចមួយប៉ុនរន្ធចង្រិត, ពេលនោះមាណពចូលមិនបាន ព្រោះរន្ធនោះតូចពេក គ្រាន់តែឈ្ងោកមើលទៅ ឃើញខ្មោចតូចនិងប្រពន្ធកូនគេនៅក្នុងនោះរងួយ, លុះតែខ្មោចតូចចេញមកដឹកដៃនាំចូល ទើបបានចូលទៅកើត ៗ លុះចូលទៅដល់ហើយ ខ្មោចតូចប្រាប់ប្រពន្ធឲ្យសំពះសួរទទួលស្គាល់មាណព ឲ្យចេះស្រឡាញ់រាប់អានគ្នាតទៅ, និយាយសំណេះសំណាលបន្តិច ក៏នាំមាណពដើរមើលក្នុងផ្ទះដំបូកគេនោះ ទាំងបាននិយាយប្រាប់មាណពបណ្ដើរថា ចូរសម្លាញ់មើលចុះ សម្បត្តិទ្រព្យមានច្រើនគ្មានខ្វះអ្វីទេ មានផ្ទាំង ចានគាំបិត ពូថៅ មាស ពេជ្រជាដើមនេះ, នែសម្លាញ់ ដែលខ្ញុំឲ្យឯងមកនេះ គឺខ្ញុំចង់ផ្ទេររបស់ទាំងអស់នេះឲ្យអ្នក ដោយខ្ញុំយល់ថា អ្នកជាម្ចាស់នៃទ្រព្យនេះ ហើយទ្រព្យរបស់អស់ទាំងនេះ ពិតជារបស់អ្នកឯងហើយ ព្រោះកាលស្ដេចខ្មោចចាត់ខ្ញុំឲ្យមកនៅចាំរក្សា បានផ្ដាំថាឲ្យចាំដរាបដល់មានមនុស្សណាមួយមកដល់នៅក្នុងទីនេះ អ្នកនោះជាមនុស្សកំព្រាអនាថា រស់នៅដោយសារគែលលក គ្មានឈ្មោះ ហើយស្ដេចខ្មោច

បានតាំងសន្មតឈ្មោះទុកឲ្យផងថា "ទៅតែលលក", ឯខ្ញុំនេះ ក៏នឹងត្រូវបានរួចវេនអស់កម្មពៀរ ឈប់ធ្វើខ្លាចចាំយាមត្រឹមនេះដែរ នឹងទៅកេតចាប់កំណើតកើតនឹងគេជាមនុស្សវិញហើយ, ដូច្នេះ ប្អូនអកទទួលយកទៅចុះ ។ ទៅមាណព គិតឃើញថា ខ្លួនអញនេះ មកនៅក្នុងព្រៃតែម្នាក់ឯង ឥតញាតិមិត្រសាច់សាលោហិត ទ័លក្រខ្លាំងណាស់, ណាមួយទឹកថា ខ្លួននេះ តាំងពីកើតមកមិនដែលមានឈ្មោះថាអ្វី ស្រាប់តែត្រូខ្លាចតូចដាក់ឈ្មោះថា "ទៅតែលលក" ឲ្យដូច្នោះ ក៏ទឹកគួរឲ្យចង់សើចព្រោះសមរម្យនឹងជីវភាពរបស់ខ្លួនហើយ ។ វាត្រេកអរណាស់នឹងឈ្មោះនោះណាស់, តែនៅមានគិតថា ក្រែងគេឯណា ទេឬ ដែលឈ្មោះ ទៅតែលលក, ប៉ុន្តែដល់ទឹក ៗ ទៅ ឃើញថា គ្មានរណ៍ាក្រៅពីអញនេះទៀតទេ ព្រោះខ្លាចតូចនេះគេដឹងណាស់ គេមិនដែលថាផ្តេសផ្តាស, បើអ៊ីចឹងមែននោះ អញមានលាភធំហើយពេលនេះ, សម្បត្តិប៉ុណ្ណោះបើនឹងចង់ធ្វើសេដ្ឋីក៏បាន, តែតាស់បន្តិច ឯងធ្លាប់តែក្រ បើនឹងយករបស់ទ្រព្យទាំងនេះក្លាមទៅ មិនដឹងជានឹងយកទៅទុកឯណា, ម្យ៉ាងទៀតខ្លាចក្រែងមានអ្នកណាមួយមកដល់ តែគេឃើញហើយ គេនឹងប្លន់យកអស់, ទើបនិយាយទៅកាន់ខ្លាចតូចថា - បងតូចសម្លាញ់! ខ្ញុំមានចិត្តត្រេកអរណាស់ ដែលបងថានឹងប្រគល់ទ្រព្យរបស់ឲ្យនេះ ខ្ញុំព្រមទទួលយកដោយសោមនស្សគ្មានប្រកែកអ្វីឡើយ, ហើយគុណបងមានមកលើរូប

ខ្ញុំ ធំណាស់ រកអ្វីប្រៀបស្មើពុំបានទេ, តែថា រូបខ្ញុំនេះ ដូចជាបងឃើញនឹងភ្នែកស្រាប់ហើយ មានតែខ្លួន នឹងកូនខ្ទមកំព្រកតូចមួយ នឹងយកទ្រព្យរបស់អស់នេះទៅទុកមិនមានកើតទេ ឲ្យខ្ញុំសុំផ្ញើទុកនឹងបងនេះសិន បើកាលណាខ្ញុំមានការត្រូវការនឹងអ្វី សឹមខ្ញុំមកយកទៅប្រើប្រាស់, ឯបងទៀតសោត ក៏កុំអាលទៅណាចោលខ្ញុំ ត្រូវនៅនេះសិន គ្រាន់បានជាគ្នា ជួយមើលសុខទុក្ខខ្ញុំផង, ខ្លាចតូច ក៏យល់ស្របតាមថា អើ! ហើយនិយាយគ្នាលេងយ៉ាងស្និទ្ធស្នាលប្លែកអំពីមុន ដោយចិត្តស្មោះស្ម័គ្រអស់ពីចិត្ត, និយាយគ្នាលេងយូរហើយ មាណពក៏លាត្រឡប់វិញ, តូចព្រមទាំងប្រពន្ធកូន ជូនដំណើរហូតផុតចេញពីដំបូក ។ ចាប់ពីពេលនោះមក គេស្និទ្ធស្នាលទៅមករកគ្នាញឹកញាប់ជានិច្ចកាលណាស់ ទៅណាមកពីណា តែងតែទៅមកជាមួយគ្នា, ការណ៍ណា ដែលចៅកែលលកមិនចេះ មិនដឹង មិនយល់ ខ្លាចតូចតែងប្រាប់បង្ហាញដោយស្មោះឥតមានលាក់លៀមអ្វីសោះឡើយ ។

សម័យមួយ ពេលព្រឹកព្រហាមស្រាង ៗ ចៅកែលលក ក្រោកពីដំណេក ស្ពាយបំពង់ទឹកមួយនៅស្មា ដៃកាន់កាំបិត ចេញទៅបង ដើម្បីលើកលប ដោះអន្ទាក់, លុះទៅជិតដល់កន្លែងដាក់អន្ទាក់ ស្រាប់តែឮខ្លាស្រែករំពងព្រៃ លាន់ព្រៃច្រោកច្រាវ ៗ មើលទៅឯងអន្ទាក់វក់វេកដើក ៗ, ខ្ញុះ គឺជាស្តេចខ្លាធំមួយ ស្វែងរកចាប់សត្វជាអាហារ មក

ផាប់អន្ទាក់តាំងពីពេលពាក់កណ្ដាលអធ្រាត្រ  ទោះចំបម្រះបណ្ដាច់អន្ទាក់អស់ទំហឹងយ៉ាងណា ក៏ពុំរួចសោះ, មាណពពេលឃើញដូច្នោះហើយ ដើរលបៗចូលទៅមើល  ដឹងជាក់ជាខ្លាជាប់  ក៏តាំងរកបានព្រនង់មួយយ៉ាងមាំ ដើរអន្ទមៗ ញ៉ើបៗ ចូលទៅមុងទៀត  ទឹងសំពងខ្លាសម្លាប់ បន្លឺសម្លេងថា «អៃយ៉ា អាគ្រហះលេច! អញរកតែមុខអានេះជាយូរថ្ងៃហើយ ថ្ងៃនេះអញអាឯងដល់ហើយ  អានឹងត្រូវព្រនង់នេះឥឡូវ  អញផ្ដាច់អាយុអាម្ដងហ្នឹង, អន្ទាក់នេះអញដាក់យកសត្វដទៃសោះទេ  ម្ដេចក៏អាឯងមកជាប់»  ថាហើយក៏យារព្រនង់ជាប ប្រុងនឹងសំពងៗ ខ្លាព្រួសដីមាណពគម្រាម ហើយយារព្រនង់ទឹងសំពងដូច្នោះ  គិតថា-នុជីវិតអញ!  ទឹងក្បែយឥឡូវនេះមិនខានហើយ, ទើបប្រញាប់និយាយអង្វរសុំជីវិតថា ឱលោកម្ចាស់អើយ! សូមលោកអាណិតមេត្តាទុកជីវិតខ្ញុំ  កុំអាលធ្វើទុកបុកម្ដេញខ្ញុំភាម  ចាំខ្ញុំនិយាយរឿងមួយឲ្យលោកម្ចាស់ថ្លៃបានដឹង,  ហើយខ្លានិយាយប្រាប់ជាបន្ទាន់នោះថា  ខ្ញុំនេះជាខ្លា  ជាតិសត្វតិរច្ឆានក៏ពិតមែន  ប៉ុន្ដែពុំមែនជាខ្លាសាមញ្ញដូចអស់ទាំងខ្លាផ្ដេសផ្ដាសទេ  គឺជាស្ដេចខ្លាមានបុទ្ធិអំណាចលើខ្លានានានិងសត្វចតុប្បាទគ្រប់ប្រភេទ,  សព្វថ្ងៃខ្ញុំរស់នៅដោយមានខ្មោចព្រាយធំៗព្រមទាំងពួកម្រេញគង្វាលតាមរក្សាជានិច្ច បើចង់តំណែងការឲ្យខ្លួនជាសត្វចតុប្បាទណាមួយដូចជា គោ ក្របី ជ្រូក ប្រើស ព្រាយ ក៏បានដូចចិត្ត, ឲ្យតែលោកដោះលែងខ្ញុំចុះ ខ្ញុំនឹងសំដែងរិទ្ធិជូនមើលឥឡូវក៏បាន,

ថ្ងៃនេះ ខ្ញុំចេញដើរត្រូវលើកសីផ្ទតសូន្យ បានជាមកប្រទះនឹងគ្រោះនាម ក្តាមខ្យងដូច្នេះ, លោកអើយ ! បើលោកមេត្តាទុកជីវិតខ្ញុំ ខ្ញុំសូមធ្វើសច្ចាសន្យាថា នឹងបម្រើលោកអស់មួយជីវិត តាមដែលលោកត្រូវការប្រើ, ចំណែករូបលោកសោត ក៏មិនមែនសុទ្ធតែបានសុខជានិច្ចនោះទេ លែងអីនឹងមានធុរៈ, បើកាលណា លោកមានធុរៈអ្វី គ្រាន់តែនឹកទៅដល់ខ្ញុំៗនឹងមកដល់ជួយយកអាសាលោកភ្លាម សូមលោកជឿទុកចិត្តចុះ ។ ចៅតែលលកថា អញមិនទុកចិត្តអាកំណាចឯងទេ អាឯងចេះតែនិយាយឲ្យតែរួចពីមាត់ ឲ្យតែបានរួចខ្លួន គ្មានទៅស្មោះត្រង់អ្វីទេ ព្រោះអាឯងនេះ សាហាវខ្លាំងណាស់ អញលែងពុំទាន់បានទេ ។ កំពុងតែជជែកនឹងខ្លា ទទួលខ្មោចតូចដឹងហើយបានទៅដល់ភ្លាម ខ្សឹបប្រាប់ថា មិនអីទេ លែងវាទៅចុះ ប៉ុន្តែ ត្រូវឲ្យវាកាឡាខ្លួន ឲ្យយើងមើលឥឡូវ, ទើបចៅតែលលកប្រថុយចូលទៅកាត់ខ្សែអន្ទាក់ទាំងភិតភ័យប៉ផ្អុក ហើយប្រុងស្មារតីយ៉ាងខ្ជាប់ផង ប្រាប់ថា ចូរឯងសម្តែងឫទ្ធិឲ្យអញមើលឥឡូវនេះកុំខាន, ស្តេចខ្លានោះ បានរួចខ្លួនពីសេចក្តីស្លាប់ហើយ ក៏សម្តែងសេចក្តីស្មោះត្រង់ម្តងទៀត ហើយចាប់ថ្លែងឫទ្ធិផ្សេងៗឲ្យគេមើល រួចលាចៅតែលលកចូលព្រៃទៅរកស៊ីតាមប្រក្រតី តាំងចិត្តថា នឹងមិនបំភ្លេចគុណគេចោលទេ ។

ចៅតែលលក បន្តដំណើរចុះទៅបឹងលើកលបយកត្រី ជាមួយនឹងខ្មោចតូចផង, ដល់កន្លែងដាក់លប ស្រាប់តែឃើញសត្វចតុប្បាទមួយ

មុខស្រួចថ្មើម ជើងខ្លីៗ សម្បុរត្នោត ស្រដៀងនឹងសត្វកំប្រុក តែមើលទៅមាឌធំជាងកំប្រុក, ខ្នោចតូច ស្រែកប្រាប់ថា គ្នាយើងស្ការជាប់លប ទើបវាស្គាល់ថានោះជាសត្វស្ការ ហើយលើកលបមើលទៅមិនឃើញមានត្រីមួយសោះ វាខឹងណាស់នឹងស្ការដែលគ្នាកំពុងបម្រះវិលៗក្នុងលបនោះ ថាស៊ីត្រីវាអស់ ក៏ទាញព្រនង់ប្រុងនឹងសម្លាប់, ប៉ុន្តែនៅពេលនោះ ស្ការនិយាយអង្វរសុំទោសទាន់តាមទំនងដូចជាខ្លាដែរថា សុំលោកអត់ទោសខ្ញុំជាស្តេចស្ការ អាចបេះកាឡាខ្លួនធ្វើជាសត្វបក្សីផ្សេងៗ បានគ្រប់បែប បើលោកដោះលែងខ្ញុំឲ្យរួចជីវិតហើយ ខ្ញុំនឹងធ្វើបង្ហាញ ហើយបើពេលណាលោកមានទុក្ខធុរៈ ខ្ញុំនឹងមកជួយ ៗ ចៅតែលលកបែរមកសួរខ្នោចតូចៗ ដឹងថា ពិតដូចស្ការថានោះមែន ទើបប្រាប់ថាឲ្យលែងវាទៅចុះ ៗ ចៅតែលលកលែងស្ការៗ ក៏សម្តែងរិទ្ធិប្លែកៗ ហើយលាទៅរកស៊ីតាមសេចក្តីសុខតទៅ ទាំងបានផ្តាំថា បើកាលណាខ្ញុំមានធុរៈ ខ្ញុំនឹករក ត្រូវមកភ្លាម ៗ ថ្ងៃនេះ គេគ្មានបានអ្វីដូចសព្វថ្ងៃទេ ទើបគេដងទឹកត្រឡប់មកខ្ទមវិញ រួចចេញទៅថែចំការដូចប្រក្រតី ។

ព្រឹកស្អែកឡើង គេទៅបឹងជាមួយខ្នោចតូចដូចទម្លាប់មុន ៗ មើលអន្ទាក់រួចចុះទៅលើកលប ស្រាប់តែប្រទះនឹងពស់មួយធំសម្បើមជាប់ក្នុងលប វាកាន់តែខឹងខ្លាំងជាងមុន ៗ ស្ទុះធ្លាគរៀងនឹងសម្លាប់ពស់នោះ, តែពេលនោះ ពស់និយាយអង្វរហូរហែសុំរួចជីវិត មានទំនងដូចខ្លានិង

(នៅមានត)

# ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត

ដែលមាននៅពុទ្ធសាសនបណ្ឌិត្យ

លោកញ៉ុក-ថែម រៀបរៀង

---

(ក)

បំណងដើម: " សាស្ត្រា ច្បាប់រាជបណ្ឌិត "(១)

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ បទព្រហ្មគីតិ ។

ប្រភពរឿង: ច្បាប់ទូន្មានកូនចៅ តាមប្រពៃណីពីបុរាណ ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១០ សន្លឹក ។ ឯក-
សារនេះប្រហែលពុទ្ធសាសនបណ្ឌិត្យ បានមក
អំពីវត្តវេឡុការាម ចុះលេខសាស្ត្រា ១.៣៧៨ ។

អត្ថបទដើម: ៙ នេះបទព្រហ្មគីតិ ។ សារសព្វច្បាប់ព្រេងព្រឹទ្ធ
ដោយសុចរិតនីនាមា ទៅក្រុមរាជសុភា ជាទំនឹម

---

១– ច្បាប់នេះ មានខ្លឹមសារ ស្របតាមប្រពៃណី ជាតិទាំងដើមកាព្យ ទាំងពាក្យពេចន៍ មិនសូវមានគក់ ក្តាំក្តុងអ្វីដែរ ។

ទំនៀមនៃ ៗ ខ្ញុំប្រាជ្ញប្រែពាក្យពិត ក្នុងសុចរិត
ធម៌ប្រពៃ ឈ្មោះរាជបណ្ឌិតថ្លៃ វៃវាងឆ្លាសអស់
អាចិ ៗ ទុកតឲ្យអស់ជន ស្តាប់យកបុណ្យគ្រប់
អាត្មា ឲ្យគិតពិចារណា តាមតម្រាច្បាប់ប្រពៃ ៗ

. . . . . ៗល ៗ

អត្ថបទបញ្ចប់: ឲ្យចាំជាក់ក្នុងប្រាណ គ្រាន់ទូន្មានខ្លួនយប់ព្រឹក
បើក្មេងឲ្យរំលឹក ពាក្យអាពុកម្តាយប្រដៅ ៗ មិនតែ
អាពុកម្តាយ គ្រូបាធ្យាយក្រែងជាខ្ទៅ អ្នកប្រាជ្ញ
ទៀតបេះជ្រៅ ចងជាច្បាប់ទុកតមក ៗ ប្រដៅ
យើងគ្រប់គ្នា ឲ្យឧស្សាហ៍ខំរិះរក រៀនច្បាប់ចាំ
ចាប់យក ដាំពន្លកពន្លឺខ្លួន ៗ អ្នកណាបើបានស្តាប់
ត្រេកត្រង់គ្រាប់ទុកជាក្បួន អ្នកនោះនឹងនាំខ្លួន
ឲ្យបានសុខក្នុងលោកិយ ៗ ឥតទុក្ខ ឥតទោស
ភ័យ ប្រសើរក្រៃទាំងប្រុស-ស្រី ទោះទៅបរ-
លោកក្តី នឹងបានសោយសុខសួគ៌ា ៗ នេះ
ច្បាប់រាជបណ្ឌិត ខ្ញុំគន់គិតដោយសទ្ធា ច្បាប់
នេះប្រសើរជាំ ជាសូរេចម៉្លេះឯងហោង ៗ

x x x

បំណងដើង: " សាស្ត្រាល្បើកមទ្រីបតិ "

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ បទព្រហ្មគីតិ ។

ប្រភពរឿង: មហាវេស្សន្តរជាតក ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ផ្សំ ២៤ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានថតចម្លង តាមច្បាប់ត្រៃវត្សកាកម កាលពី គ.ស. ១៩៤៣ ចុះលេខ ១.៣៧៦ ។

អត្ថបទដើម: ៙ នេះបទព្រហ្មគីតិ ជាតំណកាលព្រាហ្មណ៍ចង នានាំអ្នកទាំងសង បណ្តើរក្នុងព្រៃព្រឹក្សា ។ មាន ក្នុងព្រះបាលី ចមដិនស្រីស្តេចទេសនា ក្នុងកណ្ឌ មទ្រីបាតិ ចាយបែងចារអំពីតំ ។ . . .

. . . . . ។ល។

អត្ថបទបញ្ចប់ សម្តេចព្រះមទ្រី ស្តាប់ពោធីទើបនាងណា ទៀង ទូលព្រះភជា ថាកាលខ្ញុំទៅព្រឹក្សា ។ ពីកាល

ថ្ងៃម្សិលមិញ ខ្ញុំចរចេញរកផលា ឃើញកើតមាន
អស្ចារ្យ មេឃដំណាលស្រទំម៉ោ ៗ នេះគឺពាន
បារមី ព្រះចក្រីសាងពោធិ៍ រង្គុំគីរទន់កវី
ពេញអស្ចារ្យ ។ នាងអរទឹងចក្រី សាងបារមី
ត្រាស់ប្រាថ្នា សប្បាយក្នុងកាយាពជកញ្ញាឥត
មានម៉ង ។ និពានក្នុងបាលី ព្រះជិនស្រីសូរសា-
សង ចំណោទចោទចារចង មានតម្រាស់ត្រាស់
ទេសនា ។ ចេញពីក្នុងបាលី អស់សេចក្តីមទ្រីបាពិ
សម្រេចស្រេចម៉ូះណា ព្រះគាថា ៩០ គត់ ។

x x x

ចំណងជើង : "សាស្ត្រាសីល ១០"

អ្នកនិពន្ធ : ករ៍ ម៉ា ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ។

ប្រភេទរឿង : សីល ១០ ប្រការ ក្នុងលទ្ធិពុទ្ធនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៥ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្ត
វេឡុកាពមផែរ ចុះលេខសាស្ត្រា ១.៣៧៦ ។

អត្ថបទផ្ដើម: ៙ អហំនរោ នមការេ អភិវន្ទេ អាពោសិ
ពុទ្ធធម្មេ សង្ឃវិវរេ វិវុត្តមំ ។ ខ្ញុំលុតលើកករ
កាយកបបវរ ទសសីលំ លើកឡើងដាក់ដល់
មណ្ឌលសិរសំ ក្រាបថ្វាយវន្ទំ ព្រះពុទ្ធសាសនា ។

. . . . . . ។ល។ . . .

អត្ថបទបញ្ចប់: ខ្ញុំព្រះករុណា នាមដើមឈ្មោះ ម៉ា ចារចង
ទៀនទុក ជាច្បាប់ខ្ទួនាន សូមបានបានសុខ
និរនេសទោសទុក្ខ ភ័យផងទាំងឡាយ ។
ពាក្យពេចន៍ល្បិចល្បែក ផ្គរផ្គាប់លៃលើក
ជួបចប់បរិយាយ តែងតាមប្រាជ្ញា រៅហារ
អធិប្បាយ ប្រៀបប្រែស្រង់ស្រាយ សូរេច
ម៉េះហាង ។

x x x

បំណងដើង: " សាស្ត្រា ស្វាសួត ហង្សសួត "

អ្នកនិពន្ធ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ : បទកាកគតិ ។

ប្រភពរឿង: រឿងព្រេង ឥទ្ធិពលពុទ្ធនិយម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៥ សន្លឹក ។
ឯកសារនេះ បានមកអំពីវត្តវេឡុការាម កាលពី
គ.ស. ១៩៤៣ ចុះលេខសាស្ត្រា ១.៣៧៦ ។

អត្ថបទផ្ដើម: ៙ នេះបទកាកគតិ ។ ប្អូនអើយពៅស្ដាប់
បងនិងថ្លែងប្រាប់ និយាយមួយណា កាលពោធិ
សត្វ យកជាតិជាស្វា ស្ដេចមានកិរិយា និង
ស្វាពានរ ។ មានកាលមួយថ្ងៃ ស្វាឈ្មោលទៅព្រៃ
បេះផ្លែឧទុម្ពរ មានខ្លាមួយដើរ មើលយល់
ពានរ ខ្លានោះត្រេកអរ ចិត្តបង់ខាំធី ។ .
. . . . ។ល។

អត្ថបទបញ្ចប់: ហង្សហើរទៅទុំ ខែនទិព្វបន្ទុំ អាសនាប្រពៃ
ទើបហង្សទេសនា ពិរោះពេកក្រៃ នាងយកទ្រព្យ
ថ្លៃ បាចសាចបូជា ។ ខេមាទេវី នាងអរ

ឥតបី ថ្លែងថ្លឹងឧបមា អាសូរពេជហង្ស នាង

ទ្រង់ករុណា ឲ្យនាំទៅនា លំនៅព្រះអង្គ ។

x x x

បំណងជើង: " សាស្ត្រា ច្បាប់ប្រដៅខ្លួន "

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ។

ប្រភពរឿង : ច្បាប់ទូន្មានកូនចៅ តាមប្រពៃណី ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ក្សែ មាន ៦ សន្លឹក ។

ឯកសារនេះ ប្រហែល ពុទ្ធសាសនបណ្ឌិត្យបាន មកអំពីវត្ត វេឡុការាមដែរ ចុះលេខ សាស្ត្រា ១.៣៧៦ ។

អត្ថបទផ្ដើម : ៙ នេះបទកាកគតិ ទើបចង់ជា ច្បាប់ទុកទូន្មាន តាមដោយគន្ធង ព្រេងព្រឹទ្ធបុរាណ ប្រាជ្ញលោក និទាន ប្រដៅបុត្រភ្ញា ។ ហៃកូនពន្លក ស្ងួន អើយមាសយក បណ្ដាំបិតា ដីពុកនេះចាស់ ឥត

អត្ថបទដើម: ៙ នេះបទកុដន្តលីលា ។ ទឹងថ្លែងសំដែង ពណ៌នា មើលមនុស្សពុតពាល មិនយកក្បួន ច្បាប់ ។ ប្រដៅសឹងប៉ាពុំគាប់ ផ្សិតពាលគត់ ច្បាប់ យកតែចិត្តឯង ។ គេស្តីសឹងទ័ងគគ្រេង បេះតែដើរលេង សព្វដោយផ្លូវឆ្នា ។ . . . . . . . . . . ។ ល ។

អត្ថបទបញ្ចប់ : អ្នកណាអាចគិតទុក្ខ ទឹកដល់អនិច្ចំ អនត្តានោះ មាន ។ អ្នកនោះចំពោះហៅហ៊ន លោក ទុកស្មើស្ពាន ធ្ងន់រួចដល់ត្រើយ ។ អ្នកណា ខ្ជាញខ្ជិលព្រងើយ ដឹងច្បាប់ធម៌ហើយ ពុំកាន់ ឡើយណា ។ ចង់ស្ដាប់គ្រាប់ពុតពាលា ទឹង កើតវេរា បានបាបក្រាសក្រៃ ។ សោយទុក្ខ នរកនាយនៃ លំបាកសព្វថ្ងៃ វែងចប់ម្ល៉េះ ហោង ។

x x x

(មានត)

# ជីវប្រវត្តិរបស់ឈ្មោះ ប៊ូ-ប៉ូ



អ្នកប៊ូ-នាងពុជ ជាតិខ្មែរ ជាកសិករ ទីលំនៅ ៗ ឃុំថ្កូ ស្រុកល្វាឯម ខេត្តកណ្តាល មានកូនបីនាក់ គឺនាងស៊ុម ១ នាងអ៊ូ ១ កុមារជាហៅ ប៊ូ-ប៉ូ ១ ។

ក – កុមារប៊ូ-ប៉ូ កើតថ្ងៃពុធ ខែមិគសិរ ឆ្នាំខាល គ.ស. ១៩០១ មានរោគអ្នកហឺតតាំងពីកើតមកជាប់រហូតដល់អាយុ៩ ឆ្នាំទើបបាត់ ។ ប៉ុន្តែដល់អាយុ៤០ ឆ្នាំប្លាយ រោគនេះកើតឡើងទៀតជាប់រហូតដល់ចាស់ជរា ។

ខ – កុមារប៊ូ-ប៉ូ អាយុ ១០ ឆ្នាំ នៅវត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ ជាមួយព្រះបាឡាត់មង្គលពៅ ជាមាបត្តិកក៏ចាប់រៀនអក្សរសាស្ត្រខ្មែរពីត្រឹមអាយុ១០ ឆ្នាំមក ។ នៅវត្តបានជិតមួយឆ្នាំ នឹករលឹកម្តាយពេក ក៏លបរត់ពីវត្តជិះកប៉ាល់ច្រឡំទៅលើកប៉ាល់ដើរផ្លូវភ្នំពេញ-ក្រូចឆ្មារ នៅក្នុងកប៉ាល់នេះកន្លះខែ ទើបបានទៅដល់ម្តាយ ។

គ – កុមារប៊ូ-ប៉ូ អាយុ១១ ឆ្នាំចូលរៀនយីកេនៅសន្ទុន ស្វាយមាស វិហារសួរ បាន១ឆ្នាំចូលរៀនល្ខោនខោលនៅឃុំថ្កូ ស្រុកកំណើត បាន១ឆ្នាំ ឈប់រៀនល្ខោនមកនៅបំរើលោកឧកញ៉ាពុកប៉ួសឯចាស់ នៅវត្តបទុមវតី ភ្នំពេញបាន២វស្សា លោកសឹកទៅនៅស្រុកវិញ ។

ឃ - កុមារ ប៊ូ-ប៉ូ អាយុ ១៤ ឆ្នាំ បានបួសនេននៅវត្តស្វាយតាឯម ស្រុក-ខេត្តដដែលព្រះគ្រូព្រហ្មវិសុទ្ធិជាព្រះឧបជ្ឈាយ៍ ។ នៅវត្តនេះ ជាគណៈធម្មយុត្តបាន៤វស្សា ចូលមកនៅវត្តបទុមវតី កុដិព្រះមហាព្រហ្មមុនី "ស៊ុក" ចាប់រៀនព្រះត្រៃបិដកតាំងពីបួសនេនអាយុ១៧ឆ្នាំ ។ រៀននៅវត្តបទុមវតីអំពីលោកគ្រូអាចារ្យ ជាន-កែវ, ធន យ៉ាង ។ រៀននៅវត្តស្វាយតាឯមអំពីលោកគ្រូបាឡាត់ទឹម-សួន គុណ-កង អ៊ុក-ម៉ូត ។

នេនប៊ូ-ប៉ូ អាយុ២០ឆ្នាំប្រឡងជាប់ជាសិស្សសាលាបាលីជាន់ខ្ពស់នៅវិហារព្រះកែវមរកតក្នុង គ.ស.១៩៤០ រៀនគ្រប់ប្រាំឆ្នាំក៏ប្រឡងជាប់បានសញ្ញាបត្រជាព្រះមហាបរិយត្តិ ក្នុងគ.ស.១៩៤៥ ហើយមិនទាន់សឹកក្លាមទេ នៅរៀនខ្លួនឯងនិងបង្រៀនសិស្សតទៅទៀត ។

ង— នេន ប៊ូ-ប៉ូ អាយុ២១ឆ្នាំ បានឧបសម្បទជាភិក្ខុក្នុងវត្តបទុមវតី មាននាមងាយាថា បិតវីរិយោ ។ សម្តេចព្រះមង្គលទេពាចារ្យ "ស៊ុក" ជាព្រះឧបជ្ឈាយ៍ ព្រះធម្មឧត្តម អ៊ុង-ស្រី ជាកម្មវាចាចារ្យ ។

ច— កិច្ចការជាប្រយោជន៍ចំពោះពុទ្ធសាសនាដែលព្រះមហា ប៊ូ-ប៉ូ បានធ្វើរួចរៀបរាប់តទៅនេះ៖

ព្រះមហាប៊ូ-ប៉ូ បានទៅដឹកនាំក្រសួពីឃុំស្វាយរលំ ស្រុកស្អាង យកមកកសាងវិហារថ្មីនិងបន្ទប់ខ្លួនមាន៣បន្ទប់ ។ បានបង្រៀនសិស្សនៅកុដិតាំងពីមួយរូបពីររូបរហូតដល់ច្រើនរូប ក៏ធ្វើសាលាខ្ទង

បង្រៀនក្នុង១ថ្ងៃ៣ពេលគឺ ព្រឹក រសៀល និងយប់ ប្រើតាមមង្សែ ព្រោះពេលនោះមិនទាន់មានអគ្គិសនីចូលក្នុងវត្តទេ ។ មានបង្រៀនធម៌វិន័យ ពុទ្ធប្រវត្តិ ពង្សាវតារកម្ពុជា ភាសាសៀមនិងឡាតាំងខ្លះផង ។ មុនដំបូងព្រះមហាប៊ូ-ប៊ូ បង្រៀនតែម្នាក់ឯងគ្រប់ទាំង៣ពេល ក្នុង១ថ្ងៃ ។ ក្រោយមកទើបមាន លោកអាចារ្យដទៃជួយបង្រៀននៅពេលខ្លះបានបាត់សិស្សដែលចេះចាំស្ទាត់ជាងគេឲ្យជួយបង្រៀនខ្លះផង ។ បានបាត់លោកអាចារ្យខ្លះឲ្យទៅនៅទៀនក្នុងវត្តធម្មនិគហៅប៉ាធា ខេត្តបាត់ដំបង ក្នុងវត្តមង្គលតេនាកម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ក្នុងវត្តទំពចំបក ស្រុកកណ្ដាលស្ទឹងនិងវត្តស្វាយតាឯម ស្រុកល្វាឯម ខេត្តកណ្ដាល ព្រោះគ្រានោះមិនទាន់មានសាលាបាលីនៅទេ ។

បានសរសេរអធិប្បាយពីបាលីវេយ្យាករណ៍ ពីពិធីប្រែ ប្រយោគបាលីច្រើនមុខហើយបោះពុម្ពដោយបាហួយចែកបាយដល់សិស្សទាំងឡាយឥតយកថ្លៃ ។ ក្នុងថ្ងៃមួយៗមានសិស្សជាងមួយរយរូបចូលរៀនគ្រប់ទាំង៣ពេល ។ បាត់ការឲ្យមានទឹកតែចែកសិស្សឆាន់ និងថ្នាំជក់ ថ្នាំពេទ្យខ្លះពល់ថ្ងៃ ។ បាត់ឲ្យមានការប្រឡងល្បងចំណេះសិស្សពល់ខែឆ្នាំហើយឲ្យរង្វាន់លើកទឹកចិត្តតាមលេខទាប-ខ្ពស់ ។ លោកអាចារ្យគ្រប់រូបមានបៀវត្សប្រចាំខែតិចខ្លះច្រើនខ្លះតាមសមត្ថភាព តែព្រះមហាប៊ូ-ប៊ូ មិនយកបៀវត្សទេ គឺជាអ្នកទំរគបច្ច័យចំណាយ ។ បច្ច័យដែលបានដោយ

សូត្រមន្តឬទេសនាចំណាយទៅក្នុងសាលានេះទាំងអស់ ។ មានតាយកតាយិកាជាច្រើនជួយឧបត្ថម្ភដោយសៀវភៅសរសេរ ដីស ដីខ្មៅ-ស្វាប៉ាកា-ដីរលុប-ក្រដាស់ផ្តិត-តែ-ស្ករនិងបច្ច័យកល់ខែ ហើយចែកចាយវត្ថុ-ទាំងនេះដល់សិស្សគ្រប់រូប ។ មានលោកសង្ឃវត្តនួនមុនីកម ហៅវត្តថាន់ខ្ទះ វត្តស្វាយពាំពាខ្ទះ វត្តប្រយូរវង្ស ហៅវត្តឃុនព្រះញាតិខ្ទះចូលមកសុំរៀនក្នុងសាលាវត្តបទុមវតី ។

ង– ព្រះមហា ប៊ូ-ប៊ូ បួសភិក្ខុមួយវស្សាបានទទួលសមណសក្តិជាបាឡាត់អរិយព្រឹទ្ធទីហ៉ន់នា បួសភិក្ខុ៤វស្សាបានទទួលសមណសក្តិជាបាឡាត់ព្រហ្មវិជ្ជាទីរឿនលួង ជាអ្នកចាត់ព្រះសង្ឃទៅក្នុងព្រះរាជពិធីបុណ្យផ្សេងៗ មានចុតម៉ាយលោកចាងហ្វាងខែពុទ្ធសាសនបណ្ឌិត្យលេខ ចុះថ្ងៃទី ២ ខែមករាគ.ស. ១៩៣០ហៅព្រះមហាប៊ូ-ប៊ូ ឲ្យចូលទៅធ្វើការជាក្រុមជំនុំប្រែព្រះត្រៃបិដកក្នុងក្រុមពុទ្ធសាសនបណ្ឌិត្យ ក្នុងអាយុគំរប់ ៣០ឆ្នាំទាំងគេចជាភិក្ខុដោយលោកយល់ឃើញថាមហាប៊ូ-ប៊ូ ចេះចាំព្រះត្រៃបិដកនិងពិធីប្រែប្រយោគបាលីស្ទាត់គ្រាន់បើ ។ បានបៀវត្សក្នុង១ខែ ២៤ រៀល ។

ជ– ព្រះមហាប៊ូ-ប៊ូ បួសនេនបានពីរវស្សា បួសភិក្ខុបាន៩វស្សា រួមជា១៣វស្សា សឹកជាគ្រហស្ថក្នុងអាយុ ៣០ ឆ្នាំ គ ស. ១៩៣០ ហើយធ្វើមង្គលការក្នុងឆ្នាំនេះជាមួយនាងហ៊ុន-សឹងអ៊ឹម ជាតិខ្មែរអាយុ១៧ ឆ្នាំជាកូនស្រីច្បងរបស់ឈ្មោះដំទប់លេខ៦ ហ៊ុន និង នាងឈៀង ទី

លំនៅឃុំព្រៃកល្ងង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

ព្រះមហា ប៊ូ-ប៉ូ នឹងនាងហ៊ុន-សឹងអ៊ុមបង្កើតបានកូន៥នាក់ ស្លាប់មួយនាក់ទៅ នៅសល់តែ៤នាក់ គឺកូនទី១ប្រុសឈ្មោះ ប៊ូ-នរិន្ទ កើតនៅថ្ងៃទី ៦(៣) ៗ ៩ ឆ្នាំរកាបញ្ចស័ក ព.ស ២៤៧៦ ត្រូវនឹងថ្ងៃទី ២៨ ខែសូរយេត គ.ស.១៩៣៣ វេលាម៉ោង៧យប់ នៅឃុំព្រៃកល្ងង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

កូនទី២ ប្រុសឈ្មោះ ប៊ូ-នរេង្គ កើតនៅថ្ងៃ ៧(៣) ៗ ២ ឆ្នាំម្សាញ់ត្រីស័ក ព.ស.២៤៨៤ ត្រូវនឹងថ្ងៃទី ខែដេសមគ.ស.១៩៤១ វេលាព្រលប់ម៉ោង ៦ នៅឃុំព្រៃកល្ងង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

កូនទី៣ ស្រីឈ្មោះ ប៊ូ-នរម្យ កើតនៅថ្ងៃ ១ ៗ ៥(១១) ឆ្នាំច អដ្ឋស័ក ព.ស.២៤៨៩ ត្រូវនឹងថ្ងៃទី២៧ខែមេសា " អាវ្រិល " គ.ស.១៩៤៦ វេលាម៉ោង៦ព្រឹក នៅមន្ទីរពេទ្យផង៉ាង៉ម ជាពេទ្យពជការសង្កាត់លេខ២ ក្រុងភ្នំពេញ ។

កូនទី៤ ប្រុសឈ្មោះ ប៊ូ-នក កើតនៅថ្ងៃទី៣ ៗ ១(១) ឆ្នាំឆ្លូវឯកស័កព.ស ២៤៩២ ត្រូវនឹងថ្ងៃទី ៦ខែធ្នូ គ.ស.១៩៤៩ ម៉ោង៥ជិតភ្លឺ នៅផ្ទះពេទ្យឈូលខាងកើតផ្សារថ្មី សង្កាត់លេខ ៣ ក្រុងភ្នំពេញ ។

ឈ- មហាប៊ូ-ប៉ូ បានទៅនៅកែវិញ្ញាសាព្រះត្រៃបិដកកាគ ក្នុងរោងពុម្ពព្រះរាជទ្រព "នៅទីសាលាជែកចាស់" ចំនួន៦ខែ ។ ក្នុង១ថ្ងៃធ្វើការ ៣ពេល គឺពីម៉ោង៧ព្រឹកដល់ម៉ោង១១ថ្ងៃត្រង់ពីម៉ោង២រសៀលដល់ម៉ោង៥ល្ងាច និងពីម៉ោង៨យប់ដល់ម៉ោង ៤អធ្រាត ។ ឥតបានប្រាក់ម៉ោងទេ តែពួកអ្នករោងពុម្ពនោះបានប្រាក់ម៉ោងគ្រប់ៗគ្នា ។ ទៅកែវិញ្ញាសារនេះក្នុងគ.ស.១៩៣០ ។

ញ- មហាប៊ូ-ប៉ូ សូម្បីសឹកហើយក៏នៅតែធៀតឱកាសបង្រៀនលោកសង្ឃក្នុងវត្តបទុមវតីដែរ ថែមទាំងទៅបង្រៀននៅវត្តទួលមុនីរាមហៅវត្តថាន់ខុះនិងវត្តស្វាយពពែទៀត សល់ខាន់តែវត្តប្រយូរវង្សតែប៉ុណ្ណោះ ព្រោះលោកវត្តនេះចូលមករៀននៅវត្តបទុមវតីទាំងអស់ ។ មហាប៊ូ-ប៉ូ បង្រៀនដោយឥតថ្លៃឈ្នួលទេ គឺដោយមនោសញ្ចេតនាជ្រះថ្លានិងពង្រីកព្រះពុទ្ធសាសនាឲ្យសាយភាយទូលំទូលាយចេញទៅទៀត ។ មហាប៊ូ-ប៉ូ ចាប់បង្រៀនតាំងពីឆ្នាំ ១៩២៣ ជាប់រៀងរាល់ឆ្នាំរហូតដល់ចាស់ជរាទើបឈប់

មហាប៊ូ-ប៉ូ កាលនៅបួសបានផ្ដួចផ្ដើមគំនិតឃោសនាទាយកទាយិកាកសាងសាលាបាលី១ខ្នងពីរជាន់ដោយបេតុងអារមេ ដូចមានរូបរាងសាលានៅរហូតដល់សព្វថ្ងៃនេះ ។

ដ- មហាប៊ូ-ប៉ូ កាលការប្រពន្ធរួចហើយ ជួលផ្ទះគេនៅត្រឹមតែ៦ខែប៉ុណ្ណោះ ថ្ងៃឈ្នួល១ខែ៤រៀល ក៏សុំដីរាជការបាន១ឡូ៍ នៅមាត់បឹង

កេងកង ហើយសង់ផ្ទះខ្លួនទទឹង៤ម៉ែត្របណ្តោយ ៦ ម៉ែត្រគ្រឿងឈើប្រក់ស្បូវក្រាលរនាបអស់ប្រាក់ជាង២០០រៀល ហើយគាត់ប្រាក់ខែសងគេគង់១ខែ៦០រៀលទុកចាយវាយតែ៤រៀល បានដាំបន្លែជាច្រើនមុខបេះយកទៅលក់ឯផ្សារ យកប្រាក់ទិញអង្ករនិងត្រី ។ សម័យនោះ អង្ករ១តៅថ្លៃយ៉ាងច្រើន ៤ កាក់ ឬ ៤ កាក់កន្លះ ។

ប - មហាប៊ូ-ប៊ូ ពេលយប់ឆ្លៀតសរសេរក្នុងមុងអធិប្បាយ ពិធីប្រែប្រយោគបាលីបាន៥រឿងយ៉ាងវែងៗ ហើយប្រគល់សិទ្ធិឲ្យរោងពុម្ពកម្ពុជវ-ពេកាសបោះពុម្ពលក់ ឯអ្នកសរសេរគេបានមួយកាក់ទេ ។ បានសរសេរប្រែលោតប្រយោគនិងជាសេចក្តីទេសនាក្នុងគម្ពីរធម្មបទដ្ឋកថា ចប់ហើយប្រគល់ឲ្យរោងពុម្ពតាកបោះពុម្ពលក់ ។ បានរួបរួមពុទ្ធភាសិតក្នុងសុត្តន្ត-បិដក ខុទ្ទកនិកាយ ចំនួន២៨០បទ ប្រស្នាពុទ្ធប្រវត្តិ — វេយ្យាករណ៍ខ្មែររឿងព្រះកែវមរកត — រឿងខ្លួនជាគតិរបស់ខ្លួន — ករណីយកិច្ចរបស់ពុទ្ធបរិ-ស័ទនិយាយពីចតុរារិយសច្ច រឿងថ្ងៃឧបោសថតាមវិធីប័ក រឿងទាំងនេះបោះពុម្ពលក់ដោយខ្លួនឯង ។ បានសរសេរអត្ថបទខាងគតិធម៌ខ្លះ ខាងគតិលោកខ្លះជាច្រើនរឿងចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា នៃពុទ្ធសាសនបណ្ឌិត្យរាល់ខែឆ្នាំ សូម្បីឈប់ពីមុខក្រសួងនោះហើយ ក៏នៅតែឆ្លៀតសរសេររឿងផ្ញើទៅចុះផ្សាយទៀតដែរ ។

ឱ— មហាប៊ូ-ប៊ូ បានធ្វើជាសមាជិកគណៈកម្មការពុទ្ធិកសមាគមមជ្ឈ-

មណ្ឌលនៅវត្តឧណ្ណាលោមបាន៥ឆ្នាំ ធ្វើជាទាយកសមាជិកអនុព្ទិកសមាគមនៅវត្តលង្កាបាន១០ឆ្នាំ និងធ្វើជាសមាជិកគណៈកម្មការវប្បធម៌តាំងពីចាប់ផ្តើមមុនដំបូងបំផុតបាន ១ ឆ្នាំ ។ បានបង្រៀនព្រះសង្ឃនៅវត្តសាកវ័នគេជាគ្រូងក្នុំពេញបាន ១ ឆ្នាំ ។

ឃ - មហាប៊ូ-ប៊ូ ធ្វើគ្រូមជំនុំប្រែព្រះត្រៃបិដកបាន ១៣ ឆ្នាំ ចូលធ្វើជាអ្នកវក្កបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ពីថ្ងៃ៣ឆ្នាំ១០ឆ្នាំរពងទោស័ក ព.ស.២៤៨៣ ត្រូវនឹងថ្ងៃទី ៣ ខែសេបតម ឆ្នាំ ១៩៤០ រហូតដល់ថ្ងៃឈប់ពីមុខក្រសួងបានចំនួន ១៧ ឆ្នាំ ។

ណ - ក្នុងគ.ស. ១៩៤៥-៤៦-៤៧ ធ្វើការជាសាស្ត្រាចារ្យបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិអំពីភាសាខ្មែរ បាលី ក្នុង១សប្តាហ៍ ៣ម៉ោង ក្នុង១ម៉ោងបាន ១៩ រៀល ។

ក្នុងគ.ស. ១៩៤៨ បានតែងអត្ថបទ១ជាពាក្យ៧ និយាយពីទីក្រុងភ្នំពេញសម័យថ្មី ចូលប្រឡងតាមប្រកាសក្រសួងមហាផ្ទៃ ។ មេប្រ-យោគខ្មែរទាំងអស់សរសេរគ្រប់មាត់ ហើយឲ្យជាប់លេខ១ ក្នុងចំណោមអត្ថបទពប់រយ ។ ប៉ុន្តែបារាំងម្នាក់ធ្វើជាប្រធានរ៉ាសួន្យលុបចោលថាមិនបានការទៅវិញ ព្រោះជំនាន់នោះបារាំងកំពុងតែស្អប់អ្នកមានសញ្ញាប័ត្របាលីរ៉ាឃាត់លែងឲ្យចូលក្នុងក្របខណ្ឌរាជការ ដោយរ៉ាយល់ថាពួកអ្នក

រៀនព្រះត្រៃបិដកសុទ្ធតែបេះវាងផ្លូវនយោបាយ ដូចលោកអាចារ្យ ហែម-ចៀវ ជាដើម ថែមទាំងកប់ចោលសៀវភៅបោះពុម្ពរួច ពីរបីរយឈ្មោះ នៅក្នុងឃ្លាំងរបស់ពុទ្ធសាសនបណ្ឌិត្យ មិនឲ្យចេញផ្សាយទៀត ក៏ថាសៀវភៅទាំងនោះ សុទ្ធតែនិយាយពីនយោបាយដេញបារាំងឲ្យដើរចេញពីស្រុកខ្មែរ ។

ត - ក្នុងគ.ស ១៩៥៧ មហាប៊ូ-ប៉ូ បានតែងពុទ្ធភាសិត១បទថា វិរិយេន ទុក្ខមច្ចេតិ មនុស្សនឹងរួចផុតទុក្ខបាន ព្រោះតែមានសេចក្តីព្យាយាម “ ចូលប្រឡងក្នុងពិធីបុណ្យពាក់កណ្តាលពុទ្ធសាសនា ” (២៥០០ព.ស.) នៅក្រុងភ្នំពេញ ជាប់បានលេខ១ក្នុងចំណោមអត្ថបទជាង៤០ រឿងបានរង្វាន់ជាប្រាក់ ៣.៥០០រ និងព្រះពុទ្ធរូបសិតមួយអង្គ ។

ថ– មហាប៊ូ-ប៉ូ បានតែងតាំងជាមន្ត្រីកិត្តិយសទីឃុនបណ្ណាទុក្ស ។ បានទទួលគ្រឿងឥស្សរិយយស ៤ គឺ មុនីសារាភណ្ឌ១ អស្សឫទ្ធិកម្ពុជា១ អនុស្សព្រប្រាក់១ ពុទ្ធចក្រ១ ។

ទ– មហាប៊ូ-ប៉ូ បានទទួលនិវត្តន៍ពីថ្ងៃទី ១៣-៤-៥៩ បានប្រាក់និវត្តន៍ក្នុង ១ ខែ ១.៦៣២រ ហើយធ្វើការដោយជាប់កិច្ចសន្យាបាន ២ ឆ្នាំបន្តមកទៀត ប៉ុន្តែ ដោយខ្លួនមានជម្ងឺកាន់តែច្រើនឡើងទ្រាំធ្វើការមិនបាន ក៏លាលែងដាច់ស្រឡះពីមុខក្រសួងនេះ ។ បានទាំងលាលែងពី

សមាគមអ្នកនិពន្ធខ្មែរទៀតផង ។ ប៉ុន្តែលោកប្រធាន ហ៊ែល សុមផា លោក លាង-ហ័បអាន និង លោក លី-ធាមតេង មិនព្រមឲ្យលប់ឈ្មោះពីបញ្ជីទេ គ្រាន់តែឲ្យឈប់បង់ប្រាក់វិភាគទានប្រចាំខែប៉ុណ្ណោះ ។

ជ– មហាប៊ូ-ប៉ូ នៅជាកុមារ១៣ឆ្នាំ បួសជាសង្ឃ ៣ឆ្នាំ ធ្វើជាយកវ៉ាសតាមផ្លូវការ ៣១ឆ្នាំ បូករួមត្រូវជា៤៧ឆ្នាំ ។ លំដាប់ពី៤៧ឆ្នាំនេះមក មហាប៊ូ-ប៉ូ នៅទំនេរលែងប្រកបអាជីវកម្មអ្វីទៀត ព្រោះខ្លួនចាស់ជរា បានប្រគល់ផ្ទះនិងមរតកទាំងអស់ ឲ្យកូនច្បងកាន់កាប់ចំនួស ព្រោះកូននេះទទួលបន្ទុកចិញ្ចឹមគ្រួសារទាំងអស់ និងបង់ពន្ធដាជូនរាជការគ្រប់មុខ ។ សព្វថ្ងៃនេះ គ.ស. ១៩៦៦ មហាប៊ូ-ប៉ូ បានអាយុ ៦៥ ឆ្នាំ ហើយនៅមានស្មារតីមាំមួននៅមានកម្លាំងអាចដើរទៅណាបាន នៅជួបជុំប្រពន្ធកូនទាំង ៤ នាក់ក្នុងផ្ទះជាមួយគ្នា ។

ជីវប្រវត្តិរបស់ ប៊ូ-ប៉ូ សង្ខេបតែប៉ុណ្ណោះ

# រឿងសាមកុក

ចាកញ៉ាវិបុលភពសោធា

ឆ្ល កាឧ

ប្រែ-រៀបរៀង

(៣)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកភាងវៃឆ្លាតបើបានអាន<br>នឹងចេះទាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ |
| — យូរ-អ៊ុន — |

## សាមកុក ខ្សែ ៦៦

តាំងពីព្រះចៅស៊ុនគួន ឲ្យយកខ្លួនឡុកស៊ុនមកតាំងជាមេកងធំ ត្រួតលើនាយទាហាន ទឹងលើកទ័ពទៅតនឹងព្រះចៅឡេវពី ។ បាញ់ទ័ពឡុកស៊ុន ព្រះចៅចូកីលើកទ័ពមកច្បាំងទៀត ក៏បាញ់ទ័ពស្រុកកាំងតាំង ។

---

ព្រះចៅស៊ុនគួន បានទ្រង់ព្រះសណ្ដាប់ញាប់ញ័រព្រះទ័យក័យពាល់ តែស្ងួតព្រះកាយាមិនបានតបថាប្រការម្ដេច កាំចេកទីប្រឹក្សាទូលថា មានមនុស្សម្នាក់ល្អណាស់នៅក្នុងស្រុកយើងនេះ ហេតុម្ដេចថាទ្រង់មិនយកមកប្រើឲ្យធ្វើពជការ ព្រះចៅស៊ុនគួនត្រាស់សួរថា នរណានោះ កាំចេកទូលថា ឡុកស៊ុននៅស្រុកកេងជីវ ទូលបង្គំយល់ឃើញថាមានតម្រិះ

ប្រាជ្ញាប្រហែលនឹងដីវយើ កាលគ្រាយើងទៅវាយយកស្រុកកេងដីវនោះ ឡុកស៊ិនក៏បានជួយរិះគិតផងទើបបានស្រុកកេងដីវ សូមឲ្យទ្រង់យកមកធ្វើការចុះ បើមិនឈ្នះព្រះចៅឡាវតីទេ ឲ្យធ្វើទោសទូលបង្គំជាខ្ញុំចុះ ។

ព្រះចៅស៊ិនឆ្អូងបានឮដូច្នោះក៏ពេញព្រះទ័យណាស់ត្រាស់ថា ខ្ញុំគួរនឹកមិនឃើញទៀត ទៀវទូលថា ឡុកស៊ិននោះជាមនុស្សតូចទាប ធ្លាប់ធ្វើរាជការតែការឯណាតិចតួច ដែលនឹងយកមកធ្វើការធំតប្រាំងនឹងព្រះចៅឡាវតីនោះមិនកើតទេ កោះយ៉ុងឆ្លើយឡើងទៀតថាឡុកស៊ិននោះជាមនុស្សតូចទាបណាស់ អាយុក៏នៅក្មេងសេចក្ដីគំនិត មិនទាន់ចេះគិតធ្វើការធំ នឹងយកមកបន្ទុំឲ្យកាន់ការជានាយកលើគេចាស់ទុំមិនសមគួរ គេក៏គង់នឹងមិនស្ដាប់ ។

ថៅជិតទូលថា ឡុកស៊ិននោះជាមនុស្សក្មេងណាស់ ទោះបីនឹងចេះដឹងយ៉ាងណាក៏ធ្វើបានតែត្រឹមក្រុមការប្រុកតូចតាច នឹងលើកឲ្យមានអំណាចពេញទីជាមេកងទ័ពបង្គាប់បញ្ជាលើទាហានដូចម្ដេចបាន កាំប៉េកស្រែកថាបើមិនយកឡុកស៊ិនចូលបកធ្វើរាជការគ្រានេះទេ ស្រុកកាំងតាំងនឹងខូចជាប្រាកដហើយ បើអស់អ្នកកាល់គ្នាយល់ថាឡុកស៊ិនមិនល្អទេ ខ្ញុំនឹងកិរិយាបុត្រ សូមទទួលធានាថា បើឡុកស៊ិនធ្វើមេទ័ពទៅច្បាំងចាញ់ព្រះចៅឡាវតីវេលាណា សុំឲ្យយកខ្លួនខ្ញុំនឹងកិរិយាបុត្រទៅកាត់ក្បាលទាំងអស់គ្នាចេញចុះ ។

ព្រះចៅស៊ិនគួនបានទ្រង់ព្រះសណ្ដាប់ច្បាស់ត្រាស់ថា អស់អ្នកពល់គ្នា កុំប្រកែកគ្នាថ្វី ឡុកស៊ិននោះខ្ញុំបានស្គាល់ច្បាស់ ត្រូវចិត្តខ្ញុំណាស់ហើយៗ ក៏ត្រាស់បង្គាប់ឲ្យៈទៅហៅឡុកស៊ិនចូលមកគាល់ បំរើក៏ចេញទៅហៅឡុកស៊ិនឯស្រុកកេងជីវ លុះមកដល់ៈហើយក៏ចូលទៅគាល់ព្រះចៅស៊ិនគួន ឡុកស៊ិនក្រាបថ្វាយបង្គំហើយក៏នៅស្ងៀម ព្រះចៅស៊ិនគួនក៏ប្រស្រ័យសាកសួរតាមគួរសមថាខ្លួនអ្នកមានសតិបញ្ញាល្អមែន តែយើងមិនបានចាប់ភ្លឹកនឹកឃើញសោះក៏ភ្លេចអស់ទៅ នេះហាក់ជាកាំចេកនឹកនិយាយឡើងបានជាយើងនឹកឃើញឲ្យទៅអញ្ជើញអ្នកមក ដើម្បីសុំឲ្យអ្នកជួយទំនុកបំរុងស្រុកទេស ព្រោះវេលានេះព្រះចៅឡៅពីលើកទ័ពមកញាំញីជាចលាចល សុំឲ្យអ្នកជួយទប់ទល់ធ្វើជាមេកងទ័ពបង្គាប់បញ្ជាលើសេនាពាហាន នឹងបានតស៊ូនឹងព្រះចៅឡៅពីគ្រានេះ ។

ឡុកស៊ិនទូលថា អស់លោកជាសេនាបតីធំៗ ក៏មាននៅជួបជុំពេញក្នុងស្រុកកាំងតាំងសឺងតែជាខ្ញុំរាជការចាស់ ទូលបង្គំជាខ្ញុំនៅក្មេងណាស់ ទាំងសតិបញ្ញាក៏ពុំសូវប៉ិនប្រសប់ផង ព្រះចៅស៊ិនគួនត្រាស់ថា បើក្រែងអស់នាម៉ឺនធំៗឬនាយទ័ពនាយកទាំងពួងនឹងរឹងទទឹងមិនស្ដាប់បង្គាប់បញ្ជា យើងនឹងឲ្យគ្រឿងជាអាជ្ញាសិទ្ធិលើអ្នកកាន់ ប្រសិនបើឈ្មោះណារឹងទទឹងពុំស្ដាប់ឲ្យអ្នកកាប់ផ្ដាច់ក្បាលតាមអំណាចចុះ ឡុកស៊ិនទូលថា ទ្រង់នឹងប្រោសប្រទានឲ្យទូលព្រះបង្គំជាខ្ញុំមានយសដូច្នោះហើយ ព្រឹកស្អែកនេះ សូម

ឲ្យទ្រង់ហៅអស់នាម៉ឺនធំតូចមកក្រាបបង្គំគាល់ទាំងអស់គ្នា រួចសឹមទ្រង់ប្រទានគ្រឿងអាជ្ញាសិទ្ធិឲ្យទូលបង្គំជាខ្ញុំ ចំពោះមុខអស់លោកកល់គ្នាតាមការចុះ កាំបេកទូលថា ប្រវេណីអំពីបូរាណដែលទឹងតាំងមេទ័ពធំឲ្យបង្គាប់បញ្ជាលើទាហាននោះ ត្រូវតែព្រះរាជទានឲ្យអ្នកនោះឡើងអង្គុយលើទីខ្ពស់ឧត្តមសមគួរហើយ ទើបប្រគល់ត្រាអាជ្ញាសិទ្ធិសម្រាប់ខ្លួនឲ្យនាម៉ឺនទាំងក្រស្តឃើញទាំងអស់គ្នា ព្រះចៅស៊ុនគួនយល់ឃើញត្រូវ លុះវេលាយប់ទើបត្រាស់បង្គាប់ឲ្យធ្វើវទិនរបៀបរៀបតាំងមេកងទ័ព តាមទំនៀមទម្លាប់បូរាណ លុះព្រឹកឡើងត្រាស់ឲ្យប្រជុំអស់នាម៉ឺនតូចធំទាំងប៉ុន្មានមានឡុកស៊ុនជាប្រធាន ហើយព្រះចៅស៊ុនគួនក៏ឲ្យអញ្ជើញឡុកស៊ុនឡើងអង្គុយលើទីកន្លែងមេទ័ព ហើយក៏ប្រកាសព្រះរាជទានអាជ្ញាសិទ្ធិ គឺប្រគល់គ្រឿងទាំងត្រាគ្រឿងឧបភោគបរិភោគ សម្រាប់ឥស្សរិយយសមេទ័ពធំកណ្ដាលទីប្រជុំនៃសេនាបតីនាម៉ឺនមុខមន្ត្រីទាំងពួងស្រេចហើយ ត្រាស់ឲ្យឡុកស៊ុននិយាយត្រួតត្រារាជការលើខេត្តខណ្ឌនានា បើអ្នកឯណារឹងទទឹងពុំស្ដាប់បង្គាប់ឲ្យសម្លាប់តាមអាជ្ញាសិទ្ធិការរណរង្គសង្គ្រាម កុំឲ្យគេតញ្ញើតឡើយ ។

ឡុកស៊ុនបានទទួលយសជាមេទ័ពធំហើយក៏កាន់គ្រឿងដើរចេញទៅ ទើបបង្គាប់ស៊ីសេង, តេងហេងជានាយកងស្ដាំឆ្វេង ឲ្យប្រុងប្រៀបរៀបពលយោធា ទាំងទ័ពគោកទ័ពទឹកឲ្យព្រមព្រៀង យើងលើកចេញទៅវេលា

នេះ នោះស៊ីសេនទិនតេនហានក៏ចេញទៅចាត់ចែងកងទ័ពសព្វគ្រប់ប្រការ រួចស្រេចកាលណាក៏ចូលទៅជំរាបឡុកស៊ុន ។ ក៏ចេញទៅត្រួតមើលហើយ លើកចេញទៅ ឯហាន់តុងនិងជីវថាយដែលនៅក្រោយបន្ទាយខាងក្រៅ លុះដឹងថាព្រះចៅស៊ុនគួនតាំងឡុកស៊ុនជាមេកងទ័ពធំ លើកមកក៏និយាយ ថាបណ្ដានាម៉ឺនក្នុងស្រុកកាំងតាំងនោះអស់ហើយឬ បានជាស្ដេចយើងទៅ យកឡុកស៊ុនក្មេងប្រម៉ក់ឲ្យធ្វើជាមេទ័ពធំលើកចេញមក នឹងមិនខូចរាជការ ទៅហើយហ៎ះ! ចរចាគ្នាមិនទាន់ផុតមាត់ ទទួលឡុកស៊ុនលើកទ័ពទៅ ដល់ នោះឡុកស៊ុនបានក្រឡេកទៅឃើញអាការៈនិងកិរិយានៃហាន់តុង, ជីវថាយនូវអស់ទាហានទាំងឡាយ មិនសូវគោរពក្រែងរអែងខ្លាចខ្លួនជាមេ កងធំ ក៏ឲ្យបំរើទៅហៅហាន់តុង,ជីវថាយនូវអស់នាយទ័ពនាយកងទាំងពួង មកជួបជុំប្រឹក្សាការសង្គ្រាម ឡុកស៊ុនក៏កាន់គ្រឿងអាជ្ញាសិទ្ធិឈរស្រែកប្រ- កាសថាព្រះចៅស៊ុនគួន បានទ្រង់ព្រះរាជទានយសឲ្យយើងឡើងជាមេទ័ព ធំហើយដែលយើងលើកទ័ពមកនេះ ដើម្បីនឹងបង្គាប់បញ្ជាលើនាយទ័ព នាយកងពលគ្នាឲ្យទទួលស្ដាប់ បើអ្នកឯណាធ្វើការបានល្អក៏នឹងឲ្យបំណាច់ រង្វាន់យ៉ាងខ្ពស់ បើអ្នកឯណាធ្វើខុសក៏ត្រូវចុះទោសយ៉ាងសហ័សពុំត្រា ប្រណីឡើយ បើនរណាហើយបានយល់ការដោយប្រការឯណា ៗ ជាផ្លូវ ចំរើនក៏ជាសំគៀនសតិយើងចុះ យើងមិនប្រកាន់យកខុសទេ អស់ បណ្ដាទាហានក៏ស្ងៀម ។

ដីវថាយនិយាយនិងឡុកស៊ុនថា ស៊ុនហ៊ួនជាក្មួយព្រះចៅស៊ុនគួនតាំង ទ័ពទៅស្រុកអ៊ីឡេង ឥឡូវព្រះចៅឡៅតីឲ្យទ័ពស្រុកនោះនៅក្នុងចំណោម មនុស្សដៃ នៅក្នុងស្រុកនោះក៏អត់ស្បៀងអាហារ ខាងក្រៅស្រុកនោះក៏គ្មានអ្នកណានឹងលើកទៅជួយបាន សូមអញ្ជើញលោកលើកទៅជួយ ដោយសតិបញ្ញាក្លាហានឲ្យបានស៊ុនហ៊ួនរួចចេញមក ដើម្បីឲ្យចៅហ្វាយនាយរបស់យើងសប្បាយព្រះទ័យ ហើយនិងកែខគិតធ្វើការតទៅទៀត ឡុកស៊ុនថា ស៊ុនហ៊ួននោះជាមនុស្ស មានអធ្យាស្រ័យដឹងប្រណីសង្គ្រោះអស់ពលទាហាន មានគេរាប់អានស្រឡាញ់ច្រើន ទាំងសេនាទាហានក៏មានមនុស្សល្អច្រើននាក់ អាហារស្បៀងនៅក្នុងស្រុកក៏បរិបូណ៌មិនទាន់ខ្វះខាតទេ គេមិនទាន់ជាអ្វីនៅឡើយ បើយើងវាយទ័ពព្រះចៅឡៅតីបែកហើយ ស៊ុន-ហ៊ួនក៏គង់នឹងរួចឯងមិនបាច់ទៅជួយ ដីវថាយនិងទាហានទាំងពួងឮឡុកស៊ុនថាដូច្នោះក៏នាំគ្នាបែរមុខញញឹម ហើយក៏លាថយទៅក្រៅ ។

ហានតុងនិយាយនិងដីវថាយថា ព្រះចៅស៊ុនគួនតាំងឡុកស៊ុនឲ្យមកធ្វើជាមេទ័ពធំដូច្នេះ ស្រុកកាំងតាំងគង់នឹងខូចជាប្រាកដ ដីវថាយថា ខ្ញុំស្តាប់មើលគំនិតប្រាជ្ញាដែលឡុកស៊ុននិយាយការនឹងខ្ញុំថ្ងៃនេះ មុខជានឹងខូចរាជការដូចពាក្យអ្នកថាជាប្រាកដមែនណាស់ ឯឡុកស៊ុននោះ លុះវេលាព្រឹកឡើងក៏ឲ្យប្រជុំនាយកងនាយទ័ពមកព្រមគ្នា ហើយបង្គាប់ថា បើព្រះចៅឡៅតីលើកមកតតាំងចំបាំងនឹងយើង ១ មិនត្រូវចេញទៅតទល់ទេ

ត្រូវតែនៅក្រោបន្ទាយពាំងកុងប្រុងប្រយ័ត្នឲ្យមាំមួនចុះ នោះអស់នាយទ័ពនាយកងពួកឡុកស៊ុនថាដូច្នោះ ក៏នាំគ្នាសើចធ្វើហាក់ដូចមិនយកចិត្តទុកដាក់សោះ ហើយបបួលគ្នាលាថយចេញទៅ កាលដែលបង្គាប់ទាំងប៉ុន្មានក៏មិនបានទឹងធ្វើតាម ឡុកស៊ុនដឹងថា ពួកនាយកងនាយទ័ពមិនទទួលស្តាប់បង្គាប់ទឹងប្រុងប្រៀបរៀបធ្វើបន្ទាយ ដោយសេចក្តីមិនគោរពក្រែងវែងខ្លាចសោះលុះព្រឹកឡើង ក៏ឲ្យហៅនាយកងនាយទ័ពទូវទាហានទាំងពួងចូលមកប្រជុំព្រមគ្នា ហើយនិយាយថាខ្ញុំបានបង្គាប់អស់អ្នកទាំងឡាយឲ្យរៀបធ្វើបន្ទាយពាយចំរូងជីកគូធ្វើស្នាមភ្លោះ ដើម្បីនឹងការពារក្រោខ្លួនឲ្យមាំមួនកុំឲ្យចេញតទឹងសត្រូវធ្វើ ហេតុអ្វីអស់អ្នកមិនទៅតាមបង្គាប់យើងជាមេទ័ពដូច្នេះ ។

ហាន់តុងឆ្លើយថា ខ្ញុំបាទជាជាតិទាហានមានចិត្តស្រឡាញ់ព្រះចៅស៊ុនគួន បានបម្រើតាមទៅច្បាំងគ្រប់អន្ទើមិនខ្លាចសេចក្តីស្លាប់ វេលានេះលោកបានតាំងជាមេកងទ័ពចេញមកបង្គាប់បញ្ជានឹងធ្វើសង្គ្រាម តទឹងព្រះចៅឡៅពី ដែលលោកមកបង្គាប់ឲ្យតាំងទីនៅតែក្នុងបន្ទាយកុំឲ្យចេញច្បាំងនោះ លោកនឹងយកទ័ពតាមកជួយឬ ទាហានទាំងពួងឮដូច្នោះក៏ស្រែកឡើងព្រមគ្នាថា ហាន់តុងនិយាយត្រូវណាស់ យើងទាំងអស់នឹងសុំចេញច្បាំងមិនខ្លាចស្លាប់ទេ ឡុកស៊ុនឮហាន់តុងនឹងភាហានទាំងពួងថាដូច្នោះក៏ខឹងណាស់ ហូតគ្រប៉ីកាន់លើកឡើងហើយថា តោះបី

ខ្លួនយើងនៅក្នុងយ៉ាងណា វេលានេះព្រះចៅស៊ិនគួនព្រះរាជទានអាជ្ញាសិទ្ធិឲ្យយើងធ្វើមេទ័ពបង្គាប់ប្រើក្បាលអ្នកពល់គ្នាហើយត្រូវតែស្តាប់ បើនរណាល្មើសនឹងបង្គាប់មិនស្តាប់ពាក្យយើង ។ នឹងឲ្យកាត់ក្បាលនឹងផ្ទៃគ្រប់នេះ ទាហានទាំងអស់បានឮក៏នឹកក្នុងចិត្ត មិនដឹងនឹងគិតគបធ្វើយ៉ាងណា នាំគ្នាដើរចេញទៅធ្វើបន្ទាយកាយចំរូងដីកគូធ្វើស្នាមក្លោះជាមួនមាំប្រចាំយាមល្បាតលាតក្រវែលតាមបង្គាប់គ្រប់ប្រការ ។

ឯព្រះចៅឡាវពីនោះ លុះសែនពីការទៀវហ៊ុយរួចស្រេចកាលណាក៏ត្រាស់បង្គាប់នាយទ័ពនាយកងឲ្យតាំងបន្ទាយកាយផាល់ជាប់គ្នា តាំងពីដំបន់អ៊ូតេងវៀងទៅដល់ដំបន់ឈួនខៅចម្ងាយ ១.០០០សិន (៤០គី.) ចំនួន ៤០បន្ទាយ មានទាហានល្បាតនាំយកសេចក្តីទៅក្រាបទូលព្រះចៅឡាវពីថា ព្រះចៅស៊ិនគួនតាំងឡុកស៊ិនជាមេកងទ័ពធំនាំពលមកតាំងបន្ទាយកាយប្រទល់រៀបគ្នា ហើយហាមប្រាមពួកយោធាមិនឲ្យចេញចំបាំង ព្រះចៅឡាវពីបានទ្រង់ព្រះសណ្តាប់ ក៏ទ្រង់សង្ស័យណាស់ត្រាស់ថា ឡុកស៊ិននោះ នៅឯណា វាជាយ៉ាងម្តេច ម៉ាលៀងទីប្រឹក្សាថា ឡុកស៊ិននោះជាមនុស្សចំណុះស្រុកឆម្នា ទីលំនៅវានៅស្រុកកេងដីវ នៅក្មេងណាស់ តែបានរៀនសូត្រធ្វៀវឆ្លាស់ប្រតិពលយល់ការជ្រៅទូលាយ ប្រហែលនឹងដីវយ៉ីស្រុកកេងដីវខូចអន្តរាយក៏ព្រោះឧបាយប្រាជ្ញាវាដែងនេះ ។

ព្រះចៅឡៅពីទ្រង់ព្រះសណ្ដាប់ច្បាស់ ក៏ទ្រង់ព្រះក្រោធធំណាស់ ត្រាស់ថា តម្រិះប្រាជ្ញាអាដែងនេះហើយដែលកាសម្លាប់ជីវិតប្អូនអញ ល្អហើយជាបុណ្យអញនាំឲ្យមកបានសងសឹកគ្នា អញនឹងលើកពលយោធាទៅវាយទំលាយបន្ទាយវក្នុងថៃនេះ ម៉ាលៀងទូលថា ឡុកស៊ុននេះទូលព្រះបង្គំជាខ្ញុំស្គាល់បានថាមានតម្រិះប្រាជ្ញាជាជាងជីវយើ សូមឲ្យទ្រង់បង្អង់កុំអាលចូលច្បាំង សូមទ្រង់ព្រះតំរិះមើលសិនចុះ ព្រះចៅឡៅពីខ្ញាល់ណាស់ត្រាស់ថា យើងធ្វើសង្គ្រាមមកក៏ច្រើនណាស់ហើយ តាំងពីកំឡោះលុះដល់ចាស់ជរ មិនខ្លាចអ្វីដែលអាឡុកស៊ុនក្មេងពីម្សិលមិញក៏នឹងជាយ៉ាងណាជាងយើង ត្រាស់ហើយក៏បង្គាប់ទាហានឲ្យបង្ខំលើកទ័ពចេញទៅ ឯហាន់តុងនឹងជីវថាយដែលរក្សាបន្ទាយនៅនោះ លុះដឹងថាព្រះចៅឡៅពីលើកទ័ពមក ក៏ប្រើទាហានឲ្យទៅដំរាបឡុកស៊ុន ៗ ក័យណាស់ក្រែងទាហានទាំងនោះមិនស្ដាប់នឹងប្រញាប់ចេញច្បាំង ទើបឡើងសេះលេះលាំងចេញទៅមើល ប្រទះនឹងហាន់តុងឈរនៅក្នុងបន្ទាយលើកំពូលភ្នំ ៗ

ហាន់តុងក្រឡេកទៅឃើញទាហានលើកមកច្រើនណាស់ ជាន់កណ្ដាលនោះទាហានកាន់សុទ្ធតែទង់លឿង ទើបចង្អុលប្រាប់ឲ្យឡុកស៊ុនមើលថា នោះព្រះចៅឡៅពីលើកមកឯង យើងនឹងស្ងៀមនៅថ្វី ត្រូវតែចេញច្បាំងឲ្យជិតដៃគ្នា ហើយនឹងចាប់យកខ្លួនព្រះចៅឡៅពី ឲ្យបាន

ឡុកស៊ិនថា ព្រះចៅឡៅពីនោះប៉ិន ស្ទាត់គុនក្បួនពិជ័យសង្គ្រាមណាស់ រមែងចំបាំងឈ្នះគេមកច្រើនហើយ ពួកសេនាទាហានក៏មានចិត្តខ្លាំងពូកែណាស់ អ្នកទាំងនេះចេញទៅប៉ះម្ដេចបាន ចូរកែះអានគិតតែរក្សាបន្ទាយឲ្យមាំសិនចុះ បើទាហានខាងគេលើកមកទៀតហាត់ដោយកំដៅទីងថ្ងៃ គេឈប់សម្រាកក្បែរភ្នំទីងម្លប់ឈើធំវេលាណា សឹមយើងគិតការចេញចំបាំងតែម្ដង ហាន់តុងបានឮដូច្នោះក៏មិនយល់ឃើញផងសោះ តែទាល់គំនិតណាស់ ព្រោះខ្លាចក៏ស្ងៀមទៅ ។

ព្រះចៅឡៅពីឃើញទាហានស្រុកកាំងតាំងមិនចេញចំបាំងសោះ ក៏បង្ខំទាហានទាំងអស់ ឲ្យព្រួតគ្នាចូលទៅស្រែកជេរដល់មាត់ទ្វារបន្ទាយឡុកស៊ិនព្រមហើយក៏បង្គាប់ទាហានទាំងឡាយថា ឲ្យខំអត់សង្កត់ចិត្តគិតតែយកក្រដាសចុកត្រចៀកទៅសិនចុះ នោះព្រះចៅឡៅពីដែលប្រើទាហានឲ្យទៅស្រែកជេរដល់ទ្វារបន្ទាយហើយ ទាហានស្រុកកាំងតាំងមិនចេញចំបាំងសោះ ក៏ទ្រង់ឈឺក្ដៅព្រះឧរាពន់ប្រមាណ ។ ម៉ាលៀងទូលថា ឡុកស៊ិននោះមានគំនិតគិតជ្រៅណាស់ បានជាយើងប្រើមនុស្សឲ្យទៅជេរ គេមិនចេញមកចំបាំង មុខជាវាទំនងធ្វើឲ្យយើងភាន់ភាំងធ្វេសទុកចិត្ត សូមទ្រង់ព្រះតំរិះគិតមើលឲ្យល្អសិនចុះ ព្រះចៅឡៅពីត្រាស់ថា សេចក្ដីគិតវាទីងមានអាការយ៉ាងណា វាធ្លាប់តែចាញ់យើងទើបមិនចេញមុខមកចំបាំង ឃើញថាវាខ្លាចយើងពិតមែន ។

ប៉ិនស៊ិបទើបទូលថា យើងលើកទ័ពមកពេលនេះ ជាទេសកាលរដូវក្តៅ ទឹងអាស្រ័យម្លប់ឈើក៏មានតិច ទឹងរកទឹកក៏នៅឆ្ងាយណាស់ ល្តឹកណាបើមានពលការប្រទ័ពលើកមក ទឹងយកធុរៈមិនបានឆាប់រហ័ស ក្លាយ ៗ ព្រះចៅឡៅតីទ្រង់ព្រះសណ្ដាប់ក៏យល់ឃើញត្រូវ ទើបត្រាស់ថា យើងត្រូវតែថយទ័ពត្រឡប់ទៅវិញ ក៏តាំងបញ្ឈប់ទ័ពនៅក្បែរមាត់ទឹក ទឹងក្រោមម្លប់ឈើ ដើម្បីឲ្យទាហានបានសម្រាកកម្លាំង ចាំកំហួសពេលក្តៅ វេលាណាស៊ីមលើកមកតតាំងម្តងទៀត ម៉ាលៀងទូលថា ដែលទឹងថយទៅបញ្ឈប់ នៅក្បែរមាត់ទឹកទឹងម្លប់ឈើនោះជាស្រួលណាស់ហើយ តែខ្លាចក្រែង ឡុកស៊ុន ឃើញថាយើងថយទ័ព ពាក់ទឹងត្រឡប់លើកគំហុករុកបំពារមកលើយើង ៗ ទឹងធ្វើប្រការម្តេច ព្រះចៅឡៅតី ក៏ត្រាស់ថា បើដូច្នោះ យើងត្រូវឲ្យ ង៉ីប៉ាន់ ឃុំទាហាន ១០.០០០ ទៅតាំងនៅមាត់ផ្លូវ ដែលពាក់ទឹងលើកចេញមកនោះ ឯខ្លួនយើងទឹងឃុំទាហាន ដែលមានថ្វីដៃ ៨០.០០០ ទៅបង្កប់នៅទីច្រកភ្នំ ហើយយើងឲ្យថយទ័ពធំចេញទៅ បើឡុកស៊ុនឃើញថាយើងថយទ័ពពាក់ទឹងត្រឡប់ដេញចេញមក ឲ្យង៉ីប៉ាន់ច្បាំងតហើយធ្វើជាចាញ់ថយរត់ចេញទៅ បើបានចំណាប់វេលាណា ខ្ញុំឯងទឹងលើកទាហានសេនាចេញកាត់ចុងទ័ព ចាប់យកខ្លួនឡុកស៊ុនឲ្យបាន អស់នាម៉ឺនទឹងទីប្រឹក្សាទាំងប៉ុន្មានក៏យល់ឃើញត្រូវហើយសរសើរសេចក្តីរបស់ព្រះចៅឡៅតីណាស់ ។

ម៉ាលៀងទូលថា ខុងបេងជាអាចារ្យណែនាំនៅចាំស្រុក ព្រះអង្គទ្រង់លើកទ័ពមក ខុងបេងមិនបានមកឃើញផង ទូលព្រះបង្គំជាខ្ញុំសូមគូរជាផែនទីផ្ញើទៅឲ្យខុងបេងមើលតាមរបៀបដែលតាំងបន្ទាយនេះ ទិងត្រូវតាមក្បួនពិជ័យសង្គ្រាមដែរឬប្រការម្តេច ព្រះចៅឡៅពីទ្រង់យល់ត្រូវទើបត្រាស់ថាបើដូច្នោះឲ្យអ្នកគូរផ្ញើទៅចុះ បើខុងបេងឃើញហើយនឹងថាប្រការម្តេចអ្នកបួលសូត្រគ្រឡប់វិលមកឲ្យឆាប់ ម៉ាលៀងក៏ទៅគូរផែនទីតាមព្រះតម្រាស់ ព្រះចៅឡៅពីក៏ឲ្យថយទ័ពទៅធ្វើតាមគំនិតដែលគិតទុកនោះ ៗ

ឯហាន់តុងនិងជីវថាយដឹងថាព្រះចៅឡៅពីថយទ័ពហើយ ក៏ទៅប្រាប់ឡុកសុិនថាព្រះចៅឡៅពីតាំងបន្ទាយកាយរៀងគ្នាទៅដល់ ៤០ អន្លើហើយលើកថយទៅវិញ ខ្ញុំបាទគិតឃើញថាជាទេសកាលក្តៅណាស់ប្រ-ហែលជាទៅតាំងនៅម្លប់ឈើឬមាត់ទឹក យើងបានចំណាប់ពេញសន្ទឹកហើយនឹងសុំចេញទៅច្បាំងយកជ័យជំនះ ៗ

ឡុកសុិនបានឮដូច្នោះក៏មានអំណរណាស់ ទើបឡើងសេះលើកទាហានចេញទៅមើលឃើញតាំងនៅទ័ព១កង មានពលប្រហែល ១០.០០០ ទាហានចាស់ខ្លះក្មេងខ្លះមិនស្មើគ្នា ក៏គិតសង្ស័យហាន់-តុង, ជីវថាយថាឃើញទាហានទ័ពកងនេះមានក្មេងតិចចាស់ច្រើន ខ្ញុំបាទសូមចេញទៅច្បាំងទិងវាយឲ្យបែកទៅតែម្តង ឡុកសុិនហាមឃាត់ថា ទ័ពនេះគេតាំងទុក

(នៅមានត)

# ការស្រាវជ្រាវ

## ប្រវត្តិលោកវិសេស ដូង

របស់បណ្ឌិតមហា ឈឹម-ស៊ុម អតីតសាស្ត្រាចារ្យ

(តមក)

---

## សេចក្តីបញ្ជាក់

## ស្នាដៃក្នុងការនិពន្ធ

នៃ

លោកតាអាចារ្យ ដូង

គ) សាស្ត្រាណែនមាស ឬ សុវណ្ណពិលាប : សាស្ត្រានេះ អ្នកឲ្យការច្រើនគ្នាបានឲ្យពត៌មានដល់ខ្ញុំថា : នេនមាសមានកំណើតនៅឃុំព្រៃជ្រៃ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បួសនៅវត្តមាស ខាងត្បូងភ្នំហូពៅ ។ សាមណេរនេះជាមនុស្សកំព្រា, កាលដែលមាតាបិតាទទួលអនិច្ចកម្មអស់ទៅ, នៅតែ២នាក់នឹងប្អូនតូចមួយ មានសេចក្តីព្រួយចំពោះជីវភាពរបស់ខ្លួននិងប្អូននោះក្រៃពេក, ប៉ុន្តែជាអ្នកមានចិត្តសទ្ធាជ្រះថ្លា ចំណាយទ្រព្យធនធានជាលោហធាតុទាំងអស់ ដែលជាអម្រស់អម្រមានមកអំពីមាតាបិតា ញុំាងជាងឲ្យរំលាយបញ្ចូលគ្នាសាងបានព្រះពុទ្ធរូបសំរិទ្ធិ ២ ព្រះអង្គ

ធ្វើបុណ្យអភិសេក តម្កល់ទុកក្នុងវត្តហ្វូញ្ញោ(១)មួយព្រះអង្គ ក្នុងវត្តមាស មួយព្រះអង្គ ។

សាមណេរ មាស សុគតបាត់ទៅឥតមានជនណាដែលរស់នៅសព្វថ្ងៃបានស្គាល់ទេ, ប៉ុន្តែគេដឹងតៗគ្នាមកថា: សាមណេរនេះ បានសូមឲ្យលោកគ្រូអាចារ្យជួនតែងកាព្យថ្លែងពីសេចក្តីកំសត់របស់ខ្លួន ។ ហេតុដូច្នេះបានជាកំណាព្យនោះ បានឈ្មោះថា«សាស្ត្រានេនមាស» ។ សាស្ត្រានេះជួនកាលលោកអ្នកចារបានដាក់ចំណងជើងថា «សាស្ត្រាសុវណ្ណពិលាប» ដូច្នេះក៏មាន , មានចំនួនប្រហែលជាង១០សន្លឹកស្លឹករឹត រាប់រៀបអំពីបណ្តាំមាតាបិតាមុនគ្រាអនិច្ចកម្មថា ឲ្យថែទាំប្អូន ឲ្យនាំប្អូនលេងតែដោយដីកុំបីឡើងឈើ..., អំពីល្បែងក្មេងនៅស្រុកស្រែ, ទេសភាពវាលស្រែនិងព្រៃរបោះ ៗ មានដើមព្រីង ដើមត្រៀលស្វា ត្រៀលដោះក្របី ដែលជាចំណីនៃក្មេងគង្វាលគោ, ជាកំណាព្យគួរឲ្យសែនស្រណោះក្រៃពេក មានបទព្រហ្មគីតដូចឃ្លាថា :

ឱព្រីងដោះក្របី ផ្លែទុំខ្ចីជ្រុះរាត់រាយ

---

(១) ព្រះពុទ្ធរូបដែលលោកតម្កល់ទុកក្នុងវត្តហ្វូញ្ញោ មានជនច្រើនគ្នាដែលរស់នៅសព្វថ្ងៃធ្លាប់បានឃើញថា ព្រះពុទ្ធរូបនោះ មានកំពស់ទាំងបល្ល័ង្កទាំងតួអង្គប្រហែលជាង ៣០ សង់ទីម៉ែត្រ មានអក្សរជាប់នៅខាងក្រោយបល្ល័ង្កថា នេនមាសសាង ។ ប្រហែលគ.ស. ១៩៣០ ចោរលួចយកព្រះពុទ្ធរូបនេះបាត់ទៅ ។ លោកគ្រូមហា គុប-គឹម តែងស៊ើបសួររកព្រះពុទ្ធរូបនេះរឿងរៀបមក ។

...QUE ... ORIENT



យើងនាំគ្នាប្រញាប់　　ដណ្ដើមគ្នារើសភោគា ។ល។

*មានបទកាកគតិដូចឃ្លាថា :*

ស្រណោះវាលវែង　　ដែលយើងធ្លាប់ដេង
ទៅទិសឧត្តរា　　ព្រះពាយបក់បោក
ពពកត្រៀបត្រា　　ខែមាឃមាសា
សែនស្ដាប់សូរឯក[១] ។ល។

---

(១) សាស្ត្រាសុវណ្ណពិលាបនេះ ខ្ញុំធ្លាប់មើលក្នុងកាលដែលខ្ញុំមានអាយុ ១៥ ឆ្នាំ ។ និស្ស័យរបស់ខ្ញុំក្នុងការរៀនបាលីបានផុះឡើងដោយសាស្ត្រានេះជាដើមហេតុ ។ ព្រោះថាកាលនោះ ក្នុងរដូវដែលអ្នកស្រុកច្រូតកាត់ហើយ គេតែងនិមន្តលោកទៅឆាគ្រប់ ៗ ភូមិ ។ ភិក្ខុ៣អង្គទើបបួសថ្មី ត្រូវលោកគ្រូធំចាត់ឲ្យទៅឆាភូមិអង្គសំរោង ជាលំនៅនៃជនអ្នកពុំសូវមានការចេះដឹង ។ ខ្ញុំជាក្មេងវត្ត បានតាមលោកទៅឆាក្នុងភូមិនោះ ។ ពេលលោកឆាន់ព្រឹកហើយ គេតែងប្រជុំគ្នាសាកច្ឆាធម៌ ។ អ្នកភូមិនោះគ្មាននរណាម្នាក់ចេះធម៌ល្មមសន្ទនាគ្នាបានសោះ បែរជាឲ្យខ្ញុំមើលសាស្ត្រាសុវណ្ណពិលាបនេះឲ្យគេស្ដាប់ទៅវិញ ។ ខ្ញុំមើលដល់ចុងឃ្លានេះ ខ្ញុំឈប់ ។ គ្រានោះការជជែកគ្នាមិនជាច់ស្រេចក៏កើតឡើង ព្រោះមិនដឹងថា “ទិសណាឈ្មោះទិសឧត្តរ” ។ ទើបខ្ញុំសួររកហេតុថា : គេរត់ខ្លែងត្រូវរង់ចាំបណ្ដោយខ្យល់ឬប្រាសខ្យល់ ? ឆ. ប្រាសខ្យល់ ។ ស. ខែមាឃខ្យល់បក់ពីទិសណា ? ឆ. ពីទិសខាងជើង ។ ទើបខ្ញុំប្រាប់ថា : ទិសខាងជើងហ្នឹងឯងដែលឈ្មោះថា ទិសឧត្តរ ។ គេក៏ពុំទាន់ជឿ, គេថាទិសខាងជើង ចាស់ ៗ ហៅទិសឧត្តរ ។ ខ្ញុំថា ឧត្តរ ក៏គឺឧត្តរ, ឧត្តរ ក៏គឺខាងជើង, ចាស់បុរាណសម្បូណ៌ពាក្យប្រើណាស់ របស់មួយមុខ ៗ មានពាក្យហៅបីបួនបែប, អ្នកចេះពាក្យច្រើនបែប ទើបគេហៅថា លោកអ្នកប្រាជ្ញ ។

ខ្ញុំនិយាយប៉ុណ្ណេះ ជាហេតុឲ្យអ្នកភូមិនោះជ្រះថ្លាទាំងក្មេងទាំងចាស់ ខ្លះលើកដៃសំពះខ្ញុំ ។ រឿងនេះដែលចាក់ចុចត់និតខ្ញុំឲ្យខ្ញុំចង់តែរៀនតទៅទៀត ដោយការតាំងចិត្តថា មិនព្រមល្ងង់ដូចអ្នកទាំងនោះទេ, កើតមកជាកូនខ្មែរ មិនគួរល្ងង់សព្វបើពាក្យខ្មែរទេ ។

សាស្ត្រាសុវណ្ណពិលាបនេះ លោកគ្រូអាចារ្យជួន បានតែងឡើង តាមបំណងនៃនមាសជាអ្នកសុំឲ្យតែង គ្មានអត្ថន័យប្លែកពីធម្មតាទេ គឺគ្រាន់តែជាកំណាព្យមួយ ដែលគួរឲ្យស្រណោះណាស់ប៉ុណ្ណោះ ។

ឃ) សាស្ត្រាផ្អឹកផ្គរ ឬផ្គរផ្ដាំក្ដាមខ្យង : សាស្ត្រានេះជាល្បើក ដែលលោកគ្រូអាចារ្យ ជួន ប្រឌិតលើកឡើងហាក់ដូចជាអ្នកនិពន្ធនោះ ចេះភាសាមេឃ ។ ល្បើកនេះជាកាព្យបទកាកគតិ មានពាក្យដើមថា:

ព្រហាមផ្គរផ្ទង់ ផ្គរមិនទុរជិន នឹងក្ដាមទ្បើយណា
ហាក់ដូចសាប់ញាតិ សន្ដាង់ផងគ្នា ខែចេញវស្សា
ផ្គរលាក្ដាមទៅ ។ ផ្គរមាគមេត្តា ផ្គរផ្ដាំក្ដាមថា
ត្បូទក្ដាមកម្លោ ថារុំយអស់ក្ដាម ធ្វើរន្ធឲ្យជ្រៅ
ព្រោះមនុស្សក្បាលខ្មៅ ចូលបិត្តធឹក្ដាម ។ល។

ខ្ញុំធ្លាប់មើលសាស្ត្រានេះ ក្នុងកាលអាយុ ៩ ឆ្នាំ ចាំសូត្រដោយមាត់ទទេបានខ្លះរហូតដល់សព្វថ្ងៃ ។ តមក ខ្ញុំពុំដែលបានមើលសាស្ត្រានេះទៀតទេ ។ ទោះបីដូច្នោះ ក៏ខ្ញុំអាចចាំសេចក្ដីបានថា: ពាក្យកាព្យក្នុងល្បើកនេះល្អមែនទែន គួរឲ្យតែចង់មើល, មើលហើយ ហាក់ដូចជានឹងជឿថា ផ្គរចេះភាសាក្ដាម ក្ដាមចេះភាសាផ្គរ ។ កាលណាខ្ញុំនឹកឃើញល្បើកនេះមួយដងមួយកាល ខ្ញុំតែង កោតសរសើរដល់គំនិតអ្នកនិពន្ធនេះជានិច្ច

ក្នុងកាលនោះ ។

អត្ថន័យសរុបក្នុងល្បើកនោះថា : ធាតុអាកាសនៅប្រទេសកម្ពុជា តែងប្រែប្រួលទៅតាមរដូវ ៣ ។ ជាពិសេស ក្នុងវេលាចុងវស្សានរដូវ ជិតដល់ហេមន្តរដូវ គឺក្នុងរនោចខែអស្សុជ ក្នុងវេលាព្រលឹមស្រាង មហាមេឃតែងបញ្ចេញសំឡេងផ្គរ ៗ នៅទិសអាគ្នេយ៍ ។ សូរស័ព្ទនៃមហាមេឃនេះ អ្នកស្រុកសន្មតថា "ផ្គរផ្តាំក្តាមខ្យង" ព្រោះតែកាលណាគេឮសូរផ្គរនេះ គេអាចដឹងមុនថា ប្រាកដជាអស់ភ្លៀងហើយ ។ តមក គេឮសូរស័ព្ទផ្គរធូនៗទៀត ក្នុងវេលាយប់ គេហៅថា "ទឹកអង្គរបាក់" គឺសូរស័ព្ទដែលគេឮ ក្នុងគ្រាដែលទឹកថយ ពីទន្លេសាបមកទន្លេ៤មុខវិញ (ទន្លេមេគង្គ) ។

លោកតាអាចារ្យ ដួង តែងកាព្យនេះឡើង ផ្តើមដំបូងជាពាក្យផ្គរលាក្តាមខ្យង ។ បន្ទាប់មក ជាដំបូន្មានរបស់ផ្គរចំពោះក្តាមថា : ក្នុងពេលដែលយើងមិននៅ ត្រូវក្តាមទាំងឡាយ សសៀរសសៀតត្បូលជ្រៀតកាយរន្ធឲ្យជ្រៅ ក្នុងកៀនកោះ ដែលមានឫសឈើ គល់ឈើ កន្ទៀតថ្ម គ្រួសពេន ឲ្យកើតជាទីឋានលំនៅរបស់ខ្លួន ដើម្បីកុំឲ្យមនុស្សក្បាលខ្មៅ យកស៊ីបាន ។ ដំបូន្មាននេះ ហាក់ដូចជាមហាមេឃមានមេត្តាធួទៅដល់សត្វលោកទាំងអស់ សូម្បីក្តាមជាសត្វចង្រៃ ក៏មហាមេឃអាណិតដែរ ។ ប៉ុន្តែសេចក្តីនៃរឿងនេះតទៅទៀត ហាក់ដូចជាមហាមេឃអាណិតមនុស្ស

ជាងក្តាមជាសត្វចង្រៃ ព្រោះសូរស័ព្ទផ្គរ ដែលសន្ទនាជាមួយនឹងក្តាម ទុកដូចជាបង្រៀនមនុស្សឱ្យចេះធ្វើម្ហូបដោយជាតិក្តាម ដូចត្រង់សេចក្តីថា:

– ក្តាមតូច ៗ គេគ្រាន់តែចកសម្បកខ្នងនិងសន្ទះពោះចេញ គេបុកវាទាំងស្រស់ជាមួយនឹងអំបិលអម្ពិលខ្ចី (ចិញ្ច្រាំព្រហកបន្តិចលាយផងក៏មាន) ហើយប្រតម្អមខ្ចី ៗ ធ្វើជាបន្លែផ្អាប់នឹងក្តាមបុកនោះ បរិភោគជាមួយនឹងបាយក្តៅ ៗ ឆ្ងាញ់ណាស់ ។

–ក្តាមនៅគេយកទៅបុកឲ្យល្អិតគួរសម បារពីត្បាល់មកដាក់ក្នុងចានគ្រាន់ លាយទឹកច្របាច់ស្រង់កាកចេញ យកតែខ្ទុះស្លជាមួយនឹងបន្លែននោងខ្ចី ល្ពៅខ្ចី ឬ ល្ហុងខ្ចី បង់ម្ជូរ អំបិល ព្រហក់ទិនម្អម, តែប៉ុណ្ណះក៏ឆ្ងាញ់ណាស់ទៅហើយ មិនបាច់និយាយដល់ការយកត្រី ឬ កំពិស ឬកំភ្លៅកន្ត្រៃមកស្លជាមួយផងទេ ។

–ក្តាមគ្រោង ឬ ក្តាមមេធំ ៗ នារដូវខែចម្រូតគេចាប់មកបកក្តិះយកតែខ្លាញ់ដាក់ក្នុងសម្បកវា សល់ពីនោះធ្វើម្ហូបដូចខាងលើនេះ ។ ខ្លាញ់ក្តាមដែលក្តិះដាក់ពេញសម្បកឥតលាយគ្រឿងអ្វីទេ គ្រាន់តែបង់អំបិលបន្តិចកំដៅលើរងើកភ្លើងឲ្យឆ្អិនប៉ុណ្ណោះ ។ ខ្លាញ់នោះមិនបាច់ច្រើនទេ សូម្បីតែមួយ ឬ ពីរសម្បក គេអាចប្រឡាក់នឹងបាយ សព្វបានមួយចានធំ បរិភោគឆ្ងាញ់ជាទីបំផុត ។ (ត្រង់នេះ ដែលលោកវិសេស ដូង ថា: . . . ពុំទាន់បានពម (ស្រក់ទឹកមាត់មុន) ។

— កូនក្តាមតូចៗ គេបកសន្ទុះនិងសម្បកចេញ កាត់ជាពីរកំណាត់ ប្រឡាក់នឹងទឹកត្រី ផ្ទាប់នឹងអម្ពិលខ្ចី ហើយនឹងស្លឹកជីផ្សេងៗ បរិភោគទៅក៏ឆ្ងាញ់ដែរ ។

— កូនក្តាមតូចៗ គេយកមកបកសន្ទុះនិងសម្បកចេញ ប្រឡាក់ដោយទឹកស៊ីអ៊ីវផ្អែម ឬស្ករត្នោតនឹងទឹកអំបិល ល្មមចូលរសជាតិផ្អែមប្រៃគួរសមហើយបស្រង់មកប្រឡាក់ខ្លាញ់ជ្រូក លីងក្នុងខ្ទះឲ្យស្រួយ ក៏បរិភោគឆ្ងាញ់គ្រាន់បើដែរ (អ្នកស្រុកកំពតចូលចិត្តធ្វើម្ហូបក្តាមបែបនេះ) ។

—មិនត្រឹមតែអ្នកស្រែទេ, អ្នកក្រុងដែលសម្បូណ៌ម្ហូបពោរពាស ក៏អ្នកខ្លះចូលចិត្តបរិភោគក្តាមប្រៃដែរ ទោះបីមានក្លិនស្អុយ ក៏គេអាចលាយម្ជូរ លាយស្លឹកជីផ្សេងៗ បរិភោគបានដែរ, ប៉ុន្តែគេចូលចិត្តទិញតែក្តាមប្រៃពីកំពត គឺក្តាមសមុទ្រ ។ អ្នកកំពតដែលចេះធ្វើក្តាមប្រៃថា: ក្តាមស្រែឆ្ងាញ់ជាងក្តាមសមុទ្រទៅទៀត ។ (គួរពិចារណាផងចុះ) ។

(ម្ហូបក្តាមនេះ ខ្ញុំសរសេរដោយការផ្សែផ្សំ ព្រោះខ្ញុំចាំពាក្យកាព្យក្នុងសាស្ត្រាផ្គរផ្តាំក្តាមខ្សែពុំសព្វគ្រប់, ចាំតែគោលសេចក្តីប៉ុណ្ណោះ) ។

ល្បើកផ្គរផ្តាំក្តាមខ្សែនេះ ប្រហែលជាអ្នកនិពន្ធចង់ឲ្យសាធារណជនដឹងនូវធម្មតាលោកថា: ឧកាសលោក គឺ ទឹក ដី ភ្លើង ខ្យល់ ដែលមានមេឃជាធំ ក៏ដូចគ្នានឹងមនុស្សលោក ដែលមានមេបាមួយជាធំដូច្នោះដែរ។ មេឃក្តី មេបាជាធំក្តី មានក្តីអាណិតអ្នកតូចទូទៅទាំងអស់, ប៉ុន្តែអ្នកតូច

ដែលទិលខូចបំផ្លិចបំផ្លាញគេ, នោះត្រូវវិនាសដោយសំដី គឺច្បាប់ដ៏សុច-
រិតរបស់អ្នកគ្រប់គ្រង, ដូចជាក្ដាមជាទីអាណិតរបស់មេឃក៏ពិតមែន, ប៉ុន្តែ
ក្ដាមចង្រៃពេក ទើបត្រូវវិនាសដោយសំដីមេឃដូច្នោះ ។

ង) ល្បើកអក ល្បើកនេះតាមចាស់ៗអ្នកឲ្យពត៌មានដល់ខ្ញុំថា
ប្រាកដជាលោកគ្រូអាចារ្យដូង បានតែងលើក្នុំដ៏សុរ ក្នុងគ្រាដែលទៅក្រាំ
ដម្បីលោកតាហ៊ុនមែន ។ ប៉ុន្តែចាស់ទឹងមិនឃើញនាមអ្នកតែង និងកាល-
បរិច្ឆេទក្នុងល្បើកនោះសោះ ។ មានហេតុមួយ ដែលនាំឲ្យអ្នកស្រាវ
ជ្រាវមានគំនិតទទឹសទទាស ។ ហេតុនោះគឺ: រឿងអកញីឈ្មោលនេះ
មានពីរបែប គឺ មួយបែបខ្លី មួយបែបវែង ។ បែបខ្លី មានចំណងជើងថា
ល្បើកអក, បែបវែងមានចំណងជើងថាសាស្ត្រាអក ។ បែបខ្លីចប់ត្រឹម
អកញីបោះពួយៗម្នាក់ខ្លួនស្លាប់ ហើយតមកអកឈ្មោលក៏ដូច្នោះដែរ ។
បែបវែងពីខាងដើមមកដូចគ្នានឹងបែបខ្លី, តពីអកញីឈ្មោលទាំងពីរបោក
ខ្លួនស្លាប់ទៅ អកញីទី២ ដែលនៅមាត់បឹងខំប្រឹងហើររកអកឈ្មោលជាគូ
សង្សារ ទៅជួបនឹងបក្សីឯទៀតៗដ៏ច្រើន, ខ្លះគេជួយអាណិត ខ្លះគេចំអក
ឡកឡឺយឲ្យ ខ្លះគេរិះគន់និន្ទាធ្វើឲ្យអកញីនោះមានការអាម៉ាស់មុខយ៉ាង
ខ្លាំង, ដល់ទីបំផុត អកញីនោះ បានជាគូសង្សារនឹងសត្វទទុយឈ្មោល
ពោះម៉ាយ ដែលទទុយញីជាប់អន្ទាក់ស្លាប់ចោលទៅ ។ ទទុយឈ្មោល
និងអកញី (ពោះម៉ាយមេម៉ាយ) ទាំងពីរ ស្គារគ្នាលើចុងឈើតាល ជាន់

គ្រោបគ្នាជាប់ រហូតដើនធ្លាក់មកដល់ដីស្លាប់ទាំងពីរ ហើយៈទៅកើតជាសត្វប្រវឡាំងកាស ឱបគ្នាជាប់ជានិច្ច ៗ អ្នកនិពន្ធនោះ បែរមកសរជាតិថា: សត្វអកញីឈ្មោលនៅក្នុងដីស្ងួរ ដែលស្លាប់ខ្លួនព្រោះកំហុសនៃអកឈ្មោល អនោះលៈទៅកើតជាសត្វក្បាំង ត្រូវក្បាំងញីដាក់ទណ្ឌកម្មវិញ ឲ្យក្បាំងឈ្មោលនៅក្រោបពងគ្រងស្អិតក្នុងរន្ធឈើ ដែលក្បាំងញីយកដីស្អិតមកបិទមិនឲ្យចេញរួច ហើយទៅស្វែងរកអាហារមកបញ្ចុកតាមរន្ធតូចដែលខ្លួនបិទមិនឲ្យជិតទុកគ្រាន់តែបញ្ចុកអាហារ ៗ

ក្នុងទីបំផុតនៃសាស្ត្រាអកបែបនេះនោះ មានដាក់ឈ្មោះអ្នកពឹងគេឲ្យតែងថា :

ចៅព្រាំញាំងពឹងឲ្យគេលើក ជាល្បើកនេះឯងក្រៃអ្នកស្រុក
អ្នកស្រែបំការណាអផ្សុក រិតក្តិកក្តួនគឹកប្រពន្ធ ៗលៗ

ហើយមានទាំងឈ្មោះអ្នកតែងកាព្យនោះផងថា :

រឿងនេះរិះព្រឹលមើលប្រៀនប្រាណ ប្រៀនប្រួមឲ្យបានទៅជរាប
ព្រះបំរើឪទ័យលៃលើកកាព្យ កំណាព្យកំណត់ហ្មត់ធីល្មើ ៗ

ហេតុនេះឯង ដែលនាំឲ្យអ្នកស្រាវជ្រាវខ្លះយល់ថា លោកគ្រូអាចារ្យ ឌួង តែង, ខ្លះយល់ថា លោកបំរើឪទ័យតែង ៗ ឯយោបល់ខ្ញុំយល់ថា : ប្រាកដជាលោកគ្រូអាចារ្យ ឌួង តែង បានត្រឹមមួយបែបខ្លី ហើយលោក

បំរើឧទ័យតែងបន្តទៅទៀតទៅជាបែបវែង ថែមទាំងដាក់ឈ្មោះខ្លួនផង បាត់ឈ្មោះលោកគ្រូអាចារ្យ ដួង ទៅ ។ ចំណុចដូចតទៅនេះ ដែលនាំឲ្យខ្ញុំយល់ដូចខាងលើ ៖

១– អ្នកឲ្យការច្រើនគ្នា ពីប្រភពវត្តហូព្នៅ វត្តលេទតែន ភូមិព្រៃទទឹង ឃុំព្រៃញាតិ ជាដើមថាៈ ល្បើកអក គឺលោកគ្រូអាចារ្យ ដួង តែងក្នុងគ្រាដែលលោកទៅទ្រាំដម្បូលោកតាហ៊ុងនៅភ្នំជីសូរ ។

២– អ្នកឲ្យការទាំងនេះមាន ៦ នាក់ បានកើតទាន់ស្គាល់ជាក់នូវលោកគ្រូអាចារ្យ ដួង ផង ហើយម្នាក់ទៀតជាចៅបង្កើតរបស់លោកគ្រូអាចារ្យ ដួង ថែមទៀត ។

៣– ល្បើកអកបែបថ្មីនេះជាស៊ីករែត មានច្រើនតែក្នុងស្រុកគងពិសី បាទី ព្រៃកប្បាស, ក្រៅពីស្រុកទាំងនេះគេពុំសូវស្គាល់ទេ, ទើបតែនឹងស្គាល់ក្នុងគ្រាដែលព្រះអង្គម្ចាស់ភាណុវង្ស ទ្រង់បង្កើតរោងពុម្ពកម្ពុជវរោកាស នៅខាងជើងវាលព្រះមេរុ ជាប់នឹងកំផែងខាងត្បូងនៃវត្តឧណ្ណាលោម ប្រហែលក្នុងឆ្នាំ ១៩១៩ តរៀងមក, ទ្រង់ឲ្យយកល្បើកអក[១]បែបថ្មីមកជួសជុលពាក្យពេចន៍ខ្លះបោះពុម្ពឡើង ទើបគេស្គាល់ទូទៅទាំងប្រទេស ។

---

(១) ល្បើកអកបែបថ្មីនេះ និងរឿងសោកសារីកា ចៅកៃ គឹម-ស៊ុយ ម្ចាស់បណ្ណាគារ គិម-សេង បានទិញសិទ្ធិផ្ដាច់អំពីចាងហ្វាងរោងពុម្ពកម្ពុជវរោភាស ក្នុងគ្រាខាងក្រោយអំពីកាលដែលព្រះអង្គម្ចាស់ភាណុវង្សទ្រង់សុគតទៅ ។

៤- អ្នកស្រាវជ្រាវបានរកឃើញល្បើកអកសុទ្ធតែបែបខ្លី ហើយគេឃើញបែបវែងមួយច្បាប់នៅវត្តក្រួច ស្រុកព្រៃឈរ (កំពង់ចាម) ។

៥- ខ្ញុំបានប្រៀបធៀបបែបខ្លីនិងបែបវែងឃើញថា អ្នកតែងរឿងនេះមាន ២ នាក់ គឺ ម្នាក់តែងបែបខ្លី ម្នាក់ទៀតតែងបន្តពីបែបខ្លី បង្កើនសេចក្ដីជាងពាក់កណ្ដាលទៀត ដើម្បីឲ្យទៅជាបែបវែង ដូចបានបញ្ជាក់ហើយខាងដើមនេះ ។ បានជាខ្ញុំថាដូច្នេះ ព្រោះខ្ញុំធៀបជើងកាព្យឃើញថា ពាក់កណ្ដាលខាងដើមនៃបែបវែងដូចគ្នានឹងបែបខ្លី ខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ ។ បែបខ្លីនោះច្រើនតែពាក្យទី ៧ នៃឃ្លាទី ១ ចាប់ចួននឹងពាក្យទី ៤ នៃឃ្លាទី ២, ពាក្យទី ៧ នៃឃ្លាទី ៣ ទទួលចួនពីពាក្យទី ៧ នៃឃ្លាទី ២ ហើយចាប់ចួននឹងពាក្យទី ៤ នៃឃ្លាទី ៤ ទៀត ។ ពីត្រឹមពាក់កណ្ដាលទៅខាងចុងនៃបែបវែង មានជើងកាព្យផ្សេងពីខាងដើម គឺ ការចាប់ចុងចួនពុំទៀងទាត់ទេ ច្រើនតែពាក្យទី ៧ ចាប់ចុងចួននឹងពាក្យទី ២ ហើយទឹកដមសំដីពុំមែនជាសំដីលោកសង្ឃផង ។ សំដីនៃអ្នកនិពន្ធផ្នែកខាងចុងនេះ ដែលអ្នកលេងហៅថា "សំដីមនុស្សឪត" លំនាំស្រដៀងគ្នានឹងពាក្យក្រមក្មេងអាយ៉ៃ ក្នុងជំនាន់អាណានិគមបារាំងសែស ដែលសុភាវ-ធម៌ខ្វះចុះដុនដាប, ថែមទាំងជើងកាព្យលោត ៗ គឺ កាព្យពាក្យ ៧ សោះទេ ប៉ុន្តែបេះតែបន្ថែមញឹក ៗ ឲ្យទៅជាពាក្យ ៨ ខ្លះ ពាក្យ ៩ ខ្លះ ដោយជុំ ៗ

*ហើយច្រើនប្រើពាក្យដែលមានអក្សរជាមួយគ្នាញឹកញាប់ផង ដូចពាក្យថា:*

ស្បើយទុក្ខជាសុខក្នុងកាយា នឹងញីនឹងញាក់ឲ្យយ៉ាងណា
ណាអូនស្រី កម្លាំងមានស្រាប់បំណាច់ថ្មី បំណុកប្ដីបំណាំប្អូន
មិនស្លូតសោះ ។ មិនស្លូតទេមាសមេតាងជឿប៉ុះ ស្រី
ប្រុសជួបប្រាណស្មានស្មុគស្មោះ បើបេះក្រឡុះដួបក្រឡោះ ប្រ
កោះប្រកិតជិតមិនឃ្លាត ។ល។

*មួយទៀតផ្នែកខាងចុងនេះ មានពាក្យសៀមលាយចម្រុះផង ដូចពាក្យថា : ចៃ (ចិត្ត), យ៉ាកយ៉ាប់ (លំបាកខ្លាំង), ប៉ៃខាងណូន (ទៅខាងឯណោះ), យ៉ាំងណៃ (យ៉ាងណា), មីដាយថាអៈរ៉ៃ (មិនបានថាម៉េច), គេធ្វើប៉យ (គេធ្វើព្រងើយ); ក្នុងទីបញ្ចប់ថា: កំណាព្យកំណត់ហ្មត់ជ័រល្មើ ។*

*មានពាក្យផ្សារដែលអ្នកនិពន្ធឯទៀត មិនដែលប្រើក្នុងការសរសេរ ដូចពាក្យថា :*

ខ្មោចអាគិរក់អូទីគួ(១) មិនគួរឲ្យយកជាក្បួនខ្នាត

---

(១) ពាក្យអូទីគួនេះ ទើបនឹងកើតថ្មី ជាសំដីអ្នកលេងភ្នំផាខបាខតាំគ្នានិយាយលេង, អ្នកខ្លះនិយាយថា អូប្រទូ សំដៅសេចក្ដីថា : មនុស្សដែលដក់ចិត្តនឹងល្បែងផ្សេង ៗ មានស្រីនិងស្រាជាដើម ។

សមតែធ្វើស្មុលជីចំណីត្មាត ទើបសមអារយាទឬករូបវា ។
មេណាវាដោយអាដែងគោះ ចំពោះមេគោះហ្នឹងស្រីសាធារណ៍
ស្មូវធ្វើសំផឹងវិញក៏ជា បានប្រាក់ជួលស្វារាំឲ្យមើល ។

*ព្រោះហេតុតែការពិនិត្យសង្កេតឃើញដូច្នេះ ទើបខ្ញុំហ៊ាននិយាយពេញមាត់ថា: ប្រាកដជាអ្នកនិពន្ធពីរនាក់ ម្នាក់គឺ លោកតាអាចារ្យ ដូង ធ្វើបានមួយផ្នែកខាងដើម មានសេចក្តីជាពាក្យបញ្ចប់ស្រេច ហើយស្រាប់តែម្នាក់ទៀត គឺ លោកបំរើឧទ័យ ធ្វើមួយផ្នែកខាងចុងថែមទៀតក្នុងកាលខាងក្រោយ ។*

*លោកតាអាចារ្យ ដូង ប្រាកដជាធ្វើមុន ព្រោះលោកតានេះ កើតក្នុង គ.ស. ១៨០៧ ។ លោកធ្វើចៅអធិការប្រហែលក្នុងព្រះជន្ម ៣០ ឆ្នាំ ត្រូវនឹង គ.ស. ១៨៣៧ ។ លោកតាអាចារ្យ ដូង តែងល្បើកអកប្រហែលក្នុង គ.ស. ១៨៣៧ ឬលើសបន្តិចបន្តួច ។ បើដូច្នោះមែន អាយុកាលនៃល្បើកអកបែបខ្លីបាន ១៣០ ឆ្នាំហើយមកទល់នឹងឆ្នាំ ១៩៦៧ នេះ ។*

*ខ្ញុំថាដូចខាងលើនេះ ចំពោះល្បើកអកបែបខ្លី ។ បើស្រដីចំពោះបែបវែងវិញថា លោកបំរើឧទ័យ តែង ។ ពាក្យថា « បំរើឧទ័យ » នេះ*

ជាការនៃមន្ត្រីក្នុងព្រះបរមរាជវាំង មានគេ ៗ គ្នាវាយបំបាក់មក ។ ខ្ញុំស្មានថា លោកបំរើឧទ្ទ័យ នេះ ប្រហែលជាលោកគា និង ដែលខ្ញុំបានស្គាល់លោកស្រពេចស្រពិលដែរ ក្នុងកាលដែលខ្ញុំជាសាមណេរនៅវត្តឧណ្ណាលោម លោកគាបំរើឧទ្ទ័យ និង ក៏ជាបព្វជិតចាស់ជកគង់នៅវត្តឧណ្ណាលោមដែរ ។

មានចំណុចមួយទៀតត្រង់នាមលោកចៅក្រមញ៉ាំង ដែលគួរឲ្យខ្ញុំយល់ថាប្រាកដជាលោកគាបំរើឧទ្ទ័យនិង ។ ព្រោះលោកញ៉ាំងនេះខ្ញុំរឹតតែស្គាល់ជាងលោកគា និង ទៅទៀត ។ ផ្ទះលោកញ៉ាំង នៅត្រង់ផ្លូវវិថីប៉ាស្ទ័រ និងវិថីណារុធ-អ៊ុម ខាងជើងវត្តលង្កា ។ ប្រហែលជាកាលលោកញ៉ាំងទើបនឹងចូលធ្វើការក្នុងតំណែងជាចៅក្រម ក្នុងគ្រាដែលខ្លួននៅកម្មោះ បានពឹងលោកបំរើឧទ្ទ័យនិង ក្នុងកាលដែលលោកជាមន្ត្រីក្នុងក្រុមជាងមាស ( ជាងស្អាទក្រាប់ ) ឲ្យគេងបន្ត · ដើម្បីជាគ្រឿងកែអផ្សុក ឬ ដើម្បីបញ្ជាក់ថាខ្លួនលោកទាំងពីរនាក់ធ្លាប់ប្រទះទឹងសភាពបែបដូចរឿងអកនោះ ។

ការបំរើឧទ្ទ័យធ្លាប់ទំតៗគ្នា លើជនមានឈ្មោះផ្សេងៗ ក៏មែនពិត, ប៉ុន្តែជនឯទៀត ដែលធ្លាប់បានទទួលការនេះ ពុំមែនមានឈ្មោះថាជាគរិទ, មានតែលោកបំរើឧទ្ទ័យនិង ទើបមានឈ្មោះថាជាគរី ព្រោះ

លោកបានតែរឿងស្រទបចេកជាដើម ។ រឿងស្រទបចេក លោកបំរើឧទ័យនិង តែងក្នុងកាល ព. ស. ២៤៣១ បើគិតមកទល់នឹងឆ្នាំនេះ (ព. ស. ២៥១០) ឃើញថាអាយុកាលនៃរឿងស្រទបចេកបាន ៧៩ ឆ្នាំហើយ ។ សាស្ត្រាអកបែបរ៉ែងបើលោកបំរើឧទ័យ និង តែងបន្ថែមក្នុងជំនាន់គ្នានោះ មុននេះក៏ដោយ ក៏ប្រាកដជាក្នុងកាលខាងក្រោយល្បើកអកបែបខ្ញុំរបស់លោកតាអាចារ្យជួងមែន ។

ចំណុចមួយទៀតនៅត្រង់ការប្រៀបធៀបអត្ថបទគឺ : អត្ថបទទាំងប៉ុន្មានរបស់លោកតាអាចារ្យជួងឥតអត្ថបទណាមួយវែងទេ, ដែលវែងជាងគេមានតែល្បើកអក ព្រោះលោកតែងក្នុងពេលនៅទំនេរ លើកំពូលភ្នំជីសូរ ហើយនិងរឿងសេកសារិការមួយទៀត ព្រោះជារឿងមានស្រាប់នៅក្នុងគម្ពីរ ។ ក្រៅពីនេះសុទ្ធតែអត្ថបទខ្លីៗ ព្រោះលោកតែងក្នុងគ្រាមមាញឹកផង ហើយជាធម្មតារបស់មនុស្សមានចិត្តរហ័ស តែងតែធ្វើការពុំសូវចប់ជួរេះ ។ ឯលោកបំរើឧទ័យមិនប្រាកដមានការវែងៗដូចរឿងស្រទបចេកក៏វែង រឿងអកដែលលោកលើកបន្ថែមទៀតក៏វែងដែរ; ខ្ញុំស្គាល់លោកពុំច្បាស់ ប៉ុន្តែខ្ញុំអាចសង្កេតបានថា ធម្មតាជាងមាសតែងតែមានព្យាយាមច្រើន មានចិត្តធ្ងន់ធ្ង មានចរិយាទឹងទង ។ ព្រោះតែលោកមានព្យាយាម

ដៃសមុទ្រក្រពាំងរូង នេះផង ។

វេលាម៉ោង ២ រសៀល ក៏ចាប់បន្តដំណើរតាមកាណូតមួយគ្រឿង កាត់តាមដៃសមុទ្រ និងសសៀរមាត់សមុទ្រក្រៅអស់រយៈពេល ៤ ម៉ោងទៀត ទើបបានទៅដល់ក្រុងខេមរភូមិន្ទ ដែលជាទីតាំងនៃខេត្តកោះកុង ។ ពេលចុះពីកាណូត មានសហជីវិនអភិបាលខេត្តរង តំណាងសហជីវិនអភិបាល ខេត្តបានទៅរង់ចាំទទួល និងនាំទៅស្នាក់អាស្រ័យនៅបដិសណ្ឋារមណ្ឌលប្រចាំខេត្ត ដែលមានការរៀបចំយ៉ាងផ្ចិតផ្ចង់គួរជាទីសរសើរ ។

លុះព្រឹកឡើង ថ្ងៃអាទិត្យទី ៣ មីនា ១៩៦៨ ក្រោយដែលស្រស់ស្រូបពេលព្រឹកហើយ វេលាម៉ោង ៨ ក៏មានរៀបចំពិធីមួយនៅទីស្នាក់ការនៃសង្គមរាស្ត្រនិយមប្រចាំខេត្ត ដើម្បីប្រគល់សៀវភៅអំណោយចំពោះបណ្ណាល័យថ្មីដែលកសាងឡើងនៅក្នុងវត្តព្រះគ្រូមេគណខេត្ត និងដើម្បីពិគ្រោះកិច្ចការផ្សេង ៗ ជាមួយព្រះសង្ឃ ដែលលោកមានភារៈគ្រប់គ្រងព្រះពុទ្ធសាសនានៅក្នុងខេត្តនោះ ។

នៅពេលដែលសហជីវិនអនុរដ្ឋលេខាធិការ អញ្ជើញដល់កន្លែងប្រារព្ធពិធី លោកបានទទួលបដិសណ្ឋារកិច្ចយ៉ាងគួរសមអំពីសំណាក់អស់លោកជានាយក្រុមការងារប្រចាំខេត្ត គឺមាន ៖

សមាជីវិន ពាន់-ថៃ អភិបាលខេត្តរងទី ២ តំណាងសហជីវិន

អភិបាលខេត្តដែលលោកមានបេសកកម្ម

សហ. ឡឹក-ឆាយ ចាងហ្វាងសាលាលហុកោះកុង

— ហោ-ផា នាយផ្នែកសាធារណការ

— ស៊ឹម-ឧដ្ឋាន នាយក្រុមហេរញ្ញវត្ថុប្រចាំខេត្ត

— ចាយ-សារឿន ចាងហ្វាងអនុវិទ្យាល័យកោះកុង

— គីម ស៊ូយ អធិការនៃ បឋមសិក្សា

— សុន ស៊ុកន នាយផ្នែកកសិកម្ម

— ម៉ែន-សុកាន នាយផ្នែកបសុពេទ្យ

លុះទទួលការគួរសមនេះហើយ សហជីវិនអនុរដ្ឋលេខាធិការ ព្រមទាំងសហការី បានអញ្ជើញចូលក្នុងមន្ទីររៀបចំពិធី ថ្វាយបង្គំព្រះសង្ឃ គឺមានព្រះតេជព្រះគុណ សង្ហនាដ-សួង ជាមេគណខេត្ត, ព្រះតេជព្រះគុណ ភី-ឆាំ ជាអនុគណ និងព្រះសង្ឃជាបរិស័ទចំនួន ២០ អង្គដែលគង់រង់ចាំនៅទីនោះ ៗ ក្រោយដែលសំណេះសំណាលបន្តិចមក សហជីវិនអនុរដ្ឋលេខាធិការបានថ្លែងសុន្ទរកថាមួយយ៉ាងក្បោះក្បាយ ដែលយើងនឹងចុះជូនទាំងស្រុងនៅទំព័របន្ទាប់នេះ ៗ បន្ទាប់ពីសុន្ទរកថា ព្រះសង្ឃក៏បានស្វាធ្យាយជយន្តោប្រសិទ្ធិពរ ជូនសហជីវិនអនុរដ្ឋលេខាធិ-ការ តំណាងព្រះរាជរដ្ឋាភិបាល រួចហើយព្រះតេជព្រះគុណមេគណព្រះអង្គ បានវេរព្រះសង្ឃដីកាទៅព្រះតេជព្រះគុណអនុគណ ថ្លែងអំណរគុណ

តបវិញ ដែលជាអាទិ៍ព្រះអង្គបានដៅបញ្ជាក់ថា ៖ លើកនេះហើយជាលើកទី ១ ដែលមានតំណាងរាជរដ្ឋាភិបាលខាងក្រសួងធម្មការ បានអញ្ជើញមកដល់ខេត្តនេះ ជាហេតុធ្វើឲ្យព្រះសង្ឃគ្រប់អង្គកើតការរំភើបព្រះទ័យក្រៃលែង ដើម្បីបានទុកាសប្រស្រ័យកិច្ចការផ្ទាល់ក្នុងរបៀបគ្រប់គ្រងផ្នែកពុទ្ធសាសនានៅក្នុងខេត្តឆ្ងាយនេះ ។

មួយទៀត ខាងក្បួនច្បាប់ព្រះពុទ្ធសាសនា គឺ គម្ពីរសៀវភៅធម៌អាថ៌នេះឯង ខេត្តនេះនៅមានការខ្វះខាតជាប្រាកដ ត្រូវបានក្រសួងធម្មការ ដឹកនាំសៀវភៅគ្រប់មុខ ដែលពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពផ្សាយហើយ យកមកឲ្យក្នុងគ្រានេះទុកដូចជាជំនួយមួយធំឥតគណនា ត្រូវចំសេចក្តីស្រេកឃ្លានដែលរង់ចាំច្រើនឆ្នាំមកហើយ ។ គួរបញ្ជាក់ថា ៖ រដ្ឋាភិបាលសង្គមរាស្ត្រនិយម ក្រោមព្រះកិច្ចដឹកនាំនៃសម្តេចឪជាអម្ចាស់ តែងបានគិតគូរគ្រប់ផ្នែកវឌ្ឍនធម៌ មានវិស័យព្រះពុទ្ធសាសនានេះ ជាដើម ។ មុននឹងបញ្ចប់ ព្រះតេជព្រះគុណព្រះអនុគណ បានរ៉ាយរ៉ាប់យ៉ាងខ្លី អំពីសេចក្តីលំបាកខ្វះក្នុងដំណើរប្រព្រឹត្តទៅនៃវត្តអារាមនានា ដោយសារនិយមទំនៀមស្រុក និងអំពីសំណូមពរ សុំឲ្យបាននិច្ចភត្តសំរាប់សមណៈសិស្សឲ្យបានច្រើនរូប ដើម្បីទៅសិក្សាបន្តវិជ្ជាពុទ្ធសាសនានៅក្រុងភ្នំពេញ ។

សហជីវិនអនុរដ្ឋលេខាធិការ បានទទួលសំណូមពរទាំងនេះ ដើម្បី

នាំយកមកលែលកឲ្យបានដូចបំណង និងបានប៉ប់រងថា នឹងជួយផ្តល់សៀវភៅក្បួនខ្នាតគ ៗ ទៅទៀត កាលណាក្រសួងបានបោះពុម្ពផ្សាយថ្មី ៗ ទៀតហើយ ។

បន្ទាប់ពីនោះ ក៏មានការប្តូរយោបល់គ្នា រវាងព្រះតេជព្រះគុណព្រះមេគណៈនិងអនុគណ អំពីបញ្ហាផ្សេង ៗ ដើម្បីរកមធ្យោបាយឲ្យកាន់តែមានប្រសិទ្ធភាពឡើងខាងវិស័យព្រះពុទ្ធសាសនា ។ រហូតដល់ម៉ោង ៩ កន្លះ ទើបបានហើយសព្វគ្រប់ ដោយមានថតរូបទុកជាអនុស្សាវរីយផង ។

សហជីវិនអនុរដ្ឋលេខាធិការ និងសហការី បានក្រាបថ្វាយបង្គំលាព្រះសង្ឃ និងលាអ្នកពជការគ្រប់គ្នា ចុះកាណូតធ្វើដំណើរវិលមកត្រពាំងរូងវិញ ។ នៅម៉ោង ១១ កន្លះ បានចូលទៅផែកោះកាពិ ដើម្បីទទួលអាហារថ្ងៃត្រង់ រួចក៏បន្តដំណើរតាមដៃសមុទ្រទៅទៀត រហូតម៉ោង ១៦ ទើបបានដល់ត្រពាំងរូង ហើយឡើងរថយន្តបន្តដំណើរមកភ្នំពេញ ដែលបានមកដល់នៅម៉ោង ២៤ អធ្រាត្រ ។

## ការចាប់អារម្មណ៍ពិសេស

ក្នុងដំណើរទស្សនកិច្ចទៅខេត្តកោះកុងនេះ ពិតមែនតែធ្វើដោយរយៈពេលយ៉ាងខ្លីបំផុត ប៉ុន្តែយើងអាចដកស្រង់ការចាប់អារម្មណ៍បានខ្លះអំពីទេសភាពស្រុក អំពីបរអ្នកស្រុក និង អំពីទំនៀមទម្លាប់ខ្លះទៀត ។

ទេសភាពទូទៅជាការប្លែកភ្នែកណាស់ ព្រោះជាទេសភាពសមុទ្រ ហើយជាឆ្នេរសមុទ្រផង ក៏មានកោះរដិបរដុប ដែលគ្របដណ្ដប់ទៅដោយដើមស្នាច់និងដើមកោងកាង ដែលបញ្ឈរស្រោង តែមិនខ្ពស់ប៉ុន្មានទេ ។ ឯខាងក្រោមដើមនោះ ជួនក៏គ្មានឃើញដីឡើយ សុទ្ធសឹងតែទឹក ។ ប្រឡាយធំដែលជាព្រែកនោះក្រវេចក្រវៀចបត់បែន នៅសងខាងមានដើមចាកដុះដង្ហែរត់ផ្លូវ ពាសពីមុខ ដើមកោងកាងរត់ផ្លូវអែបពីក្រោយ យូរៗឃើញមានផ្ទះអ្នកស្រុកមួយៗ ។ លុះទៅដល់ក្រុងខេមរភូមិន្ទ ក៏ឃើញថាជាក្រុងធំ លៃទុកដីជាសង្កាត់ភូមិឋាន ជាផ្លូវថ្នល់យ៉ាងច្រើនហើយធំទូលាយផង ។ អគាររាជការ សង់ពីបាយអស្ទើរតែទាំងអស់. ឯផ្ទះផ្សារ សង់ពីឈើជាល្វែងៗក៏ច្រើនណាស់ដែរ ។

អ្នកស្រុកដែលនៅជាប់នឹងសមុទ្រក្រៅ ដូចជានៅដងទង់ (ទីតាំងក្រុងខេមរភូមិន្ទ) នៅតាមក្រសាប នៅកោះកាពិ កោះមូល ភាគច្រើនជាអ្នកនេសាទ ។ ឯអ្នកនៅតាមឆ្នេរសមុទ្រចូលជ្រៅៗ ដូចជានៅត្រពាំងរូង នៅកោះកុងក្រៅជាដើម គេច្រើនធ្វើចំការដំណាំ មានគ្រៀវ សាវម៉ាវ មាក់ប្រាង ។ល។ របរពិសេសប្លែកមួយទៀត គឺការស្វែងរកខ្លឹមចន្ទន៍ក្រស្នា ប៉ុន្តែយើងស្ដាយជាអនេក ព្រោះពេលខ្លីពេក មិនអាចឲ្យយើងសាកសួរស្រាវជ្រាវយកពត៌មានច្បាស់អំពីរបរពិសេសនេះ មករៀបរៀងឲ្យបានល្អិតល្អន់ទៅឡើយ ។ ចំណែកទំនៀមស្រុកទេសក៏ដូចនោះដែរ

យើងគ្រាន់តែសង្កេតឃើញថា របៀបស្លៀកពាក់អ្នកស្រុក ពិសេសស្រីៗ ស្លៀកពាក់តែពណ៌យ៉ាងគគោករ របៀបរៀបចំផ្ទះ ក៏ប្លែកដោយគេនិយមតុបតែងលំអដោយផ្កាភ្ញី និងរូបលំអផ្សេងៗ ។

## សុន្ទរកថា

សហជីវិន អ៊ុកា-ម៉ុន

### អនុរដ្ឋលេខាធិការក្រសួងធម្មការ

សូមនមស្ការ ព្រះតេជព្រះគុណមេគណ

សូមពិតពុទ្ធដីកាព្រះថេរានុត្ថេរគ្រប់ព្រះអង្គ

សូមជំរាបសហជីវិនអភិបាលខេត្ត និងសហជីវិនី សហជីវិនទាំងអស់ ដែលបានអញ្ជើញមកជួបជុំក្នុងពេលនេះ ។

ខ្ញុំព្រះករុណា-ខ្ញុំមានសេចក្តីរីករាយដ៏ក្រៃលែង ដែលបានធ្វើជាតំណាងរាជរដ្ឋាភិបាល នាំយកសៀវភៅក្បួនខ្នាតនានាជាភាសាខ្មែរចំនួន ២៣០ក្បាល ដែលវិជ្ជាបានពុទ្ធសាសនបណ្ឌិត្យ នៅក្រសួងធម្មការបានបោះពុម្ពផ្សាយ ។

គោលបំណងធំរបស់រាជរដ្ឋាភិបាល ក្នុងការបោះពុម្ពដើម្បីផ្សាយនូវសៀវភៅទាំងនេះ អាស្រ័យលើមូលហេតុពីរយ៉ាងគឺ ៖

១-ដើម្បីផ្សព្វផ្សាយអក្សរច្បាប់ ដែលជាលក្ខណ៍គោលខាងព្រះពុទ្ធ-សាសនា ដែលខ្មែរយើងធ្លាប់តែបានគោរពរៀងមករាប់ពាន់ឆ្នាំមកហើយ ហើយសព្វថ្ងៃនេះទៀត យើងបានតម្កល់ទុកជាសាសនារបស់រដ្ឋពេញលក្ខណៈសឹងមានជាប់នៅក្នុងសន្តានចិត្តបណ្តាជនខ្មែរយើង នៅគ្រប់និគមជនបទទាំងអស់ ជាកស្តុតាងមានវត្តដ៏ស្កុកស្កម្ភនៃព្រះតេជព្រះគុណៈមគណៈនេះជាដើម ។

២ – ដើម្បីផ្សាយវប្បធម៌ខ្មែរ ឲ្យបានជ្រួតជ្រាបទៅគ្រប់ទិសទីក្នុងព្រះរាជាណាចក្រ ព្រោះថាវប្បធម៌នេះជាមូលដ្ឋានធ្វើឲ្យសន្តានចិត្តអ្នកស្រុកមានការក្តីស្ងាន និងមានគំនិតយល់សិបក្នុងអារ្យធម៌ជាតិ គឺនិយាយឲ្យខ្លីថាមានចិត្តស្រឡាញ់ជាតិខ្លួនកាន់តែមាំទាំឡើង ។

មួយទៀត, ដោយវប្បធម៌ខ្មែរយើងជាវប្បធម៌ចាស់បុរមបុរាណណាស់ គឺថាមានកំណើតមកជាង២ ពាន់ឆ្នាំមកហើយ ហើយដែលសម័យនោះប្រ-ទេសជិតខាងយើងខ្លះ មានប្រទេសសៀមជាដើមពុំទាន់ទាំងមានកើតរូបរាងមានឈ្មោះជាសញ្ជាតិមួយនៅឡើយផង ។ វប្បធម៌ខ្មែរសម័យដើមនោះតែងបានរីកចំរើនជាលំដាប់រៀងរាល់សតវត្ស មិនដែលអាក់ខានឡើយ ហេតុនេះហើយបានជាមែកធាងគ្រប់បែបគ្រប់យ៉ាងក្នុងវប្បធម៌ខ្មែរ មានសព្វគ្រប់ឥតសល់ចន្លោះ ដូចជាអក្សរសាស្ត្រ សិល្បៈ សាសនាជាដើម ។ រូបចម្លាក់យើងនៅប្រាសាទថ្មនានា ដែលកសាងសុទ្ធតែជាងមួយពាន់ឆ្នាំ

ហើយនោះសំដែងពីសិល្បៈដ៏ឆើតឆាយផង ពីទីយក្នុងអក្សរសាស្ត្រផង និងពីគោលគំនិតក្នុងសាសនាផង ។ តែបុរាណទាំងនេះហើយជាសាក្សីបញ្ជាក់ឲ្យយើងដឹងច្បាស់ថា ជាតិខ្មែរយើងជាអ្នកបង្កើតវប្បធម៌សម្រាប់ជាតិខ្មែរខ្លួនឯងផង សម្រាប់ផងជាតិនានានៅជិតខាងខ្លួនមានជាតិសៀមជាដើម ។ បានជាយើងពោលដូច្នេះ ព្រោះអ្នកស្រាវជ្រាវ អ្នកសិក្សានៃប្រទេសធំ ៗ មានបារាំង អង់គ្លេសជាដើម គេបានសរសេរបញ្ជាក់ជាច្រើនសៀវភៅថា: អារ្យធម៌-វប្បធម៌ខ្មែរបានចូលទៅស្រុកសៀម គ្រប់ផ្នែក ទាំងតួអក្សរ ទាំងភាសា ទាំងក្បាច់ចម្លាក់ របាំរាំរែក ទាំងគម្ពីរដីកាខាងព្រះពុទ្ធសាសនា និងទំនៀមទម្លាប់ផ្សេង ៗ សឹងតែគ្រប់យ៉ាង ៗ ជាភស្តុតាងដូចជាព្រះតេជព្រះគុណគ្រប់ព្រះអង្គ ដែលបានសិក្សាវិជ្ជាព្រះពុទ្ធសាសនាលោកធ្លាប់បានជ្រាបស្រាប់មកហើយថា គម្ពីរដើមដែលនៅជាក្រាំង ឬជាសាស្ត្រាស្លឹករឹតរបស់សៀមនោះ មានជានពិតប្រាកដជាអក្សរខ្មែរភាសាខ្មែរច្រើនណាស់ ។ បើយើងគិតពីប្រវត្តិពង្សាវតារវិញ យើងក៏ឃើញថា កាលសៀមតាំងបានជាអាណាចក្រខ្លួន ហើយក៏បង្កើតជាសង្គ្រាមយ៉ាងរឹកញាប់ជាមួយប្រទេសខ្មែរ ។ ជួនកាលខ្លះ សង្គ្រាមនោះ ក៏មានជ័យលើប្រទេសយើងម្តង ៗ គេក៏ដឹកជញ្ជូនយកក្បួនច្បាប់ខ្មែរ និង ចាប់យកអ្នកចេះដឹងខ្មែរយើង នាំទៅស្រុកគេដើម្បីសាបព្រោះពូជវប្បធម៌ខ្មែរឲ្យដុះដាលនៅឯនោះទៅ ។ ត្រង់នេះហើយ បានជា

សព្វថ្ងៃ មានអ្នកខ្លះ យល់ច្រឡំថាវប្បធម៌ខ្មែរយើងមានឥទ្ធិពលមកពីសៀមទៅវិញ ។ ការយល់នេះខុសស្រឡះ ឯការពិតខ្មែរយើងទេតើដែលជាអ្នកសាបព្រោះវិជ្ជានេះឲ្យទៅសៀម ហើយដោយសារតែសៀមលួចដឹកជញ្ជូនទៅស្រុកខ្លួនស្ទើរតែអស់យ៉ាងនេះ ទើបអ្នកសិក្សាខ្មែរយើងជាន់ៗក្រោយមិនមាននាំគ្នាទៅរៀនយកវិជ្ជារបស់ខ្លួន ដែលសៀមលួចទៅនោះយកមកវិញតែប៉ុណ្ណោះ ។ ទាំងនេះហើយជាភស្តុតាងបញ្ជាក់ពីដើមកំណើតវប្បធម៌ខ្មែរយើង ។

អាស្រ័យហេតុនេះ សព្វថ្ងៃ អ្នកស្រាវជ្រាវ អ្នកសិក្សាទាំងអស់គិតរកឃើញវិញនូវក្បួនខ្នាតបុរាណគ្រប់មុខវិជ្ជា ដើម្បីបោះពុម្ពផ្សាយឲ្យបានជ្រួតជ្រាបទៅគ្រប់ទិសទី ទោះបីទីនោះនៅឆ្ងាយអំពីរាជធានីយើងដូចក្រុងខេមរភូមិន្ទនេះជាដើម ឲ្យជនរួមជាតិយើងបានក្រេបរសជាតិពិតប្រាកដនៃវប្បធម៌ខ្មែរ តម្រូវតាមព្រះរាជបំណងដ៏ខ្ពង់ខ្ពស់នៃសម្តេចឪជាអគ្គមគ្គទេសក៍ជាតិយើង ដែលព្រះអង្គតែងត្រាស់បញ្ជាដាស់តឿនឲ្យកូនចៅព្រះអង្គដើរទៅរកផ្លូវចំរើនរុងរឿងគ្រប់វិស័យ មានវិស័យវប្បធម៌នេះជាអាទិ ។ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលមានអង្គសម្តេចឪជាព្រះប្រមុខ តែងតែខ្នះខ្នែងសម្រេចគោលបំណងនេះឲ្យបានរួសរាន់ជាដរាប ទើបបានក្រសួងធម្មការបានចេញសារាចរជាញឹក

ញាប់រំលឹកទៅគ្រប់គ្នា សុំឲ្យកសាងបណ្ណាល័យសម្រាប់ដំកល់និងផ្សាយក្បួនខ្នាតសព្វគ្រប់របស់ជាតិយើង តាំងគម្ពីរសាស្ត្រាចាស់ ៗ ដែលមានស្រាប់មកហើយ និងក្បួនច្បាប់ដែលបោះពុម្ពថ្មី ៗ ផង ៗ ឥឡូវព្រះតេជព្រះគុណ បានកសាងបណ្ណាល័យនេះ ពេញជាត្រូវតាមបំណងនៃរាជវង្សា-គិបាលហើយ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងតាងនាមរាជរដ្ឋាភិបាលនូវអំណរព្រះគុណព្រះអង្គ និងអំណរគុណចំពោះរាជការខេត្ត និងអ្នកមុខអ្នកការទាំងអស់ ដែលបានជួយជ្រោមជ្រែងឲ្យសមិទ្ធិនេះ បានសម្រេចឡើង ។ ហើយសូមថ្លែងទទួលម្តងទៀត នូវសេចក្តីសរសើរដ៏ស្មោះអស់ពីដួងចិត្ត ចំពោះព្រះទ័យឆ្លៀវឆ្លាសនៃព្រះតេជព្រះគុណមេគណនិងព្រះសង្ឃគ្រប់អង្គ ដែលបានយល់ច្បាស់នូវឧត្តមប្រយោជន៍ដ៏ជ្រាលជ្រៅក្នុងការផ្សាយវប្បធម៌ជាតិ ដោយការកសាងបណ្ណាល័យនៅក្នុងទីនេះ ។

ខ្ញុំព្រះករុណា-ខ្ញុំ សូមប្រសិទ្ធិពរ សូមឲ្យបណ្ណាល័យនេះ មានការរីកចំរើនយ៉ាងឆាប់រហ័សជាតិយោភាព ។

---

ភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៦៨

លេខ.៨០៩ ព.ប. សូមក្រាបបង្គំទូលក្រោមលម្អងធូលីព្រះបាទ នៃសម្ដេច
ព្រះសង្ឃរាជថ្នាក់ទី ១ ជាអម្ចាស់

សូមទ្រង់ព្រះមេត្តាជ្រាប ។

ក្នុងឱកាសមហានក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំ វក សំរិទ្ធិស័ក ព.ស. ២៥១២ នេះ,

ទូលព្រះបង្គំជាខ្ញុំ តាងនាមព្រះសង្ឃ និងគ្រហស្ថ ជាបុគ្គលិក នៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យទាំងមូល,

សូមព្រះពរវរោកាស ក្រាបបង្គំទូលថ្វាយ នូវព្រះសព្ទសាធុការពរ សិរីសួស្ដី ជោគជ័យមង្គលមហាប្រសើរ បរមសុខចម្រើនរុងរឿង ថ្វាយសម្ដេចជាអម្ចាស់ សូមលម្អងធូលី បានប្រកបតែនូវព្រះពុទ្ធពរ ៥ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណ គ្រប់ទិវាត្រី ។ សូមសម្ដេចជាអម្ចាស់ ប្រកបដោយនូវព្រះជន្មាទីឃាយុ ជាងរយព្រះវស្សា ដើម្បីបានជាម្លប់ដ៏ត្រជាក់សម្រាប់ពុទ្ធបរិស័ទក្នុងកម្ពុជរដ្ឋ និងបានគង់នៅជាព្រះពន្លឺត្រចះត្រចង់ នៃវប្បធម៌អក្សរសាស្ត្រជាតិ ។.

គួរពុំគួរ សូមសម្ដេចជាអម្ចាស់ ទ្រង់ព្រះមេត្តាប្រោស ។

ទូលព្រះបង្គំជាខ្ញុំ លាង ហាប់ អាន

នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ ថ្ងៃទី ១០ មេសា ១៩៦៨

លេខ.៤១៦ ព.ប សូមនមស្ការដោយគោរព ចំពោះសម្តេចព្រះ

មង្គលទេពាចារ្យ ឧត្តម ទីប្រឹក្សាគណៈធម្មយុត្តិកនិកាយ

វត្តបទុមវតី រាជវរារាមភ្នំពេញ

សូមព្រះករុណាជ្រាប ។

ក្នុងឱកាសមហានក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំ វក សំរឹទ្ធិស័ក ព.ស-២៥១២ នេះ

ខ្ញុំព្រះករុណា តាងនាមព្រះសង្ឃ និង គ្រហស្ថ ជាបុគ្គលិកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យទាំងមូល,

សូមព្រះឱកាស ប្រគេននូវព្រះពរសព្ទសាធុការ សិរីសួស្តីជោគជ័យមង្គលមហាប្រសើរ បរមសុខ ចំពោះសម្តេចជាម្ចាស់ សូមសម្តេចបានប្រកបតែដោយនូវព្រះពុទ្ធពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈគ្រប់ទិវារាត្រី ។ សូមសម្តេចជាម្ចាស់ប្រកបដោយព្រះជន្មាទីឃាយុ ជាងរយព្រះវស្សា មានព្រះសុខភាពបរិបូណ៌ ដើម្បីបានជាម្លប់ដ៏ត្រជាក់ សម្រាប់ពុទ្ធបរិស័ទគ្រប់ៗរូប តរៀងទៅ ។

គួរពុំគួរ សូមសម្តេចជាម្ចាស់មេត្តាប្រោស ។

ខ្ញុំព្រះករុណា លាង-ហាប់អាង

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ ថ្ងៃទី ១០ មេសា ១៩៦៨

លេខ ៥១១ ព.ប សូមនមស្ការដោយគោរព ចំពោះសម្តេចព្រះពោធិវង្ស

សូមព្រះករុណាជ្រាប ។

ក្នុងកាលសមហានក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំ វក សំរិទ្ធិស័ក ព.ស. ២៥១២ នេះ,

ខ្ញុំព្រះករុណា តាងនាមព្រះសង្ឃ និង គ្រហស្ថ ជាបុគ្គលិកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យទាំងមូល,

សូមព្រះវរោកាស ប្រគេនទូវព្រះពរសព្ទសាធុការ សិរីសួស្តី ជោគជ័យមង្គលមហាប្រសើរ បរមសុខចម្រើនរុងរឿង ចំពោះសម្តេចជាម្ចាស់ សូមសម្តេចបានប្រកបតែដោយទូវព្រះពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ គ្រប់ទិវារាត្រី ។ សូមសម្តេចជាម្ចាស់មានព្រះសុខភាពបរិបូណ៌ ប្រកបដោយព្រះជន្មា ទីឃាយុ ជាងវយព្រះវស្សា ដើម្បីគង់ជាម្លប់ដ៏ត្រជាក់សម្រាប់ពុទ្ធបរិស័ទក្នុងកម្ពុជរដ្ឋ និងបានជាព្រះពន្លឺចំពោះវប្បធម៌ អក្សរសាស្ត្រជាតិ ព្រមទាំងជាគ្រឹះនៃពុទ្ធិកសិក្សា ដែលមានវិវឌ្ឍន៍អស្ចារ្យ ក្នុងសម័យសង្គមរាស្ត្រនិយម ។

គួរពុំគួរ សូមសម្តេចជាអម្ចាស់ មេត្តាប្រោស ។

ខ្ញុំព្រះករុណា លាង-ហ៊ាប អាន

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ,